# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et de Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **ស៊ុន លក្ខិណា**

**ប៉ាន់ មុន្នីចិត្រា**

សាស្ត្រាចារ្យណែនាំ

ឯកឧត្តម **ឆឹង ស៊ីនៀង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ប៉ាន់ មុន្នីចិត្រា** និងនាងខ្ញុំ **ស៊ុន លក្ខិណា** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ជំនាញ នីតិសាស្ត្រ ជំនាន់ទី២១ ឆ្នាំសិក្សា ២០១៧-២០២១ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមគោរពប្រតិបត្តិ និង សម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះអ្នកមានគុណ របស់យើងខ្ញុំយ៉ាងក្រៃលែង និង លើសលុបដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាយ៉ាងកក់ក្តៅ ប្រកបទៅដោយព្រហ្មវិហារធម៌ ព្រមទាំងទូន្មានប្រៀនប្រដៅ និង ផ្តល់ទំនុកបំរុងគ្រប់យ៉ាង តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នេះ ។ កម្លាំងញើសឈាមធំក្រៃលែងដែល អ្នកមានគុណ លះបង់សម្រាប់កូនក្នុងការផ្គត់ផ្គង់ ទំនុកបំរុង ទាំងផ្នែកស្មារតី និង សម្ភារៈនានា ក៏ព្រោះតែចង់ឃើញធំដឹងក្តី និង មានចំណេះដឹងដែលជាស្ពានចម្លងផុតទុក្ខនាថ្ងៃអនាគត ។

យើងខ្ញុំ ក៏សូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាវជ្រៅផងដែរ ជូនចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ លុយ ចណ្ណា** និង សាស្ត្រាចារ្យ ទាំងអស់នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្រួលការងារគ្រប់បែបយ៉ាង និង បង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ និង អស់ពីកម្លាំងកាយចិត្តដល់ពួកយើងខ្ញុំ រយៈពេល ៤ ឆ្នាំ កន្លងមកនេះ ។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណ និង ដឹងគុណយ៉ាងក្រៃលែងជូនចំពោះ **ឯកឧត្តម នឹម ស៊ីនៀង** ដែលបានចំណាយពេលផ្ទាល់ខ្លួនដ៏មានតម្លៃក្នុងការជួយណែនាំ និង កែតម្រូវរាល់កំហុសឆ្គងផ្សេងៗដែលកើតមានឡើង ព្រមទាំងបានផ្តល់នូវអនុសាសន៍ដែលជាគំនិតថ្មី ប្រៀបបានជាពន្លឺក្នុងការសរសេរ បំពេញបន្ថែមនូវចំណុចខ្វះខាតនានា ចាប់តាំងពីថ្ងៃផ្តើម រហូតដល់ទទួលបានសមិទ្ធផលជាស្ថាពរនូវសារណានេះ ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គលដល់លោក អ្នកមានគុណទាំងពីរ និង លោកគ្រូ អ្នកគ្រូដែលបានបង្ហាត់បង្រៀន តាំងពីថ្នាក់មតេយ្យរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឲ្យជួបតែពុទ្ធពរ ទាំងបួន ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្រេចបាននូវគោលបំណង និង ទទួលបាននូវ សេចក្តីសុខ ចម្រុងចម្រើន មានជោគជ័យគ្រប់បែបយ៉ាងក្នុងការបំពេញកាតព្វកិច្ចការងារ កុំបី ឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

តាមរយៈការសិក្សារយៈពេលបួនឆ្នាំ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ក្រោយការសិក្សារយៈពេលកន្លងមកនេះ យើងខ្ញុំទទួលបាននៅចំណេះដឹងជាច្រើន ក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានធ្វើការចងក្រងជាស្នាដៃស្រាវជ្រាវនេះឡើងក្រោមការជួយជ្រោមជ្រែងយ៉ាងខ្លាំងពី **ឯឧត្តម ឆឹង ស៊ីនៀង** ។ ក្នុងស្នាដៃសារណានេះផងដែរ ត្រូវបានធ្វើការបែងចែកជា ២ជំពូក ដែលក្នុងជំពូកទី១ ធ្វើការបង្ហាញពី **ការចោទប្រកាន់** និង ជំពូកទី២ ធ្វើការបង្ហាញពី **ការតម្កល់រឿងទុកឥតចាត់ការ** ។ ការស្រាវជ្រាវនៅលើប្រធានបទ ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការនេះផងដែរ មានគោលបំណងក្នុងការស្រាវជ្រាវ ចងក្រងជាស្នាដៃនេះឡើង គឺដើម្បីទុកជាឯកសារសម្រាប់ទុកជាស្នាដៃឲ្យអ្នកជំនាន់ក្រោយទុកធ្វើការស្រាវជ្រាវបន្ត និង ដើម្បីសិក្សាឲ្យកាន់តែលម្អិត ទៅលើប្រធាបបទមួយនេះ ។ ម៉្យាងទៀត ដើម្បីសិក្សាឱ្យកាន់តែស៊ីជម្រៅទៅលើការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ឲ្យបានយល់កាន់តែច្បាស់ផងដែរ នៅការលំបាករបស់និស្សិតថ្នាក់បរិញ្ញាបត្របច្ចុប្បន្ន និង អនាគត ដែលត្រូវធ្វើការសិក្សាលើចំណុចនេះ ។

តាមរយៈស្នាដៃមួយនេះ យើងខ្ញុំសង្ឃឹមថា នឹងបានចូលរួមក្នុងការជាជំនួយដល់ការសិក្សាដល់និស្សិតជំនាន់ក្រោយទុកជាឯកសារស្រាវជ្រាវ និង មិត្តអ្នកអានធ្វើការស្វែងយល់នៅដំណាក់កាលនៃការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ នេះផងដែរ។

យើងខ្ញុំសូមធ្វើការសូមទោស នូវរាល់កំហុសឆ្គងទាំងឡាយដែលបានកើតមានឡើងក្នុងស្នាដៃមួយនេះដោយអចេតនាក្នុងកិច្ចអធិប្បាយ និង អក្ខរាវិរុទ្ធ ហើយសូមទទួលយកនៅការរិះគន់នានាពីសំណាក់មិត្តអ្នកអានលោកសាស្ត្រចារ្យ និស្សិតក្នុងន័យស្ថាបនា ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ការចោទប្រកាន់**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការចោទប្រកាន់** ........................................ ៥

១.១ ស្ថាប័នទទួលបន្ទុកក្នុងការចោទប្រកាន់........................................៥

១.១.១ ស្ថាប័នអយ្យការ........................................៥

១.១.២ គោលការណ៍នៃកាចោទប្រកាន់........................................៦

១.១.២.១ គោលការណ៍នីត្យានុគោលភាពនៃការចោទប្រកាន់........................................៦

១.១.២.១.១ ធាតុនីត្យានុគោល........................................៧

១.១.២.១.២ ធាតុសត្យានុម័ត........................................៧

១.១.២.១.៣ ធាតុអត្តនោម័ត........................................៨

១.១.២.២ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់........................................៨

១.២ នីតិវិធីនៃការចោទប្រកាន់ ........................................១០

១.២.១ ការពិនិត្យសំណុំរឿង........................................១០

១.២.២ ការបើកការស៊ើបសួរ........................................១០

១.២.២.១ ការបើកការស៊ើបសួរដោយផ្ទាល់របស់តំណាងអយ្យការ........................................១៣

១.២.២.២  ការបើកការស៊ើបសួរជំនួស........................................១៣

១.២.២.៣ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់........................................១៥

១.២.២.៤ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម........................................១៥

**ផ្នែកទី២៖ បញ្ហាប្រឈមក្នុងការចោទប្រកាន់របស់តំណាងអយ្យការ**........................................ ១៧

១.១ កង្វះធាតុផ្សំនៃបទល្មើស........................................១៨

១.១.១ ធាតុនីត្យានុគូល........................................១៨

១.១.២ ធាតុសត្យានុម័ត........................................១៨

១.១.៣ ធាតុអត្តនោម័ត........................................១៨

១.១.៤ ការអន្តរាគមន៍របស់អ្នកមានអំណាច........................................១៩

១.១.៥ កត្តានយោបាយ........................................២០

# ជំពូកទី២
# ការតម្កល់រឿងទុកឥតចាត់ការ


**ផ្នែកទី១៖ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ** ............ ២១
១.១ អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ............ ២១
១.២ នីតិវិធីក្នុងការតម្កល់រឿងទុកឥតចាត់ការ............ ២២
១.២.១ ការពិនិត្យសំណុំរឿង............ ២២
១.២.២ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ............ ២៣
១.២.៣ ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ............ ២៣
១.២.៤ បណ្តឹងតវ៉ាអំពីដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ............ ២៣
**ផ្នែកទី២៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**............ ២៤
១.១ កង្វះធាតុផ្សំនៃបទល្មើស ............ ២៤
១.២ ការរលត់បណ្តឹងអាជ្ញា ............ ២៤
១.២.១ មរណភាពនៃជនល្មើស............ ២៥
១.២.២ ផុតអាជ្ញាយុកាលនៃបទល្មើស............ ២៥
១.២.៣ ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ............ ២៦
១.២.៤ អាជ្ញាអស់ជំនុំ............ ២៦
១.២.៥ ការលើកលែងទោសជាទូទៅ............ ២៧
១.២.៦ ការសម្រុះសម្រួល............ ២៧
១.២.៧ ការដកពាក្យបណ្តឹង............ ២៨
១.២.៨ ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស............ ២៨
១.៣ កត្តាផ្សេងទៀតដែលនាំឲ្យមានការតម្កល់រឿងទុកឥតចាត់ការ............ ២៩
១.៣.១ ជនល្មើសជាជនវិបល្លាសស្មារតី............ ២៩
១.៣.២ ការការពារស្របច្បាប់............ ៣០
១.៣.៣ ស្ថានភាពចាំបាច់............ ៣០
១.៣.៤ ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ............ ៣០
១.៣.៥ អានុភាពនៃកម្លាំង ឬ ការបង្ខំ............ ៣០
១.៣.៦ ជនល្មើសជាអានីតិជនក្រោមអាយុ១៤ឆ្នាំ............ ៣១
១.៤ អភ័យឯកសិទ្ធិ ............ ៣១
១.៥ អនិយតភាពនៃនីតិវិធី............ ៣១

**ផ្នែកទី៣៖ បញ្ហាប្រឈមក្នុងការតម្កល់រឿងទុកឥតចាត់ការ** ............................................ ៣២
១.១ កង្វះធាតុផ្សំនៃបទល្មើស ................................................................................ ៣៣
១.១.១ ធាតុនីត្យានុកូល........................................................................................ ៣៣
១.១.២ ធាតុសត្យានុម័ត........................................................................................ ៣៣
១.១.៣ ធាតុអត្ថនោម័ត......................................................................................... ៣៤
១.២ ការអន្តរាគមន៍របស់អ្នកមានអំណាច......................................................................... ៣៤
១.៣. កត្តានយោបាយ ............................................................................................ ៣៥
**សេចក្តីសន្និដ្ឋាន**.................................................................................................. ៣៦
**អនុសាសន៍**......................................................................................................... ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. មូលហេតុនៃការសិក្សាស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ជាប្រទេសមួយដែលបានប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ពោលគឺ អំណាចរបស់រដ្ឋត្រូវបែងចែកជា បី រួមមាន៖ អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និង អំណាច តុលាការ ។ ហើយអំណាចនីមួយៗ មានការបែងចែកដាច់ពីគ្នាមិនមានអំណាចណាមួយជ្រៀតជ្រែកកិច្ចការ ផ្ទៃក្នុងបានឡើយ ប៉ុន្តែអំណាចនីមួយៗមានការទំនាក់ទំនងគ្នាយ៉ាងល្អ នៅក្នុងការកសាងជាតិ តាមរយៈបទប្បញ្ញត្តិនានា ។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងនៅក្នុងការ បង្កើតច្បាប់ សម្រាប់ជាការការពារផលប្រយោជន៍សាធារណៈ រក្សាសន្តិសុខសង្គម តាមរយៈការបង្កើតឲ្យមាន ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងគោលបំណងដាក់ទោសទណ្ឌទៅលើជនគ្រប់រូបដែលប្រព្រឹត្ត ខុសច្បាប់ ឬ ល្មើសច្បាប់ដែលមានចែងជាធរមាន និងដើម្បីថែរក្សា ស្ថេរភាព របស់សង្គមឲ្យមាន ភាពសុខសន្តិភាព នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ដូច្នេះ ហើយដើម្បីចូលរួមបង្ការ ទប់ស្កាត់ នូវបទល្មើសដែលកើតមាន ទើបរាជរដ្ឋាភិបាល ក្រើនរំលឹកដល់មន្ត្រីអនុវត្តច្បាប់ត្រូវ រឹតបន្តឹងក្នុងការអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់ និង ម៉ត់ចត់បំផុត ។

ស្របជាមួយគ្នានេះដែរ ដោយនៅក្នុងរដ្ឋធម្មនុញ្ញ ជំពូកទី១១ ថ្មី ត្រង់មាត្រា ១២៨ ថ្មី បានចែងថា អំណាចតុលាការ ជាអំណាចឯករាជ្យ ធានារក្សាអនាគតិ និង ការពារសិទ្ធិ សេរីភាព របស់ប្រជាពលរដ្ឋ ហើយ អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាល ផង ។ នៅពេលដែលមានបទល្មើសកើតឡើង ស្របតាមរដ្ឋធម្មនុញ្ញ មាត្រា ១៣១ ថ្មី ចែងថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ ហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា ៣ ចែងថា បណ្តឹងអាជ្ញា អនុវត្តទៅលើបុគ្គលគ្រប់រូប ទាំង រូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ជាមួយគ្នានេះដែល នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង សង្កេតឃើញថា មានច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពី វិសោធនកម្មច្បាប់នីតិវិធី ឆ្នាំ ២០០១ នឹងត្រូវបាននិរាករណ៍ ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។ នីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំវិធានការដែលគ្រប់គ្រងលើការរៀបចំ ការប្រព្រឹត្តទៅ និង ការវិនិច្ឆ័យ នៃរឿងក្តីព្រហ្មទណ្ឌ ដើម្បីធានានូវប្រសិទ្ធិភាពនៃដំណើរការរបស់តុលាការ ក៏ដូចជា ការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ។ ម៉្យាងទៀត នីតិវិធីព្រហ្មទណ្ឌត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ជាអាទិ៍ ដូចជាទាក់ទងដល់ការកំណត់សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់យុត្តា

ធិការព្រហ្មទណ្ឌ និង ទាក់ទងទៅនឹងបែបបទនីតិវិធីនៃ ការពិនិត្យ ការចោទប្រកាន់ ការស្រាវជ្រាវស្វែងរកភស្តុតាង ព្រមទាំងនីតិវិធីនៃការ ជំនុំជម្រះ និង ការតម្កល់រឿងទុកឥតចាត់ការ ។

នៅពេលដែលមានបទល្មើសមួយកើតឡើង គេសង្កេតឃើញមាន នីតិវិធីជាច្រើនត្រូវបានអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមវិធាន នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធ្វើការកំណត់អំពីអត្ថិភាពតាមផ្លូវច្បាប់នៃបទល្មើសនោះ មុនពេលដែលជនល្មើសត្រូវបានផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ។ ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ គឺចែកចេញជា ៤ ដំណាក់កាលគឺ ការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និង ការជំនុំជម្រះ ។ នៅក្នុងដំណាក់កាលស៊ើបអង្កេត គឺជាសមត្ថកិច្ចរបស់ នគរបាលយុត្តិធម៌ ក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការស៊ើបអង្កេត ស្វែងរកភស្តុតាង និង ចាប់ខ្លួនជនល្មើស ។ នៅក្នុងដំណាក់ទាំង ៤ នៃនីតិវិធីព្រហ្មទណ្ឌនោះ នៅក្នុងដំណាក់កាល នៃការចោទប្រកាន់ ព្រះរាជអាជ្ញា មិនត្រឹមតែធ្វើការចោទប្រកាន់នោះទេ ព្រះរាជអាជ្ញាក៏អាចធ្វើការតម្កល់រឿងទុកឥតចាត់ការ បានដែរ នៅពេលដែលបទល្មើសនោះមិនគ្រប់នូវធាតុផ្សំនៃបទល្មើសជាដើម ដែលតម្រូវឲ្យព្រះរាជអាជ្ញា ត្រូវធ្វើការតម្កល់រឿងនោះទុកឥតចាត់ការ ។ បន្ទាប់ពីការសិក្សាស្រាវជ្រាវរយៈពេលកន្លងមកនេះ យើងខ្ញុំបានកំណត់នូវចំណុចសំខាន់ ក៏ដូចជានីតិវីធីទាក់ទងទៅនឹង **ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ** របស់ព្រះរាជអាជ្ញាបានមួយចំនួន ដែលទាំងនោះគឺសុទ្ធសឹងតែជាចំណុចសំខាន់ ។ បុព្វហេតុ ដែលនាំឲ្យក្រុមយើងខ្ញុំជ្រើសរើសយកនូវប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ គឺដើម្បីទទួលបាននូវចំណេះដឹងបន្ថែមទៀតតាមរយៈការពិនិត្យទៅលើច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងទទួលបានបទពិសោធន៍ពី លោកគ្រូសាស្ត្រចារ្យ ដែលមានជំនាញផ្នែកព្រហ្មទណ្ឌ និងការយល់ដឹងពីនីតិវិធីនៃការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ បញ្ហាប្រឈមមួយចំនួននៅក្នុងការអនុវត្តជាក់ស្តែងរបស់តំណាងអយ្យការនាពេលកន្លងមកនេះ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងទៅតាមការសិក្សា និង ស្រាវជ្រាវកន្លងមក ដើម្បីឲ្យយល់កាន់តែច្បាស់ ទាក់ទងទៅនឹង ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ដែលជានីតិវិធីយ៉ាងសំខាន់នៅក្នុងរឿងព្រហ្មទណ្ឌ នោះ យើងខ្ញុំបានកំណត់ចេញជាបញ្ហាគតិយុត្ត មួយចំនួនថា៖

- តើការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ មានសញ្ញាណទូទៅយ៉ាងដូចម្តេច ? ហើយតើការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ មាននីតិវិធី និង បញ្ហាប្រឈមអ្វីខ្លះ ?
- តើស្ថាប័នណាដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ? តើស្ថាប័នណាទទួលបន្ទុកក្នុងការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ? តើស្ថាប័ននោះមានតួនាទីភារៈកិច្ចអ្វីខ្លះ នៅក្នុងដំណើរការនីតិវិធីរបស់តុលាការ នៅក្នុងការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ?

ហើយតើ ស្ថាប័ននោះមានបញ្ហាប្រឈមអ្វីខ្លះ នៅក្នុងការអនុវត្តនីតិវិធីក្នុងការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះផងដែរ គឺយើងខ្ញុំមានគោលបំណងដើម្បីយកទៅអនុវត្តការងារជាក់ស្តែង និង ការពង្រឹងនូវចំណេះដឹងក្នុងសកលវិទ្យាល័យ ធ្វើការផ្សារភ្ជាប់ជាមួយនឹងការអនុវត្តជាក់ស្តែង ព្រមទាំងចូលរួមចែករំលែក និង ការកែលម្អទៅលើចំណុចមួយចំនួនដែលនៅមានការខ្វះខាត ដើម្បីសម្រេចបាននូវប្រសិទ្ធិភាពនៃការស្រាវជ្រាវ និងប្រកបដោយចីរភាព ។

ហើយនៅក្នុងគោលបំណងនៃការស្រាវជ្រាវទៅលើប្រធានបទ ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ មានចំណុចសំខាន់មួយចំនួនដូចជា៖

- ស្វែងយល់ពីដំណើរការនីតិវិធីបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលអយ្យការ
- ស្វែងយល់ពីដំណើរការចោទប្រកាន់របស់តំណាងអយ្យការដូចជា៖
  - ➢ ការបើកការស៊ើបសួរ
  - ➢ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម
  - ➢ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់
- យល់ដឹងពីនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ
- បញ្ហាប្រឈមនៅក្នុងការអនុវត្តជាក់ស្តែងរបស់តំណាងអយ្យការ
  - ➢ ការអន្តរាគមន៍របស់អ្នកមានអំណាច
  - ➢ កត្តានយោបាយ ។

## ៤. ទំហំ និង ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយហេតុថា តុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា មាននៅគ្រប់ រាជធានី-ខេត្ត ហើយយើងខ្ញុំ ពុំអាចធ្វើការសិក្សាស្រាវជ្រាវឲ្យបានគ្រប់តុលាការទូទាំងប្រទេសបានទេ ។ ដូច្នេះហើយ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទស្តីពី **“ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ” ។** ហើយការសិក្សានេះផងដែរ គឺផ្តោតទៅលើ ជម្រើសនៃការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ម្យ៉ាងទៀតយើងខ្ញុំ សិក្សាស្រាវជ្រាវដោយធ្វើការផ្អែកទៅលើច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលមានចែងជាធរមាននៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ភ្ជាប់ជាមួយការអនុវត្តជាក់ស្តែង នៅក្នុងសាលាដំបូងរាជធានីភ្នំពេញ ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

សារណានេះគឺ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវ និង ធ្វើការរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និង វិភាគ លើយកជាឧទាហរណ៍មួយចំនួនមកធ្វើការបង្ហាញ ។ យើងខ្ញុំបានធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ព្រមទាំងឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីធានានូវភាពត្រឹមត្រូវប្រាកដនិយម និង ប្រសិទ្ធិភាពកាន់តែប្រសើរឡើង ។ ហើយព័ត៌មានទាំងអស់នេះត្រូវបាន ដកស្រង់ ចេញពីប្រភពមួយច្បាស់លាស់ដូចជា ការបកស្រាយរបស់អ្នកច្បាប់ល្បីៗ និង អ្នកមានបទពិសោធន៍ នៅក្នុងវិស័យច្បាប់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ ព្រះរាជាណាចក្រកម្ពុជា ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

យោងទៅតាមបញ្ហាគតិយុត្ត ដែលបានលើកឡើងខាងលើ និង ឆ្លងតាមរយៈការស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទរយៈពេលកន្លងមកនេះ យើងខ្ញុំបានបែងចែកចេញជា ២ (ពីរ) ជំពូក រួមមាន៖

- **ជំពូកទី១ ការចោទប្រកាន់**
- **ជំពូកទី២ ការតម្កល់រឿងកតតចាត់ការ**

# ជំពូកទី ១
# ការចោទប្រកាន់

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការចោទប្រកាន់

ជាទូទៅ នៅក្នុងជីវភាពរស់នៅសព្វថ្ងៃតែងតែកើតមានឡើង នូវអំពើរំលោភបំពាន ដែលបុគ្គលបាន ប្រព្រឹត្តទៅលើជនងាយរងគ្រោះ ហើយនៅក្នុងការប្រព្រឹត្តអំពើរំលោភបំពានជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរង គ្រោះ តែងបានដាក់ពាក្យបណ្តឹងទៅកាន់អាជ្ញាធរមានសមត្ថកិច្ចរួមមាន ការដាក់ពាក្យបណ្តឹងទៅកាន់ ប៉ុស្តិ៍ នគរបាល ឬ តុលាការ ជាដើម ។ ហើយដើម្បីធ្វើការចោទប្រកាន់ទៅលើអំពើរំលោភបំពានដែលប្រព្រឹត្តដោយ ចារី ឬ សហចារីបាន គឺនៅក្នុងពាក្យបណ្តឹងត្រូវតែមានសរសេរនូវ អង្គហេតុ អំពើល្មើស និង បញ្ជាក់អំពី អត្តសញ្ញាណ នៃជនសង្ស័យ ឬ ជនល្មើសនោះ ដែលជាហេតុនាំអោយ តុលាការ ឬមន្ត្រីនគរបាលយុត្តិធម៌ ងាយស្រួលក្នុងការ ធ្វើការបើកការស៊ើបអង្កេត ការចោទប្រកាន់ និង ការជំនុំជម្រះរបស់តុលាការ ។

ការដាក់ពាក្យបណ្តឹងដោយជនរងគ្រោះ ឬ ហៅថា បណ្តឹងសាមញ្ញ គឺវាគ្រាន់តែជាការប្រកាសរបស់ ជនរងគ្រោះថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើសតែប៉ុណោះ ។ ហើយបណ្តឹងនេះគ្មានអានុភាពតាមផ្លូវច្បាប់ណា មួយ ដែលអាចនាំឲ្យមានការចោទប្រកាន់ជា បទព្រហ្មទណ្ឌនោះទេ ។[1]

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ការចោទប្រកាន់ គឺសំដៅដល់ការកំណត់អំពី អត្ថិភាពនៃបទល្មើសដោយស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋដែលបានកំណត់ក្នុងច្បាប់ជាធរមាន ។ យោងតាម មាត្រា ៤ កថាខណ្ឌទី ២ បានចែងថា អយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង សុំឲ្យអនុវត្តច្បាប់ នៅចំពោះយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះ ។[2]

ទោះបីគ្មានពាក្យបណ្តឹងពីជនរងគ្រោះ ឬ បុគ្គលណាមួយក៏ដោយ ស្ថាប័នអយ្យការអាចធ្វើ ការចោទ ប្រកាន់ គ្រប់អំពើដែលជាបទល្មើស លើកលែងតែមានករណីពិសេសដែលមានបញ្ញត្តិក្នុងច្បាប់ ។

### ១.១ ស្ថាប័នទទួលបន្ទុកក្នុងការចោទប្រកាន់

#### ១.១.១ ស្ថាប័នអយ្យការ

ស្របតាមរដ្ឋធម្មនុញ្ញ និង ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ស្ថាប័នដែលមានសមត្ថកិច្ច ក្នុងការទទួលបន្ទុកក្នុងការចោទប្រកាន់ គឺមានតែអង្គការអយ្យការតែមួយគត់ ។[3]

[1] មាត្រា ៦ នៃក្រមនីតិវីធីព្រហ្មទណ្ឌ

[2] មាត្រា ៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[3] មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាដោយអយ្យការ គឺ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ។ ហើយអ្នកមានសមត្ថកិច្ចធ្វើការសម្រេចចោទប្រកាន់មាន៖

១. ព្រះរាជអាជ្ញា (មាត្រា ៤០ កថាខណ្ឌទី២) ។

២. ព្រះរាជាអាជ្ញារង (មាត្រា៣៨) ។

(សម្គាល់៖ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង) ។

### ១.១.២ គោលការណ៍នៃការចោទប្រកាន់

នៅក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌជាសាកល មានគោលការណ៍នៃការចោទប្រកាន់ចំនួន ០២ (ពីរ) គឺ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និង គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់ ។ គោលការណ៍ទាំងពីរនេះ ត្រូវបានយកមកប្រើប្រាស់សម្រាប់អង្គការអយ្យការ ដែលមានតួនាទី ក្នុងការចោទប្តឹង ។ ក្នុងការជ្រើសរើសនូវគោលការណ៍ណាមួយមកអនុវត្ត គឺអាស្រ័យលើស្ថានភាពនៃសង្គមជាក់ស្តែង ។ ហេតុនេះ ដើម្បីស្វែងយល់អំពីការប្រើប្រាស់ និង អត្ថន័យនៃគោលការណ៍ទាំងពីរខាងលើ យើងនឹងធ្វើការបកស្រាយ ដូចតទៅ៖

#### ១.១.២.១ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ត្រូវបានយកមកប្រើប្រាស់នៅប្រទេសអាឡឺម៉ង់ និង ច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់កម្ពុជា ។ ប្រសិនបើបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ព្រះរាជអាជ្ញាត្រូវតែធ្វើការប្តឹងចោទប្រកាន់ ដែលប្រៀបបាននឹងម៉ាស៊ីនយន្តដោយមិនពិចារណាថាជារឿងតូចតាច ឬ មានការប៉ះពាល់សណ្តាប់ធ្នាប់សង្គមតិចតួចអ្វីនោះទេ គឺឲ្យតែមានអង្គហេតុដែលជាបទល្មើសកើតឡើង ព្រះរាជអាជ្ញាត្រូវតែធ្វើការ ប្តឹងចោទប្រកាន់ទាំងអស់ ។ ហើយព្រះរាជអាជ្ញា គ្មានសិទ្ធិតម្កល់រឿងទុកឥតចាត់ការនោះទេ ហេតុនេះហើយទើបមានមតិលើកឡើងថា "ព្រះរាជអាជ្ញាមិនបានដើរតួនាទីជាអ្នកការពារផលប្រយោជន៍សង្គមនោះទេ" ។

គោលការណ៍នេះ បានផ្តល់នូវផលវិជ្ជមានផងដែរ គឺ គ្មានការរំលោភអំណាច ឬ បំពានច្បាប់ ក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដើម្បីជាប្រយោជន៍ខ្លួននោះទេ មានន័យថា ព្រះរាជអាជ្ញា បានដើរតួរជា អព្យាក្រឹត្យ និង ឯករាជ្យ ដោយមិនរណបទៅនឹងអង្គការណាមួយឡើយ ។រីឯ ផលអវិជ្ជមានវិញ គឺគោលការណ៍នេះ មិនបានផ្តល់ប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាងទេ តែបែជាបណ្តាលឲ្យមានការកកស្ទះសំណុំរឿង ដែលផ្ទុយទៅនឹងភាពឆាប់រហ័ស និងយុត្តិធម៌ ក្នុងសង្គមទៅវិញ។ ដោយសារតែមានមូលហេតុបែបនេះហើយ បានជានាំឲ្យមានគោលការណ៍ កាលានុវត្តភាពនៃការចោទប្រកាន់ ដែលជាកម្មវត្ថុនៃការបកស្រាយខាងក្រោម ។

### ១.១.២.១.១ ធាតុនីត្យានុកូល

ធាតុនីត្យានុកូល សំដៅលើបញ្ញត្តិនៃច្បាប់ដែលនៅជាធរមាន ហើយដែលបានចាត់ទុកថាអំពើណាមួយជាបទល្មើស ដែលច្បាប់បានចែងទុកឲ្យអំពើនោះ ត្រូវផ្តន្ទាទោសតាមច្បាប់កំណត់ ។ ធាតុនីត្យានុកូលនៃបទល្មើស និងធាតុនីត្យានុកូលនៃទោស គឺត្រូវតែមានចែងក្នុងច្បាប់ជាធរមាន ។

យោងតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ពីគោលការណ៍នីត្យានុកូលភាព គឺ មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

ឧទាហរណ៍៖ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ "ក" និង "ខ" បានរៀបចំគម្រោងក្នុងការសម្លាប់ "គ" ហើយនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ។ "គ" ត្រូវបានសម្លាប់ដោយបុគ្គល "ក" និង "ខ" តាមការរៀបចំគម្រោងបានសម្រេចប្រាកដមែន ។

មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ បានចែងថា "ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការ ពួនស្ទាក់ ។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។ ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។ ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

យើងអាចសន្និដ្ឋានបានថា ធាតុនីត្យានុកូលនៅក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន និង ការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត) ធាតុសត្យានុម័ត (អំពើសម្លាប់ទៅលើបុគ្គល "គ" តាមការគ្រោងទុក) និងធាតុអត្តនោម័ត (ចេតនាសម្លាប់) ។

### ១.១.២.១.២ ធាតុសត្យានុម័ត

ធាតុសត្យនុម័ត ឬ ហៅថាធាតុសម្ភារៈ គឺសំដៅលើអំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើស ដែលបានសម្តែងចេញមកខាងក្រៅតាមរយៈអំពើបង្កព្យសនកម្ម ដល់សង្គមជាតិ និង មានទំនាក់ទំនងហេតុ និង ផល រវាងអំពើ និង បច្ច័យ ដែលបានកើតមានឡើងដោយសារអំពើរបស់ចារី ។ អំពើដែលបង្កព្យសនកម្មដល់សង្គម គឺជាសកម្មភាព ឬ កាយវិការរបស់មនុស្ស (ចារី) ដែលបានស្តែងចេញមកខាងក្រៅដែលអាចមើលឃើញ ព្រមទាំងបង្កឲ្យអន្តរាយដល់ទំនាក់ទំនងនៃសង្គម ដែលច្បាប់បានបញ្ញត្តិទុក ។ អំពើដែលបានប្រព្រឹត្តដោយចារីដែលបានស្តែងចេញតាមរយៈកាយវិការមកខាងក្រៅនេះ ដើម្បីសម្រេចនូវគោលបំណងដែលមានគោលដៅក្នុងការសម្រេចនូវការប៉ងប្រាថ្នារបស់ខ្លួន (ចារី) ។

មាត្រា ២៧១ នៃក្រមព្រហ្មទណ្ឌ បទហិង្សាដោយចេតនា គឺជាអំពើប្រព្រឹត្តហិង្សាដោយចេតនាទៅលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

ឧទាហរណ៍៖ បុគ្គល "ក" បានប្រើអំពើហិង្សាដោយចេតនាទៅលើ "ខ" ក្នុងកម្មវិធីបុណ្យមួយនៅក្នុងភូមិកាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ។

ធាតុសត្យានុម័ត មាត្រា ២១៧ គឺការស្តែងចេញមកខាងក្រៅតាមរយៈកាយវិការ ដែលបានប្រើអំពើហិង្សាដោយចេតនា ("ក" ប្រើអំពើហិង្សាទៅលើ "ខ" ដោយចេតនា) ។

### ១.១.២.១.៣ ធាតុអត្តនោម័ត

ធាតុអត្តនោម័ត គឺជាផ្នែកខាងក្នុង ឬ ផ្នែកបញ្ញាស្មារតីនៃចារី ដែលវាផ្ទុយនឹងធាតុសត្យានុម័ត ដែលស្តែងចេញមកខាងក្រៅ ។ ធាតុអត្តនោម័តនេះ ស្តែងចេញតាមរយៈផ្លូវចិត្ត ឬ ស្មារតី ដែលយើងពុំអាចមើលឃើញនឹងភ្នែកទទេ បានឡើយ ប៉ុន្តែវា ជាដើមហេតុដែលបណ្តាលឲ្យមានការប្រព្រឹត្តនូវបទល្មើស និង នាំឲ្យមានព្យសនកម្មកើតមានឡើងក្នុងសង្គម ។ ធាតុអត្តនោម័តនេះ មានកត្តារួមផ្សំជាច្រើន គឺ កំហុសចេតនា ឬ អចេតនា គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស និង គោលដៅនៃការប្រព្រឹត្តបទល្មើសផងដែរ ។ ទោះបីជាយើងមិនអាចសន្និដ្ឋានអំពីធាតុអត្តនោម័ត បានយ៉ាងណាក្តី ក៏យើងអាចសន្និដ្ឋានបានតាមរយៈនៃធាតុសត្យានុម័តបាន ។ កំហុសរបស់ចារីដែលបានប្រព្រឹត្តកើតចេញពីចេតនា ឬ អចេតនា ប្រសិនបើធាតុនីត្យានុកូលបានបញ្ញត្តិ នោះចារីត្រូវទទួលខុសត្រូវ ព្រហ្មទណ្ឌ ។ គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស គឺសំដៅដល់ស្ថានភាពដែលជនល្មើសមានស្មារតីក្នុងការប្រព្រឹត្ត បទល្មើសដែលជាកត្តាអត្តនោម័តដែលជម្រុញផ្នែកខាងក្នុងនៃចិត្ត ។ គោលដៅនៃការប្រព្រឹត្តបទល្មើសគឺសំដៅដល់ការចង់បាន និង ការសម្រេចបំណងណាមួយ ក្នុងការប្រព្រឹត្តបទល្មើសទៅលើកម្មវត្ថុនៃបទល្មើសនោះ ។

### ១.១.២.២ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្នរបស់កម្ពុជា យកមកប្រើប្រាស់សម្រាប់ឲ្យអង្គការអយ្យការធ្វើការពិចារណា មុននឹងធ្វើចំណាត់ការនីតិវិធី ។ នៅក្នុង គោលការណ៍នេះផងដែរ បានធ្វើឲ្យ ព្រះរាជអាជ្ញា ក្លាយទៅជានិយ័តការសង្គមមួយយ៉ាងពិតប្រាកដ ដែលមានសិទ្ធិសម្រេចដោយធ្វើការថ្លឹងថ្លែងមុននឹងសម្រេចថា "ចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការ" ។

គោលការណ៍នេះ បានផ្តល់ផលវិជ្ជមានដែលជាផលអវិជ្ជមាននៃគោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់នោះ គឺ ផ្តល់ប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ដោយគ្មានការកកស្ទះសំណុំរឿង ដែលផ្តល់នូវភាពឆាប់រហ័ស និង យុត្តិធម៌ក្នុងសង្គម ។ រីឯចំណុចអវិជ្ជមាន នៃគោលការណ៍នេះ គឺ អាចមានស្ថានភាពនាំឲ្យរំលោភអំណាច ឬ បំពានច្បាប់ ដោយសារតែការតម្កល់រឿងទុកឥតចាត់ការ ឬ ការយល់ខុសក្នុង

ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ប៉ុន្តែចំណុចអវិជ្ជមាននេះ អាចដោះស្រាយបានអាស្រ័យទៅលើឆន្ទៈរបស់រដ្ឋ ។ ជាក់ស្តែងមាត្រា ៤១ កថាខណ្ឌទី ៤ និងទី ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបើកផ្លូវឲ្យអ្នកប្តឹងដែលមិនសុខចិត្តទៅនឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ធ្វើការប្តឹងតវ៉ាក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹង អំពីការតម្កល់រឿងទុកឥតចាត់ការ ទៅអគ្គព្រះរាជអាជ្ញា ដើម្បីពិនិត្យអត្ថិភាព នៃបទល្មើសថ្មីម្តងទៀត ។ **ការចោទប្រកាន់ចំពោះអនីតិជន គឺ៖**

នៅក្នុងគោលការណ៍នេះក្រោយពីការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងហើយនោះ ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់ទៅលើអនីតិជននោះបាន ។ ព្រះរាជអាជ្ញា អាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីលើកការស៊ើបសួរបន្ថែមទៅលើអនីតិជនដែលជាជនជាប់ចោទនោះ ។ បន្ទាប់ពីធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញា ត្រូវឲ្យដំណឹងពីបទចោទប្រកាន់នោះ ទៅកាន់អនីតិជនដែលជាជនជាប់ចោទ នោះភ្លាម និង ឪពុកម្តាយ ឬ អាណាព្យាបាល និង មេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយក្នុងការការពារនូវអនីតិជននោះភ្លាម ។[4]

ក្នុងករណីនេះដែលមានការបារម្ភថា អនីតិជនអាចនឹងរត់គេចខ្លួន ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការឃុំខ្លួនជាបណ្តោះអាសន្នលើអនីតិជននោះបាន (ការស្នើសុំសម្រាប់តែមធ្យោបាយចុងក្រោយបង្អស់តែប៉ុណ្ណោះ) ។ ជាមួយគ្នានេះផងដែរ ព្រះរាជអាជ្ញា ក៏ត្រូវពិចារណាដល់វិធានការផ្សេងទៀតដែលមានលក្ខណៈគាប់ប្រសើរដូចជា វិធានការបង្វែរជាដើម ដែលបម្រើឧត្តមប្រយោជន៍របស់អនីតិជននោះ ។

ស្របតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ព្រះរាជអាជ្ញា ក៏ត្រូវយកវិធានការបង្វែរនេះមកធ្វើការអនុវត្តជាមុនសិន មុននឹងសម្រេចធ្វើការស្នើសុំទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការឃុំខ្លួនទៅលើអនីតិជននោះ ។ វិធានការនេះអាចយកមកអនុវត្តបានចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទលហុ ឬ បទមជ្ឈឹម ។[5]

ដើម្បីធ្វើការកំណត់បាននូវបទល្មើស និង ធ្វើការចោទប្រកាន់ ទៅលើជនណាម្នាក់ដែលបានប្រព្រឹត្តអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត ក្នុងនីតិព្រហ្មទណ្ឌកម្ពុជា បានកំណត់ថាត្រូវមានធាតុផ្សំនៃបទល្មើសចំនួន ៣(បី) គឺ៖

- ធាតុនីត្យានុកូល
- ធាតុសត្យានុម័ត
- ធាតុអត្តនោម័ត ។[6]

[4] មាត្រា ២៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[5] មាត្រា ២៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[6] https://www.pheakdeylaw.com/kh/publication/45

## ១.២ នីតិវិធីនៃការចោទប្រកាន់

ជាទូទៅតំណាងអយ្យការត្រូវតែគោរពតាមគោលការច្បាប់ដែលមានចែង ដើម្បីធ្វើការចោទប្រកាន់ ខាងបទព្រហ្មទណ្ឌ ទើបតំណាងអយ្យការអាចធ្វើតាមនីតិវិធីចំនួន ៤ គឺៈ

- ការពិនិត្យសំណុំរឿង
- ការបើកការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់
- ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម[7] ។

### ១.២.១ ការពិនិត្យសំណុំរឿង

ជំហានដំបូងដែលនាំឲ្យមានការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌ គឺព្រះរាជអាជ្ញាដែលក្នុងនាមជាអ្នកតំណាងការពារផលប្រយោជន៍របស់សង្គម ដែលច្បាប់បានកំណត់នោះ ។ ការទទួលបានពាក្យបណ្ដឹងផ្ទាល់ ឬតាមរយៈការបញ្ជូនកំណត់ហេតុពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការត្រូវធ្វើការពិនិត្យសំណុំរឿងដែលទទួលបាននោះ រួចធ្វើការថ្លឹងថ្លែង ពីចំណាត់ការលើពាក្យបណ្ដឹង ។[8] បើតំណាងអយ្យការពិនិត្យ និង ធ្វើការថ្លឹងថ្លែងរួចយល់ឃើញថា អង្គហេតុដែលបណ្ដាលដោយជនរងគ្រោះ ឬ កំណត់ហេតុ នៅក្នុងសំណុំរឿងមានធាតុផ្សំគ្រប់គ្រាន់ដែលនាំឲ្យតំណាងអយ្យការ ធ្វើការតាមនីតិវិធីដូចជា ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និង ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

### ១.២.២ ការបើកការស៊ើបសួរ

នៅក្នុងនីតិវិធីនៃការបើកការស៊ើបសួរនេះ អាចប្រព្រឹត្តទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

- **ការបើកការស៊ើបសួរដោយផ្ទាល់របស់តំណាងអយ្យការ**
- **ការបើកការស៊ើបសួរជំនួស**

#### ១.២.២.១ ការបើកការស៊ើបសួរដោយផ្ទាល់របស់តំណាងអយ្យការ

ការបើការស៊ើបសួរដោយផ្ទាល់របស់តំណាងអយ្យការ គឺជាដំណើរការនីតិវិធីក្នុងការបើកការស៊ើបសួររបស់តំណាងអយ្យការដើម្បីធ្វើការចោទប្រកាន់ និង សុំឲ្យយុត្តាធិការស៊ើបសួរអនុវត្តច្បាប់ ពោលគឺដើម្បីឲ្យសំណុំរឿង ដល់ដៃចៅក្រមស៊ើបសួរក្នុងការអនុវត្តនីតិវិធីបន្តតាមបញ្ញត្តិនៃច្បាប់ ។

តំណាងអយ្យការ អាចធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរនៅពេលមានបទល្មើសដូចខាងក្រោម ៖

[7] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[8] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- បទឧក្រិដ្ឋ៖ ក្នុងករណីបទឧក្រិដ្ឋ តំណាងអយ្យការត្រូវតែបើកការស៊ើបសួរ ។[9] គ្មានបទឧក្រិដ្ឋណាមួយដែលត្រូវបានជំនុំជម្រះដោយពុំបានឆ្លងកាត់ ដំណាក់កាលនៃការស៊ើបសួរនោះទេ ពីព្រោះបទឧក្រិដ្ឋជាប្រភេទបទល្មើសមួយដែលមានលក្ខណៈធ្ងន់ធ្ងរ មានអប្បបរមានៃទោសដាក់ពន្ធនាគារ ចាប់ពី ៥ ទៅ ៣០ឆ្នាំ ឬ អស់មួយជីវិត ។[10] ដោយសារកម្រិតទោសនេះធ្ងន់ធ្ងរ ដូចនេះទាមទារនូវការស្រាវជ្រាវឲ្យបានហ្មត់ចត់ មុននឹងសម្រេចយកជនល្មើសទៅចំពោះមុខតុលាការធ្វើការជំនុំជម្រះ ពីព្រោះដើម្បីជៀសវៀងការជំនុំជម្រះធ្វើឲ្យឡើងដោយមានការភាន់ច្រឡំ ឬ ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិរបស់ជនដែលត្រូវគេចោទប្រកាន់ និង ដើម្បីធានាឲ្យដំណើរការរឿងក្តីប្រកបដោយយុត្តិធម៌ ។ ការស៊ើបសួរជាមុនចំពោះ បទឧក្រិដ្ឋដែលធ្វើឡើង ដោយចៅក្រមស៊ើបសួរ ក្នុងការស៊ើបសួរ ទាំងភស្តុតាងដាក់បន្ទុក និង ដោះបន្ទុកដែលចំណុចនេះ គឺដើម្បីស្វែងឲ្យដឹងការពិត និង លាតត្រដាងឲ្យកាន់តែច្បាស់មួយកម្រិតទៀតក្រៅពីការជំនុំជម្រះរបស់យុត្តាធិការ ជំនុំជម្រះ ។ ក្នុងករណីបទឧក្រឹដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ការបើកការស៊ើបសួរត្រូវបានបើកបានតាមដីការបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹទៅចៅក្រមស៊ើបសួរ ។ ការបើកការស៊ើបសួរ អាចប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានការចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញតជន (ជនដែលគេមិនស្គាល់អត្តសញ្ញាណ) ។

ដីកាបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេប នៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គល ដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។
- ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចុះការបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូចច្នេះទេដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ ។[11]

---

[9] មាត្រា ៤៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[10] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[11] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ខ្លឹមសារនៃចំណុចខាងលើនេះ មានន័យថា ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញា ដាច់ខាតត្រូវតែបើកការស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅដល់ចៅក្រមស៊ើបសួរដែលតាមរយៈដីកានេះ បានបើកសិទ្ធិដល់ចៅក្រមស៊ើបសួរមានសិទ្ធិបើកការស៊ើបសួរបាន ។

- បទមជ្ឈឹម៖ ក្នុងករណីបទមជ្ឈឹម តំណាងអយ្យការអាចជ្រើសរើសនីតិវិធីចោទប្រកាន់ តាមរយៈការបើកការស៊ើបសួរ ឬ តាមនីតិវិធីផ្សេងទៀត ។[12] បទមជ្ឈឹមនេះ ព្រះរាជអាជ្ញាអាចប្រើនីតិវិធី បញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ នីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ចំពោះប្រភេទបទមជ្ឈិមនេះ ហើយព្រះរាជអាជ្ញាក៏អាចប្រើនីតិវិធីបើកការស៊ើបសួរបានដែរ ។ បទមជ្ឈឹម ជាប្រភេទនៃបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ចាប់ពីថ្ងៃ ៦ថ្ងៃ ដល់ ៥ ឆ្នាំ[13] ដោយឡែក ការបើកការស៊ើបសួរចំពោះបទមជ្ឈិមនេះ គឺគេពុំបានចែងច្បាស់ថាជា ប្រភេទបទមជ្ឈិមស្មុគស្មាញ ឬ យ៉ាងណាទេ ក៏ប៉ុន្តែតាមស្មារតីនៃក្រម បានផ្តល់ឆន្ទានុសិទ្ធិដល់ ព្រះរាជអាជ្ញា ក្នុងការថ្លឹងថ្លែងអំពីស្ថានភាពនៃបទល្មើស ប្រសិនបើបទល្មើសដែលជនត្រូវចោទបានប្រព្រឹត្តជាបទមជ្ឈិម ប៉ុន្តែមិនមានភស្តុតាងគ្រប់គ្រាន់ ឬ ជនល្មើសជាអញ្ញាតជនពុំមានអត្តសញ្ញាណច្បាស់លាស់ ហើយសំណុំរឿងមិនទាន់មូល ពោលគឺមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការជំនុំជម្រះបាន ដូចនេះព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់តាមនីតិវិធីបើកការស៊ើបសួរ ។

ចំពោះបទមជ្ឈឹម ក៏ព្រះរាជអាជ្ញាអាចធ្វើការបើកការស៊ើបសួរបានផងដែរ ប្រសិនបើមូលហេតុមួយចំនួនត្រូវបានបំពេញដូចខាងក្រោម ៖

- អត្តសញ្ញាណរបស់ចារីត្រូវបានគេស្គាល់
- សំណុំរឿងមិនទាន់មូលសព្វគ្រប់ ដោយភស្តុតាង ដែលប្រមូលបានពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ។
- បទមជ្ឈឹមដែលត្រូវបានចោទប្រកាន់នោះ គឺមានលក្ខណៈស្មុគស្មាញពិបាកនឹងដោះស្រាយ ឬ ជនល្មើសមានគ្នាច្រើន ដែលបានប្រព្រឹត្តបទល្មើស ។

ការបើកការស៊ើបសួរត្រូវបានធ្វើឡើង ទៅតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅកាន់ចៅក្រមស៊ើបសួរ ។ ដីកានេះគឺជា នីតិវិធីដែលមានសារៈសំខាន់បំផុត ដែលផ្តល់ឲ្យចៅក្រមស៊ើបសួរ នូវសមត្ថកិច្ច ដើម្បីប្រើប្រាស់ទាំងអស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន ៖

- សេចក្តីសង្ខេប នៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស

[12] មាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[13] មាត្រា ៤៧ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និងឈ្មោះបុគ្គល ដែលត្រូវរងការស៊ើបសួរ
- កាលបរិច្ឆេទ និងមានចុះហត្ថលេខារបស់តំណាងអយ្យការ ។

ក្រោយពីបានទទួលនូវពាក្យបណ្តឹងហើយ បើព្រះរាជអាជ្ញាយល់ឃើញថា អំពើដែលគេប្តឹងមកនោះមាននូវមូលដ្ឋានគ្រប់គ្រាន់ដែលគេអាចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ ដើម្បីបើកការស៊ើបសួរទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។

ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាការបញ្ជាក់ពីការផ្តល់សមត្ថកិច្ចការងារជូនដល់ចៅក្រមស៊ើបសួរ ដែលនៅក្នុងពេលនេះចៅក្រមស៊ើបសួរមានអំណាចយ៉ាងធំធេង នៅក្នុងចំណាត់ការដោះស្រាយចំពោះរឿងក្តីព្រហ្មទណ្ឌ ដោយធ្វើការស៊ើបសួរស្វែងរកភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុកទៅលើជនល្មើស ក្នុងគោលដៅស្វែងរកឲ្យឃើញពីការពិតនៃរឿងក្តី ។

សរុបសេចក្តីមក នៅពេលដែលមានបទល្មើសមួយកើតឡើង នោះព្រះរាជអាជ្ញា ឬ តំណាងអយ្យការត្រូវតែធ្វើការបែងចែកនូវបទល្មើសនោះថាតើជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម និងត្រូវធ្វើការចោទប្រកាន់តាមរយៈការស៊ើបសួរ ។

### **១.២.២.២ ការបើកការស៊ើបសួរជំនួស**

ជាការពិតណាស់ នៅក្នុងការបើកការស៊ើបសួរនៅដំណាក់កាលនេះ គឺធ្វើឡើងដោយតំណាងអយ្យការ ក៏ប៉ុន្តែតំណាងអយ្យការ ក៏អាចធ្វើការចាត់អោយមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបសួរជំនួសបានផងដែរ ប៉ុន្តែនៅក្នុងដំណាក់នេះ កាលណាអនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ដែលច្បាប់បានបញ្ញត្តិទុក ។[14]

### **១.២.២.៣ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីនៃការចោទប្រកាន់របស់តំណាងអយ្យការ ។ ហើយការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ធ្វើឡើងដោយពុំបានឆ្លងកាត់ដំណាក់កាលនៃការស៊ើបសួរនោះទេ គឺត្រូវបញ្ជូនសំណុំរឿងទៅ ចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះផ្ទាល់តែម្តង ។ ដោយហេតុថា ការចោទប្រកាន់តាមនីតិវិធីនេះ ត្រូវបានអនុវត្តចំពោះរឿងក្តីដែលមានលក្ខណៈគ្រប់គ្រាន់ដែលអាចធ្វើការជំនុំជម្រះបាន (ពុំត្រូវការការស្រាវជ្រាវបន្ថែមឡើយ) ហើយធ្វើឡើងក្នុងគោលបំណងដើម្បីឲ្យចំណេញពេលវេលាក្នុងការអនុវត្តនីតិវិធី និងដើម្បីកាត់បន្ថយសំណុំរឿងនៅដំណាក់កាលស៊ើបសួរ ។[15]

[14] មាត្រា ៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[15] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

តំណាងអយ្យការ អាចធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ នៅពេលដែលលក្ខខណ្ឌត្រូវបានបំពេញដូចជា ៖

- ប្រភេទនៃបទល្មើស៖ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏អាចធ្វើឡើងបានចំពោះ បទមជ្ឈឹម (មាត្រា ៤៥) និងបទលហុ (មាត្រា ៤៩) ។

ថ្វីបើក្រមព្រហ្មទណ្ឌ ពុំបានធ្វើការចែងច្បាស់ថា បទល្មើសមជ្ឈិមមួយណា ដែលអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញា អនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏ដោយ ក៏ប៉ុន្តែគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងពីស្ថានការនៃបទល្មើស ។ ដោយឡែក បើព្រះរាជអាជ្ញាមើលឃើញថា បទមជ្ឈិមនេះមានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឲ្យតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យសេចក្តីលើរឿងនេះបាន ព្រះរាជអាជ្ញា នឹងប្រើនីវិធីនៃការចោទប្រកាន់នេះ ។ ផ្ទុយមកវិញបទមជ្ឈិម អាចជាកម្មវត្ថុនៃការចោទប្រកាន់ តាមទម្រង់ជាការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ព្រោះមានស្ថានភាពនៃបទមជ្ឈិមមួយចំនួនត្រូវបានទទួលឲ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀតបាន ។ ដូចជាស្ថានភាពនៃបទមជ្ឈិមដែលមានលក្ខណៈស្មុគស្មាញ ទាមទារឲ្យមានការបើកការស៊ើបអង្កេតស្វែងរកភស្តុតាងគ្រប់គ្រាន់ ឬ បទល្មើសដែលមិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម ។

ចំពោះបទលហុវិញ គឺព្រះរាជអាជ្ញា ត្រូវធ្វើការកោះជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់[16] ដោយមិនមានការបើការស៊ើបសួរ ឬ ការបង្ហាញខ្លួនភ្លាមចំពោះបទលហុនេះទេ ។ ដោយសារតែបទលហុជាបទល្មើសតូចតាច ដោយមានអតិបរិមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើ ៦ថ្ងៃ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ ឬ ត្រឹមតែជាបទល្មើសដែលត្រូវផ្តន្ទាទោសស្រាល ដូចនេះគ្មានជម្រើសផ្សេងដែលល្អជាង ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នោះទេ ពីព្រោះអាចដំណើរការរឿងក្តីបានឆាប់រហ័សផងដែរ ។

អត្តសញ្ញាណនៃជនជាប់ចោទ៖ នីតិវិធីនេះធ្វើឡើងតាមរយៈការកោះហៅជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅចំពោះមុខចៅក្រមជំនុំជម្រះ ទាមទារឲ្យមានអត្តសញ្ញាណរបស់ជនល្មើស ។ ជាក់ស្តែងក្រៅពីមានការកំណត់នូវប្រភេទនៃបទល្មើសហើយ ព្រះរាជអាជ្ញាត្រូវធ្វើការកំណត់នូវអត្តសញ្ញាណ ឬ សាវតាជាតិរបស់ជនល្មើស ។ ការកំណត់នូវសាវតាជាតិនេះគឺជាលក្ខខណ្ឌ ចាំបាច់មួយដែលត្រូវធ្វើ ដើម្បីធ្វើនូវបណ្តឹងអាជ្ញា ព្រោះថាបើពុំមាននូវសាវតាជាតិរបស់ជនល្មើសទេនោះគឺពុំអាចធ្វើការចោទប្រកាន់ និង បញ្ជូនជននោះទៅជំនុំជម្រះបាននោះទេ ។

[16] មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន៖ ពុំត្រូវការការស្រាវជ្រាវបន្ថែម ។

នៅពេលដែលទទួលបានបណ្តឹងសាមញ្ញ ឬ សំណុំរឿងដែលបញ្ជូនមកពីមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការធ្វើចំណាត់ការដូចជា៖

- ការស្រាវជ្រាវ៖ មុនសម្រេចចោទប្រកាន់តំណាងអយ្យការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យស្រាវជ្រាវបន្ថែម ។[17] ការស្រាវជ្រាវគឺអាចធ្វើឡើងតាមវិធីផ្សេងទៀតដូចជា ការស្នើសុំឲ្យមានការបើកការស៊ើបអង្កេតបឋម ការកោះហៅសួរ និងការស្តាប់ចម្លើយ បង្គាប់ឱ្យចូលខ្លួន ការឆែកឆេរ ជាដើម ។
- ការចោទប្រកាន់៖ នៅពេលមានការសម្រេចថាចោទប្រកាន់តាមការបញ្ជូនទៅជំនុំជម្រះផ្ទាល់តំណាងអយ្យការចេញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។[18]
- ការបញ្ជូនដីកា៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺត្រូវបានបញ្ជូនទៅដល់ជនជាប់ចោទ ។

### ១.២.២.៤ ការបង្គាប់អោយចូលបង្ហាញខ្លួនភ្លាម

ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទ ។ ការចោទប្រកាន់តាមរយៈនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនេះគឺ ធ្វើឡើងដោយពុំមានការឆ្លងកាត់ដំណាក់កាលស៊ើបសួរនោះទេ គឺត្រូវបញ្ជូនសំណុំរឿង និង ជនជាប់ចោទ ទៅកាន់ចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះ នៅថ្ងៃដែលជនជាប់ចោទចូលមកបង្ហាញខ្លួននៅចំពោះមុខតំណាងអយ្យការតែម្តង ។ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺត្រូវបានអនុវត្តចំពោះរឿងក្តីដែលមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន (ពុំត្រូវការការស្រាវជ្រាវបន្ថែម) ហើយធ្វើឡើងក្នុងគោលបំណងដើម្បីឲ្យចំណេញពេលវេលា និងដើម្បីកាត់បន្ថយសំណុំរឿងនៅដំណាក់កាលស៊ើបសួរ ដូចជាការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គ្រាន់តែមាននីតិវិធី និង លក្ខខណ្ឌខុសគ្នាត្រង់ចំណុច មួយចំនួន ។

ការចោទប្រកាន់តាមរយៈនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមអាចប្រព្រឹត្តទៅបាន ប្រសិនបើមានលក្ខខណ្ឌដូចជា៖

- បទល្មើសជាបទល្មើសជាក់ស្តែង តាមអន្តន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង) ។ តាមខ្លឹមសារនៃមាត្រាទាំងអស់នេះ បញ្ជាក់យ៉ាងច្បាស់ថា ក្រៅពីបទល្មើសមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានឡើយ ។

---

17 មាត្រា ៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

18 មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ ។ បទល្មើសដែលមានការដាក់ពន្ធនាគារបែបនេះ សំដៅដល់បទល្មើសមិនមែនលហុមិនមែនមជ្ឈិមដែលមានការផ្តន្ទាទោសដែលទោសអតិបរមាតិចជាង ១ឆ្នាំ និងមិនមែនបទឧក្រិដ្ឋនោះទេ គឺសំដៅដល់បទមជ្ឈិម ដែលទោសអតិបរមាយ៉ាងតិចចំនួន ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ ។
- ជនជាប់ចោទជានីតិជន ៖ នីតិជនសំដៅដល់ជនដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ ។ វិធានការបានកម្រិត ពីចំណុចជាច្រើនដែលនាំឲ្យមានការសន្និដ្ឋានថា នីតិវិធីនេះជាវិធានការដែលចង់ឲ្យមានការជំនុំជម្រះឲ្យលឿន និងចង់បានវត្តមានជនល្មើសមានជនល្មើសនៅពេលអនុវត្តទោស ដោយអនុវត្តទោស ដោយអនុញ្ញាតឲ្យចៅក្រមអាចសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ។ ដូចនេះបើយើងយកអនីតិជនមកប្រើចំពោះនីតិជន បែបនេះហាក់បីដូចជា គម្រាមដល់គោលការណ៍នៃការយកចិត្តទុកដាក់បំផុតចំពោះផលប្រយោជន៍របស់អនីតិជន ។ ការទទួលលក្ខខណ្ឌបែបនេះ គឺជាស្មារតីនៃការទទួលស្គាល់សិទ្ធិរបស់អនីតិជន ដោយធានាថាមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពារខ្លួនរបស់អនីតិជន និងជៀសវាងការបំពាននូវសិទ្ធិរបស់អនីតិជន ។
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបានទៅបាន ។[19] ចំណុចនេះ ដូចការកំណត់ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ ដោយសារបើសំណុំរឿងគ្មានបន្ទុកចោទប្រកាន់គ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួធ្វើការចោទប្រកាន់តាមទម្រង់នេះទេ ។ ក្នុងករណីនេះព្រះរាជអាជ្ញា គួរពិចារណាលើការបើកការស៊ើបសួរ ឬ ស៊ើបអង្កេតឲ្យគ្រប់សិន ។ ព្រះរាជអាជ្ញា មិនត្រូវគិតថាមានការស៊ើបអង្កេតណាមួយកើតមានក្នុងពេលជំនុំជម្រះទេ ព្រោះវាអាចជាមូលហេតុនាំឲ្យជនជាប់ចោទត្រូវបានតុលាការសម្រេចក្តីឲ្យរួចខ្លួន ហើយ ព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់ជាថ្មីចំពោះអំពើដដែល លើជនដដែលទៀតទេ ដោយសារអាជ្ញាអស់ជំនុំ ។

បន្ថែមពីនេះទៅទៀត ការបង្ហាញខ្លួនភ្លាម ក៏ត្រូវតែធ្វើទៅតាមនីតិវិធីដែលមានចែង និង បញ្ញត្តិនៅក្នុងច្បាប់ផងដែរ ដោយនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ដោយនីតិវិធីនៃការបង្ហាញខ្លួនភ្លាម នេះគឺត្រូវធ្វើឡើងដោយ ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន៖ ដើម្បីសម្គាល់ថានរណាជាជនល្មើស ហើយជននោះមានអត្តសញ្ញាណដូចអ្វី ដែលកំណត់ហេតុបានកត់ត្រា ឬ ទេ ។

[19] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- ឲ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស៖ ការទទួលយកបែបនេះ ព្រោះវាជាសិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងលឺអំពីមូលហេតុអ្វីដែល គេចោទមកខ្លួន នេះជាស្មារតីលើការទទួលស្គាល់លើសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា ។
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ៖ នេះក៏ជាសិទ្ធិសេរីភាពរបស់ជនជាប់ចោទលើការអះអាងគ្រប់បែបយ៉ាង ដើម្បីការពារខ្លួន និង លើកយកព័ត៌មាន គ្រប់យ៉ាងដែលខ្លួនបានដឹងជាផលប្រយោជន៏របស់ខ្លួន ។
- ធ្វើកំណត់ហេតុស្ដីអំពីការបងញកាប់ឲ្យចូលបង្ហាញខ្លួនភ្លាម[20] ។

ដើម្បីជាការចោទប្រកាន់ទៅតុលាការ ព្រះរាជអាជ្ញាត្រូវចេញកំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរួចបញ្ជូនទៅតុលាការជាន់ទាប(សាលាដំបូងរាជធានី-ខេត្ត) ដើម្បីចាត់តាំងចៅក្រមជំនុំជម្រះ (ដោយប្រធានតុលាការ) ក្នុងការស៊ើបសួរសវនាការ ។ ក្នុងកំណត់ហេតុនេះចាំបាច់ត្រូវតែមានការចែងនូវចំណុច ដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិ ក្នុងការពឹងពាក់មេធាវីដែលអាចជ្រើសរើសដោយខ្លួនឯង ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។ ក្នុងករណីនេះមេធាវីត្រូវទទួលដំណឹងភ្លាមដើម្បីទទួលស្គាល់នូវសិទ្ធិមានរយៈពេលគ្រប់គ្រាន់ ដើម្បីការពារខ្លួនរបស់ជនជាប់ចោទ ។

សម្គាល់៖ នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមត្រូវបានអនុវត្តចំពោះតែករណីដែលបទល្មើសជាបទល្មើសជាក់ស្ដែង ដែលជនជាប់ចោទត្រូវបានបញ្ជូនខ្លួនទៅបង្ហាញខ្លួននៅចំពោះមុខតំណាងអយ្យការ តែប៉ុណ្ណោះ (គឺមានវត្តមាននៃជនជាប់ចោទ) ។

## ផ្នែកទី២៖ បញ្ហាប្រឈមក្នុងការចោទប្រកាន់របស់តំណាងអយ្យការ

ជាទូទៅ តំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទដោយផ្អែកលើធាតុផ្សំនៃបទល្មើស ប្រសិនបើបទល្មើសមួយបានកើតឡើងដោយមានធាតុផ្សំគ្រប់គ្រាន់នោះ តំណាងអយ្យការនឹងធ្វើការចោទប្រកាន់ទៅតាមមូលច្បាប់ដែលបានបញ្ញត្តិទុក ។

ផ្ទុយទៅវិញតំណាងអយ្យការតែងជួបបញ្ហាប្រឈមមួយចំនួនដូចជា កង្វះធាតុផ្សំនៃបទល្មើស ការអន្តរាគមន៍ ពីសំណាក់អ្នកមានអំណាច និង បញ្ហានយោបាយ ។

ដោយនៅក្នុងបញ្ហាប្រឈមក្នុងការចោទប្រកាន់របស់តំណាងអយ្យការ រួមមានចំណុចដូចខាងក្រោម ៖

- **កង្វះធាតុផ្សំនៃបទល្មើស**
- **ការអន្តរាគមន៍ដោយអ្នកមានអំណាច**

[20] មាត្រា ៤៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ១.១ កត្តាធាតុផ្សំនៃបទល្មើស

### ១.១.១ ធាតុនីត្យានុកូល

ស្របតាមគោលការណ៍នីត្យានុកូលភាព គឺមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។ ត្រង់ចំណុចនេះបាននិយថា ការដែលអាចចោទប្រកាន់ថាបុគ្គលណាម្នាក់មានទោស នៅក្នុងរឿងព្រហ្មទណ្ឌបាន នោះលុះត្រាតែព្យសនៈកម្ម និង អំពើ ដែលបុគ្គលណាម្នាក់នោះ បានប្រព្រឹត្ត គឺជាបទល្មើសដែលអាចផ្តល់ផ្តន្ទាទោស និង មានទោសចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវបានប្រកាសទោសដល់ជននោះបាន ។[21]

ផ្ទុយទៅវិញប្រសិនបើអំពើដែលប្រព្រឹត្តនោះ គ្មានទោស ដែលមាន បញ្ញត្តិចែងក្នុងក្រមព្រហ្មទណ្ឌ នោះទេ ក៏ពុំអាចមានបទល្មើសកើតឡើង ដែលអាចនាំឲ្យតំណាងអយ្យការជួបប្រទះនូវបញ្ហាប្រឈមក្នុងការអនុវត្តនីតិវិធីនៃការចោទប្រកាន់បានដែរ ។

### ១.១.២ ធាតុសត្យានុម័ត

នៅក្នុងធាតុសត្យានុម័ត ឬ ហៅម្យ៉ាងទៀតថា ធាតុសម្ភារៈ សំដៅដល់អំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើសស្តែងចេញមកខាងក្រៅតាមរយៈ អំពើដែលបានបង្កគ្រោះថ្នាក់ដល់សង្គម នាំឲ្យមានបច្ច័យកើតមានឡើង ដោយមានទំនាក់ទំនងហេតុផលរវាងអំពើ និង បច្ច័យដែលកើតមានឡើងដោយសារតែអំពើនោះ ។

ផ្ទុយទៅវិញ កាលណាមានតែបច្ច័យកើតមានឡើង ប៉ុន្តែគ្មានអំពើណាមួយ ដែលបានប្រព្រឹត្តដោយជនណាម្នាក់នោះទេ នោះបច្ច័យដែលបានកើតមានឡើងពុំមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌឡើយ ។

ឧទាហរណ៍៖ ផ្ទះដែលត្រូវបានខ្យល់ព្យុះបានបក់ចំនាំឱ្យមានការខូចខាតដំបូលផ្ទះ ការកើតមានឡើងនូវបច្ច័យនេះពុំបានកើតឡើងដោយអំពើរបស់បុគ្គលណាម្នាក់ឡើង ។ ដូច្នេះការណ៍មានតែបច្ច័យកើតឡើងនេះ មិនបានបំពេញឱ្យមានទំនាក់ទំនងហេតុផល និងបច្ច័យ ជាធាតុសត្យានុម័តឡើយ។

### ១.១.៣ ធាតុអត្តនោម័ត

ធាតុអត្តនោម័ត ត្រូវបានគេសន្មតថាជាផ្នែកខាងក្នុងនៃបទល្មើស ឬ ជាផ្នែកបញ្ញាស្មារតី ដែលនាំឲ្យជនល្មើសបង្កឡើងក្នុងគោលបំណងដើម្បីបំពេញសេចក្តីសម្រេចរបស់ខ្លួន ហើយអំពើនេះបង្កឲ្យមានព្យសនកម្មកើតមានឡើងដល់សង្គម ។ កត្តារួមផ្សំនៃបទល្មើសរួមមាន៖ កំហុសដោយចេតនា ឬ អចេតនា គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស និង គោលដៅនៃការប្រព្រឹត្តបទល្មើស ។

[21] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ

ស្របតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ចេតនាប្រព្រឹត្តបទល្មើស គឺពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

មូលហេតុនៃការមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌ៖

- ជនដែលបានប្រព្រឹត្តអំពើល្មើសជាបុគ្គលវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ។[22]
- បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ។ កម្លាំង និងការបង្ខំ អាចកើតចេញមកពីក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។[23]

ធាតុសត្យានុម័តនេះ តំណាងអយ្យការត្រូវធ្វើការពិនិត្យមើលទៅលើកំហុសចេតនា ឬ អចេតនា និង មូលហេតុដែលនាំឲ្យមានការមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌជាដើម និង ដែលនាំឲ្យមានបញ្ហាប្រឈមក្នុងការចោទប្រកាន់ ។

### ១.១.៤ ការអន្តរាគមន៍របស់អ្នកមានអំណាច

តំណាងអយ្យការ គឺជាម្ចាស់នៃបណ្ដឹងអាជ្ញាដែលច្បាប់បានកំណត់ និងឲ្យសិទ្ធិអំណាចក្នុងការ ការពារផលប្រយោជន៍សាធារណៈ ។ ប៉ុន្តែដោយការអនុវត្តច្បាប់មួយចំនួន យើងឃើញមានការប្រឈមពាក់ព័ន្ធនឹងការអន្តរាគមន៍របស់អ្នកមានអំណាច នៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ដែលជាហេតុនាំឲមានការលំបាកក្នុងការអនុវត្តច្បាប់របស់មន្ត្រីអនុវត្តច្បាប់ ។

បញ្ហាប្រឈមរបស់តំណាងអយ្យការ នៅក្នុងនីតិវិធីនៃការចោទប្រកាន់ដោយមានការអន្តរាគមន៍របស់អ្នកមានអំណាចមានដូចជា៖

ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់តែតំណាងអយ្យការធ្វើការចោទប្រកាន់តាមការចង្អុលបង្ហាញរបស់អ្នកមានអំណាចមួយចំនួន ទៅដល់ជនណាម្នាក់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ។ ប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកមានអំណាច ទាំងអស់នេះទៀតសោត គឺកើតឡើងដោយការគុំគួន និង កំហឹង ឬ មានបំណងចង់ធ្វើបានជនណាម្នាក់ដែលនិយាយប៉ះពាល់ ឬ ធ្វើអ្វីមួយដែលនាំឲ្យខាតបង់ប្រយោជន៍ខ្លួន ។ ត្រង់ចំនុចនេះធ្វើឲ្យព្រះរាជអាជ្ញាមានការពិបាកក្នុងការចោទប្រកាន់ ដែលខុសពីបញ្ញត្តិនៃច្បាប់ចែង និង ជាពិសេសគឺខុសពីសតិសម្បជញ្ញៈរបស់ខ្លួនទៀតផង ។

---

[22] មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ

[23] មាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌ

ធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ តែតំណាងអយ្យការមិនធ្វើការចោទប្រកាន់ដោយហេតុថា មានការអន្តរាគមន៍ ពីសំណាក់អ្នកមានអំណាច ដែលនាំឲ្យមានការខូចប្រយោជន៍សាធារណៈ ។ ជាការពិតណាស់ជាក់ស្តែង នៅក្នុងសង្គមរស់នៅសព្វថ្ងៃ មនុស្សភាគច្រើន គឺស្រឡាញ់នូវ អំណាច បុណ្យសក្តិ និង ទ្រព្យសម្បត្តិរបស់ខ្លួន ដែលជនទាំងអស់នោះហើយ នៅពេលដែលមានការប្រព្រឹត្តនៅទោសកំហុសអ្វីមួយ ដែលខុសពីច្បាប់ និយាយរួម គឺប្រព្រឹត្តនូវបទល្មើសណាមួយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា គឺរមែងតែប្រើប្រាស់នូវអំណាច និង ទឹកប្រាក់របស់ខ្លួនមកធ្វើការសង្កត់លើឆន្ទានុសិទ្ធិ ក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។

### ១.១.៥ កត្តានយោបាយ

ក្រៅពីបញ្ហាប្រឈម ដែលកើតចេញឡើងដោយ ការអន្តរាគមន៍ពីអ្នកអំណាច នោះ ក៏មានកត្តានយោបាយ ដែលជាកត្តាចម្បងមួយទៀត និង មានការពិបាកជាង កត្តាផ្សេងៗខាងលើទៅទៀត ។ ជាការពិតណាស់ ប្រទេសកម្ពុជាទោះមានច្បាប់គ្រប់គ្រាន់ដាក់ឲ្យអនុវត្តយ៉ាងណាក៏ដោយ កត្តានយោបាយនៅតែជាកត្តាមួយយ៉ាងសំខាន់ដែលអាចធ្វើអោយមានការប្រែប្រួលនៃការអនុវត្តច្បាប់ ។

ការដែលពិបាកនៅក្នុងរឿងនយោបាយ គឺនៅពេលដែលមានចុងចម្លើយជាសកម្មជន នយោបាយ ព្រះរាជអាជ្ញា ត្រូវធ្វើការមើលពីធាតុផ្សំនៃបទល្មើស ការប្រព្រឹត្ត និង ការស៊ើបសួរទៅលើអង្គហេតុ ឲ្យបានច្បាស់លាស់ ។ ជាពិសេសទៅទៀត គឺត្រូវធ្វើការពិនិត្យទៅលើភស្តុតាងដែលប្រមូលបាន ឲ្យបានច្បាស់លាស់មុននឹងធ្វើការចោទប្រកាន់ជននោះ ។ បន្ថែមពីនេះទៅទៀត នៅក្នុងការកាន់នូវសំណុំរឿងដែលទាក់ទងទៅនឹងនយោបាយ ព្រះរាជាអាជ្ញា ត្រូវធ្វើការផ្ចិតផ្ចង់ ពិនិត្យ នូវទម្រង់ អក្ខរាវិរុទ្ធ នៃដីការនីមួយៗ ឲ្យម៉ត់ចត់ ។

ផលវិបាកចម្បងទៅលើការពិនិត្យនូវឯកសារ ផ្សេងៗខាងលើ នោះ គឺការចោទប្រកាន់ ព្រះរាជអាជ្ញាខ្លះគាត់អាចនឹងពិបាកក្នុងចោទ ដល់ជននោះ ពីបទល្មើសណាមួយ ។

# ជំពូកទី២
# ការតម្កល់រឿងទុកឥតចាត់ការ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

អង្គការអយ្យការ គឺជាស្ថាប័នមួយតំណាងឲ្យស្ថាប័ននីតិបញ្ញត្តិ ដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ហើយមានតួនាទីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។[24] អង្គការអយ្យការមានតួនាទី ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង សុំឲ្យអនុវត្តច្បាប់នៅចំពោះ យុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះ ។[25] មានន័យថា អង្គការអយ្យការមានសិទ្ធិក្នុង ការបង្ក្រាបរាល់បទល្មើសទាំងឡាយណា ដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍របស់ សង្គមជាតិ ឬសាធារណៈផងដែរ ។ អង្គការអយ្យការធានារ៉ាប់រង ការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ជាពិសេសធានា យកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អង្គការអយ្យការ មានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន ។ អង្គការអយ្យការត្រូវមានវត្តមាននៅក្នុងពេល សវនាការក្នុងរឿងក្តីព្រហ្មទណ្ឌ ។[26]

ស្ថាប័នអយ្យការ គឺស្ថាប័នឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ហើយសាលាជម្រះក្តីទៀតសោតគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ ក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងាររបស់ខ្លួនក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន និង មិនអាចស្តីបន្ទោសអ្វីដល់ ព្រះរាជអាជ្ញាឡើយ ។ ចំពោះការហាមឃាត់នេះ ទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ និង រឿងក្តីផ្សេងទៀត ។

ដើម្បីធ្វើការពន្យល់ពីការតម្កល់រឿងទុកឥតចាត់ការ របស់តំណាងអយ្យការដែលអនុវត្តតាមច្បាប់រួមមានដូចខាងក្រោមនេះ ៖ អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ ស្ថាប័នទទួលបន្ទុកនៃការតម្កល់រឿងទុកឥតចាត់ការ និងរចនាសម្ព័នរបស់អង្គការអយ្យការ ។

### ១.១ អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ

ដំណើររឿងក្តីព្រហ្មទណ្ឌនៅសាលាជម្រះក្តីជាន់ទាប ជាទូទៅត្រូវបានបែងចែកជា ៤ ដំណាក់កាលគឺ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ។

[24] មាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញ

[25] កថាខណ្ឌទី២ នៃមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[26] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដំណាក់កាលចោទប្រកាន់៖ គឺជាដំណាក់កាលមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នអយ្យការ (ជាម្ចាស់បណ្តឹងអាជ្ញា) ដែលអាចសម្រេចចោទប្រកាន់ និង បញ្ជូនសំណុំរឿងទៅយុត្តាធិការស៊ើបសួរ និង យុត្តាធិការ ជំនុំជម្រះ ដើម្បីធ្វើចំណាត់ការបន្ត ។

ក្រៅពីការចោទប្រកាន់ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា គឺបានផ្តល់អំណាចមួយទៀតដល់ព្រះរាជអាជ្ញា នោះគឺ ការតម្កល់រឿងទុកឥតចាត់ការ (ការសម្រេចមិនចោទប្រកាន់) ។ យោងមាត្រា ៤០ កថាខណ្ឌទី២ បានបញ្ញត្តិថា *"ព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ"* ។ តាមខ្លឹមសារនេះ មានន័យថា ព្រះរាជអាជ្ញា អាចសម្រេចធ្វើការចោទប្រកាន់ផង និង តម្កល់រឿងទុកឥតចាត់ការផង ចំពោះបទល្មើសព្រហ្មទណ្ឌ (អំពើដលជាបទល្មើស) ។

ដូចនេះ មានន័យថា ព្រះរាជអាជ្ញា អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះអំពើចំនួន ២ គឺ ៖ អំពើដែមមិនមែនជាបទល្មើសព្រហ្មទណ្ឌ និង អំពើដែលជាបទល្មើសព្រហ្មទណ្ឌ ។ ដោយកាផ្តល់អំណាច ក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះអំពើដែលជាបទល្មើសដល់ព្រះរាជអាជ្ញានេះ ហៅបានថា "គោលការកាលានុវត្តភាពនៃការចោទប្រកាន់" ។ តាមរយៈគោលកាណ៍នេះ គឺបានផ្តល់អំណាចឆន្ទានុសិទ្ធិដល់ ព្រះរាជអាជ្ញា ដើម្បីធ្វើការថ្លឹងថ្លែងថា គួរចោទប្រកាន់ ឬ មិនគួរចោទប្រកាន់ទៅលើអំពើដែលជាបទល្មើសព្រហ្មទណ្ឌ ។ តាមគោលការណ៍នេះផងដែរ ក៏បានលេចចេញជាចំណោទបញ្ហាមួយបានចោទឡើងថា "ហេតុអ្វី បានជាច្បាប់ផ្តល់អំណាចដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការ ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌទៅវិញ" ?

## ១.២ នីតិវិធីក្នុងការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ សំដៅទៅលើសកម្មភាពមួយនៅក្នុងដំណាក់កាល នៃការថ្លឹងថ្លែងទៅលើបណ្តឹងអាជ្ញា ដែលត្រូវសម្រេចដោយការតម្កល់រឿងទុកឥតចាត់ការ ។ ចំពោះ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ រួមមានដូចតទៅ៖ ១.២.១ ការពិនិត្យទៅលើសំណុំរឿង ១.២.២ ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ និង ១.២.៣ បណ្តឹងតវ៉ាពីដីកាតម្កល់រឿងទុកឥតចាត់ការ នឹងបកស្រាយជូនដូចខាងក្រោម ។

### ១.២.១ ការពិនិត្យសំណុំរឿង

បន្ទាប់ពីទទួលបានសំណុំរឿងព្រហ្មទណ្ឌ ត្រួតពិនិត្យរួចហើយ ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងពីចំណាត់ការលើពាក្យបណ្តឹង ដែលខ្លួនបានធ្វើដោយផ្ទាល់ ឬ តាមការបញ្ជូនកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ។[27] បើព្រះរាជអាជ្ញាយល់ឃើញថា រឿងរ៉ាវនៃអង្គហេតុ ឬ សំណុំរឿងនោះមិនទាន់គ្រប់គ្រាន់ ព្រះរាជអាជ្ញា ត្រូវបើកឲ្យមានការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យមានការស្រាវជ្រាវបន្ថែម ។[28] ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេត ឬ

[27] កថាខណ្ឌទី១ មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[28] កថាខណ្ឌទី២ មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ស្រាវជ្រាវបន្ថែមនោះ ឥតបានការទេ នាំឲ្យព្រះរាជអាជ្ញាចោទប្រកាន់ ឬ បើគ្មានជម្រើសផ្សេងនោះទេ ព្រះរាជអាជ្ញា នឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ ជាក់ជាមិនខាងឡើយ ។

### ១.២.២ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីមានបទល្មើសព្រហ្មទណ្ឌ ឬ ក្នុងករណីផ្សេងពីនេះ ដូចដែលបាន រៀបរាប់ខាងលើ គឺត្រូវធ្វើឡើងតាមរយៈ ដីការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដែលសម្រេចដោយតំណាងអយ្យការ ស្របតាមនីតិវិធីមួយត្រឹមត្រូវ និង ច្បាស់លាស់ ដើម្បីឲ្យដីកាសម្រេចនោះមានអានុភាពក្នុងការអនុវត្ត ។

### ១.២.៣ ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ

នៅពេលដែលព្រះរាជអាជ្ញា តម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងទៅអ្នកប្ដឹងអំពីសេចក្ដីសម្រេចរបស់ខ្លួន ក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូបំផុតរយៈពេល ២ ខែ គិតពីថ្ងៃចុះពាក្យបណ្ដឹងក្នុងបញ្ជី ។[29] បានសេចក្ដីថា ក្រោយពីពាក្យបណ្ដឹងត្រូវបានចុះក្នុងបញ្ជី សំណុំរឿងអយ្យការ ស្ដីពីការសម្រេចតម្កល់រឿងទុកឥតចាត់ការ រួចហើយនោះ ព្រះរាជអាជ្ញា ត្រូវឲ្យដំណឹងអំពី ការសម្រេចតម្កល់រឿងទុកឥតចាត់ការ តាមរយៈលិខិតជូនដំណឹង របស់តំណាងអយ្យការ ទៅអ្នកប្ដឹងមិនឲ្យលើសពី ២ ខែ គិតពីថ្ងៃចុះពាក្យបណ្ដឹងក្នុងបញ្ជីរួចមក ។ ចំពោះដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងហេតុ និង សំអាងច្បាប់ ។[30]ម្យ៉ាងទៀតគឺងាយស្រួលក្នុងការដែលដើមបណ្ដឹងមិនសុខចិត្តចំពោះសេចក្ដីសម្រេចនោះ លើកយកហេតុផលសម្រាប់ប្ដឹងតវ៉ា ។

### ១.២.៤ បណ្ដឹងតវ៉ាអំពីដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ

ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ អាចប្ដឹងតវ៉ាបាន បើអ្នកប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ការប្ដឹងតវ៉ានេះដែរត្រូវធ្វើឡើងក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចនោះ ។ ការប្ដឹងតវ៉ា ត្រូវធ្វើឡើងតាមរយៈពាក្យបណ្ដឹងសាមញ្ញ ដាក់មកតំណាងអយ្យការ បន្ទាប់មកព្រះរាជអាជ្ញា ត្រូវបញ្ជូនសំណុំរឿងនេះភ្លាម ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីធ្វើអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឲ្យធ្វើការចោទប្រកាន់ ។ បើផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នឹងតម្កល់សេចក្ដីសម្រេច របស់ព្រះរាជអាជ្ញាអមសាលាដំបូង ទុកជាបានការ ដដែល ។ ដោយអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ នឹងឲ្យដំណឹងអំពីសេចក្ដីសម្រេចនោះ ទៅអ្នកប្ដឹងតវ៉ា ។

[29] កថាខណ្ឌទី១ មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[30] កថាខណ្ឌទី២ មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ផ្នែកទី២៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

### ១.១ កង្វះធាតុផ្សំនៃបទល្មើស

ក្នុងការកំណត់អំពើណាមួយថាជាបទល្មើស ឬ មិនមែនជាបទល្មើសព្រហ្មទណ្ឌបាន គឺយើងត្រូវធ្វើការសិក្សាទៅលើធាតុផ្សំនៃបទល្មើស ដែលជារូបមន្តក្នុងការកំណត់អំពីបទល្មើសព្រហ្មទណ្ឌ ។ តើអំពើនោះ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ហើយឬនៅ ? តាមគោលការណ៍ អំពើមួយត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌបានលុះត្រាតែ អំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ។ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌនេះផងដែរមាន ៣ គឺ ធាតុ នីត្យានុកូល[31], ធាតុសត្យានុម័ត និងធាតុអត្តនោម័ត[32] ដែលមានការបកស្រាយជូនដូចខាងក្រោមនេះ ៖

ធាតុធាតុនីត្យានុកូល៖ គឺជាធាតុច្បាប់ ។ ជាគោលការណ៍ដើម្បីកំណត់អំពើណាមួយជាបទល្មើស បានលុះត្រាតែអំពើនោះមានច្បាប់ចែង គឺមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែង នៅក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានតែប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសបាន ។

ធាតុសត្យានុម័ត ឬធាតុសម្ភារៈ៖ គឺជាអង្គហេតុ ឬ ជាគោលការណ៍ទាំងឡាយណាដែលបង្កឲ្យមាន នូវព្យសនកម្ម ឬ កាខូចខាតដែលស្តែងចេញតាមរយៈអំពើរបស់ជនល្មើស ឬ ចារីនៃបទល្មើស ។ អង្គហេតុ ឬ ហេតុការណ៍ទាំងឡាយអាចជា៖ អំពើវិជ្ជមាន និង អំពើអវិជ្ជមាន ។

ធាតុអត្តនោម័ត៖ គឺជាផ្នែកខាងក្នុងនៃបទល្មើស ឬជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើ បង្កគ្រោះថ្នាក់ដល់សង្គមដែលជននោះបានប្រព្រឹត្ត និង ចំពោះបច្ច័យដែលកើតមានឡើងចំពោះអំពីអំពើនោះ ។ ជាទូទៅពិបាកសម្គាល់ តែយើងអាចដឹងតាមរយៈសកម្មភាពឃោឃៅកើតចេញពីចិត្ត ឬ ចេតនាខាងក្នុងរបស់ជននោះ ។

ដូចនេះ ប្រសិនបើកង្វះនូវធាតុផ្សំណាមួយ តំណាងអយ្យការនឹងសម្រេចតម្កល់រឿងនោះទុកឥតចាត់ការ ។

### ១.២ ការរលត់បណ្តឹងអាជ្ញា

ការរតល់បណ្តឹងអាជ្ញា ឬ ជាទូទៅត្រូវបានគេហៅថា "បណ្តឹងព្រហ្មទណ្ឌ" មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពីពិរុទ្ធភាពនៃបទល្មើស និង ផ្តន្ទាទោសជនដែលបានប្រព្រឹត្តបទល្មើសតាមកំណត់ច្បាប់ ។ បណ្តឹងអាជ្ញា ត្រូវអនុវត្តលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល និង ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការ នយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។[33] មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[34] ដូច្នេះ ការធ្វើបណ្តឹងអាជ្ញា គឺជាសិទ្ធិផ្តាច់មុខរបស់ស្ថាប័នអយ្យការ ហើយបណ្តឹងអាជ្ញានឹងត្រូវបានចាប់ផ្តើម ដំណើការ

---

[31] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ

[32] មាត្រា៤ នៃក្រមព្រហ្មទណ្ឌ

[33] https://www.facebook.com/329066187511534/posts/902049593546521/?d=n

[34] មាត្រា១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ដោយចោទប្រកាន់ពីបទល្មើសណាមួយដោយអយ្យការ និង សុំឲ្យនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និង យុត្តាធិការ ជំនុំជម្រះ ។ ថ្វីត្បិតតែ បណ្តឹងអាជ្ញាត្រូវធ្វើឡើងដោយស្ថាប័នអយ្យការ ដើម្បីធានា នូវសណ្តាប់ធ្នាប់សាធារណៈ និង ប្រយោជន៍ទូទៅរបស់សង្គម ប៉ុន្តែបុគ្គលដែលទទួលរងគ្រោះដោយផ្ទាល់ ឬ ភាគី ដែលពាក់ព័ន្ធនឹងហេតុការណ៍ដែលត្រូវបានកំណត់ក្នុងបណ្តឹងអាជ្ញានោះ មានសិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណី ដែលត្រូវបានកំណត់ថា ជាប្រភេទបណ្តឹងរដ្ឋប្បវេណីក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលបណ្តឹងរដ្ឋប្បវេណីនេះ មានគោលបំណងឲ្យភាគីរងគ្រោះបានទទួលសំណងជម្ងឺចិត្ត សមល្មមនឹងព្យសនកម្មដែលខ្លួនទទួលរង ។ បណ្តឹងអាជ្ញា នឹងត្រូវបានរលត់ដោយសាកត្តាដូចខាងក្រោម៖ មរណៈភាពនៃជនល្មើស ផុតអាជ្ញាយុកាលនៃបទល្មើស កានិរាកណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ កាលើកលែងទោសជាទូទៅ ការសម្រុះសម្រួល និង ការដកពាក្យបណ្តឹង ។

### ១.២.១ មរណៈភាពនៃជនល្មើស

មរណៈភាពនៃជនល្មើស គឺផ្តោតទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើស ឬ សង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ក្នុងករណីខ្លះទៀត អាចជាប់ចោទដែលស្ថិតនៅក្នុងនីតិវិធីរបស់តុលាការ ។ បើកាលណាជនល្មើសបានទទួលមរណៈភាព ជាមូលហេតុនាំឲ្យបណ្តឹងអាជ្ញាត្រូវរលត់[35] ផងដែរ ។ ចំពោះមរណៈភាពរបស់ជនល្មើសនេះផងដែរ មិនប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារឲ្យមានការទទួលខុសត្រូវនូវព្យសនកម្មនោះទេ ដូចនេះជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី អាចសូមឲ្យមានការជួសជុលព្យសនកម្មពី សិទ្ធិវ័ន្តនៃជនជាប់ចោទបាន ។[36] យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើដែលខ្លួនបានប្រព្រឹត្តប៉ុណ្ណោះ ។[37] ដូច្នេះ ប្រសិនបើជនល្មើស បានទទួលមរណៈភាព នោះតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ទៅលើជនល្មើសនោះបានឡើយ ហើយនៅក្នុងករណីនេះ តំណាងអយ្យការចាំបាច់ត្រូវតម្កល់រឿងទុកឥតចាត់ការ ។

### ១.២.២ ផុតអាជ្ញាយុកាលនៃបទល្មើស

ការផុតអាជ្ញាយុកាលនៃបទល្មើស ជាមូលហេតុនាំឲ្យតំណាងអយ្យការសម្រេចមិនចោទប្រកាន់ ក្នុងករណីនេះ តំណាងអយ្យការនឹងចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ អាជ្ញាយុកាលនៃបទល្មើស ឬ អាជ្ញាយុកាល នៃបណ្តឹងអាជ្ញា គឺជារយៈដែលកំណត់ក្នុងច្បាប់យ៉ាងជាក់លាក់ បើផុតរយៈពេលនេះ ព្រះរាជអាជ្ញាមិនអាចធ្វើការ ចោទប្រកាន់លើជនប្រព្រឹត្តបទល្មើស ដើម្បីឲ្យមកទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ។

---

[35] កថាខណ្ឌទី២ មាត្រា៧ នៃក្រមនៅតិវិធីព្រហ្មទណ្ឌ។

[36] វាក្យខណ្ឌទី១ កថាខណ្ឌទី១ មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ ។

[37] មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ ។

ចំពោះអាជ្ញាយុកាលនៃបទល្មើស គឺមានលក្ខណៈប្រែប្រួលទៅតាមប្រភេទបទល្មើស ។ ថេរវេលានៃអាជ្ញាយុកាលនៃបទល្មើសរួមមាន ដូចខាងក្រោម៖

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម និង

-១ (មួយ) ឆ្នាំ ចំពោះបទលហុ[38] ។

លើកលែងតែមាត្រា៩ (បទឧក្រិដ្ឋដែលគ្មានអាជ្ញាយុកាលកំណត់) ។

### ១.២.៣ ភាពនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺសំដៅដល់គោលការណ៍នៃការលប់ចោល ឬ ការច្រានចោលនូវបទបញ្ញត្តិរបស់ក្រមព្រហ្មទណ្ឌ ដោយមូលហេតុច្បាប់ព្រហ្មទណ្ឌថ្មី មិនមានចែង ឬ លុបចោលបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាស់ ។ ម្យ៉ាងវិញទៀត ច្បាប់ព្រហ្មទណ្ឌថ្មីត្រូវយកមកអនុវត្ត និង វិធាននៃការនិរាករណ៍ចំពោះបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌមុន ផងដែរ ។ ការអនុវត្តច្បាប់លុបចោលបទល្មើស គឺសម្តៅលើបទបញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។[39] ក្នុងករណីដែលអំពើបានប្រព្រឹត្តនៅមុន បទបញ្ញត្តិនោះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ឡើយ ។ ដោយឡែកការចោទប្រកាន់ ដែលកំពុងប្រព្រឹត្តទៅនោះ គឺត្រូវបញ្ចប់ ប្រសិនបើការផ្តន្ទាទោសស្ថាពរត្រូវបានប្រកាសរួចហើយ ទោសដែលចែងអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬ ត្រូវតែឈប់អនុវត្ត ។[40] ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺពិតជាលក្ខខណ្ឌ ដែលមានអានុភាពចាប់បង្ខំឲ្យតំណាងអយ្យការ មិនអាចធ្វើការចោទប្រកាន់បានដោយស្វ័យប្រវត្តបានទេ គឺតំណាងអយ្យការចេញដីកាតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើស ដែលត្រូវបាននិរាករណ៍ដោយច្បាប់ព្រហ្មទណ្ឌ ។

### ១.២.៤ អាជ្ញាអស់ជំនុំ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការបានសម្រេចសេក្តីអំពីការដាក់ទោសជនជាប់ចោទ គឺមានន័យថាជនជាប់ចោទមានកំហុស ឬ បានប្រព្រឹត្តបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ជាស្ថាពរ ។ យោងតាមគោលការណ៍មិនអាចជំនុំជម្រះពីរដង លើរឿងក្តីតែមួយ នាំឲ្យមានផលវិបាកមិនអាចធ្វើបណ្តឹងអាជ្ញា ទៀតនោះទេ ។ ប្រសិនបើមាន សាលក្រម តុលាការដោះលែងជនជាប់ចោទ ចំពោះអំពើដដែលនោះ ទៅបីជាក្រោយពេលមានសាលក្រមរួចហើយក៏ដោយ ក្នុងករណីរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ ។

[38] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[39] វាក្យខណ្ឌទី១ កថាខណ្ឌទី១ មាត្រា៩ នៃក្រមព្រហ្មទណ្ឌ

[40] កថាខណ្ឌទី២ មាត្រា៩ នៃក្រមព្រហ្មទណ្ឌ

អនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនដែលតុលាការបានសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននេះ មិនអាចត្រូវចោទប្រកាន់នូវអំពើដដែល ទោះស្ថិតក្រោមការកំណត់បតល្មើសថ្មីផ្សេងទៀតក៏ដោយ ។[41]

### ១.២.៥ ការលើកលែងទោសជាទូទៅ

រដ្ឋសភាអនុម័តច្បាប់លើកលែងទោសជាទូទៅ[42] មានន័យថា កាលើកលែងទោសជាទូទៅត្រូវតែ ជាច្បាប់ត្រូវអនុម័តដោយរដ្ឋសភា ហើយជាគោលការណ៍ ច្បាប់មួយកើតឡើងតាមរយៈសេចក្តីព្រាងច្បាប់ ។ នៅពេល មានសំណើរច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ត្រូវបានដាក់ស្នើទៅរដ្ឋសភាដើម្បីអនុម័តហើយ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅមានអនុភាពពីចំណាត់ការរបស់តំណាងអយ្យការ តាមស្មារតីនៃច្បាប់ក្នុងករណីមានជនដែលប្រព្រឹត្តបទល្មើសណាមួយរួចហើយ ប៉ុន្តែដោយហេតុថា បទល្មើសនោះ លែងកើតមានផលប៉ះពាល់ដល់សង្គមទៀតហើយ គេនឹងស្នើសុំឲ្យរដ្ឋសភាអនុម័ត ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ចំពោះបទល្មើសទាំងនោះ ។

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ គឺមានលក្ខណៈពាក់ព័ន្ធទាំងទណ្ឌកម្មព្រហ្មទណ្ឌ និង ទណ្ឌកម្មរដ្ឋបាល ហើយកំណត់ច្បាស់ដោយខ្លួនឯង ពីកាលបរិច្ឆេទដែលក្នុងនោះ ចំពោះការប្រព្រឹត្តបទល្មើសត្រូវលើកលែង ឬ ពីទោសប្រកាសត្រូវលើកលែង (ឧទាហរណ៍៖ ទណ្ឌិតដែលត្រូវផ្តន្ទាទោសពី ៦ខែដល់ ៥ឆ្នាំ ត្រូវលើកលែងទោស) ឬ ពីគុណសម្បត្តិរបស់ចារី នៃបទល្មើសដែលត្រូវលើកលែងទោស (ឧទាហរណ៍៖ ចារីមានអាយុក្រោម ២៥ឆ្នាំ ត្រូវលើកលែង) ។ លក្ខខណ្ឌខាងលើដែលច្បាប់ស្តីពីការលើកលែងទោសជាទូទៅ មានអានុភាពលុបបំបាត់នូវទណ្ឌកម្មទាំងអស់នោះហើយ តើការចោទប្រកាន់របស់តំណាងអយ្យការមានប្រយោជន៍អ្វី? ករណីនេះ តំណាងអយ្យការនឹងធ្វើកាសម្រេចមិនចោទប្រកាន់តាមរយៈ ការចេញដីកាតម្កល់រឿងទុកឥតចាត់ការ ដោយមូលហេតុមកពី អានុភាពនៃច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

### ១.២.៦ ការសម្រុមសម្រួល

ការសម្របសម្រួលមិនអាចធ្វើទៅបានឡើយ ចំពោះបទល្មើសព្រហ្មទណ្ឌ ។ ដោយឡែក មានច្បាប់ពិសេស គឺច្បាប់ដោយឡែក អនុញ្ញាតឲ្យមានការសម្រមសម្រួល ឬ ផ្សះផ្សារគ្នាបាន ។ (ឧទាហរណ៍៖ មាត្រា ២៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៤ ចែងថា *"ចំពោះបទល្មើសដែលជាអំពើប៉ះពាល់ខាងផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច និង បទល្មើសមជ្ឈឹមស្រាល ឬ បទលហុ ការផ្សះផ្សារ ឬ សម្រុះសម្រួលអាចធ្វើទៅបានតាមកាយល់ព្រមពីភាគីទាំងសងខាង"* ។

[41] មាត្រា១០ នៃក្រមព្រហ្មទណ្ឌ

[42] កថាខណ្ឌទី៤ មាត្រា៩០ នៃរដ្ឋធម្មនុញ្ញ

ក្នុងករណីនេះ ការសម្រុះសម្រួលនាំឲ្យមានការលត់បណ្តឹងអាជ្ញា នាំឲ្យតំណាងអយ្យការមិនអាចចោទប្រកាន់ទៅលើជនដែលបានកប្រព្រឹត្តនោះឡើយ ម្យ៉ាងតំណាងអយ្យការមានជម្រើសតែមួយគឺ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

### ១.២.៧ ការដកពាក្យបណ្តឹង

ការដកពាក្យបណ្តឹងដែលធ្វើឡើងដោយជនរងគ្រោះ មិនអាចធ្វើឲ្យអាជ្ញាយុកាលនៃបណ្តឹងអាជ្ញារលត់នោះទេ ។ ក៏ប៉ុន្តែ មានបទល្មើសព្រហ្មទណ្ឌមួយចំនួន ប្រសិនមានការដកពាក្យបណ្តឹងពីជនរងគ្រោះ នោះ បណ្តឹងអាជ្ញាត្រូវរលត់ផងដែរ បើពាក្យបណ្តឹងជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ។[43] ដោយយោងតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ចំពោះការចោទ ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបាននោះទេ បើមានការដកពាក្យបណ្តឹងពីជនរងគ្រោះផ្ទាល់ ។[44] តែបើ អំពើហិង្សាក្នុងគ្រួសារនោះ បានកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែចោទប្រកាន់ជននោះ តាមនីតិវិធីព្រហ្មទណ្ឌ បើទោះបីជាមានការដកពាក្យបណ្តឹងពីជនរងគ្រោះក៏ដោយ ។[45]

ដូច្នេះបើមានការដកពាក្យបណ្តឹងពីជនរងគ្រោះ ហើយប្រសិនបើការដកពាក្យបណ្តឹងនោះ ជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ដែលមានចែងយ៉ាងជាក់លាក់ពីច្បាប់ដែលជាមូលហេតុនាំឲ្យមានការរលត់បណ្តឹងអាជ្ញា ។ ព្រះរាជអាជ្ញា ពុំអាចធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌនោះទេ គឺព្រះរាជអាជ្ញា ធ្វើការតម្កល់រឿងនោះទុកឥតចាត់ការ ។

### ១.២.៨ ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស

គោលការលានុវត្តភាពនៃការចោទប្រកាន់ បានអនុញ្ញាតដល់តំណាងអយ្យការ ក្នុងការប្រើឆន្ទានុសិទ្ធិដើម្បីសម្រេចថា គួរចោទប្រកាន់ ឬ មិនចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌ ។

គោលគំនិតនៃការបង្កើតនូវគោលការណ៍នេះ គឺដោយយល់ឃើញថា ចំពោះអំពើមួយចំនួនថ្វីត្បិតតែច្បាប់បានកំណត់ថាជាបទល្មើសក៏ពិតមែន ប៉ុន្តែកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ហេតុ និងប ច្ច័យ ដែលទាក់ទងនឹងបទល្មើសខ្លះ មិនបានបង្កព្យសនកម្មធ្ងន់ធ្ងរ និង ភាពរឹករវដល់សង្គមនោះទេ ហេតុនេះប្រសិន បើធ្វើការចោទប្រកាន់ហាក់មិនបានផ្តល់ផលប្រយោជន៍អ្វី ហើយដូចជាបន្ថែមបន្ទុកទៅលើសង្គមទៅវិញ ។

ឧទាហរណ៍៖ ស្ត្រីមេម៉ាយក្រីក្រម្នាក់ មានកូនតូចៗក្នុងបន្ទុក៥នាក់ ដោយសារតែឃ្លានពេក ក៏បានសម្រេចចិត្តលួចបាយប្រអប់មួយប្រអប់ដែលគេលក់នៅតាមចញ្ចើមផ្លូវ ។ តាងអង្គហេតុនេះ ស្ត្រីម្នាក់នេះបាន

[43] មាត្រា៨ នៃក្រមព្រហ្មទណ្ឌ

[44] មាត្រា៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

[45] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៦, ទំព័រ៧

ប្រព្រឹត្តបទល្មើសលួច ប៉ុន្តែបើយើងពិនិត្យទៅលើ ហេតុ និង បច្ច័យ ដែលទាក់ទងនឹងការប្រព្រឹត្តបទល្មើសវិញ គឺដោយសារតែឃ្លានពេក (ដើម្បីជីវិតរស់នៅបានចិញ្ចឹមកូន) ហើយព្យសនកម្មក៏មានលក្ខណៈតិចតួចមែនទែន ។

ប្រសិនបើសម្រេចចោទប្រកាន់ វានឹងផ្តល់ផលប៉ះពាល់ដល់សង្គមជាច្រើនដូចជា៖ កូនៗត្រូវក្លាយជាកុមារកំព្រា ពុំមានអ្នកទំនុកបំរុង បង្កើនការកកស្ទះសំណុំរឿងនៅតាមតុលាការ ប៉ះពាល់ដល់សេដ្ឋកិច្ចជាតិដោយសារការចំណាយលើទណ្ឌិតនៅពន្ធនាគារ ។

ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការ គឺជារឿងដែលសមហេតុផលបំផុត ។ ក្រៅពីការបកស្រាយនៅក្នុងអង្គហេតុខាងលើ នៅមានមូលហេតុផ្សេងទៀតជាច្រើនដែលនាំឲ្យមានការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌ ។

### ១.៣ កត្តាផ្សេងៗដែលនាំឲ្យមានការតម្កល់រឿងទុកឥតចាត់ការ

ចំពោះការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺមានន័យថាជាការរួចផុតការទទួលខុសត្រូវពីបទល្មើសព្រហ្មទណ្ឌ របស់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសនោះ ។ ជាគោលការណ៍ ជនដែលបានប្រព្រឹត្តបទល្មើស ពិតណាស់ត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ តែដោយសារផ្អែកទៅលើមូលហេតុនៃការប្រព្រឹត្ត កាលៈទេសៈនៃការប្រព្រឹត្ត ឬបុគ្គលិកលក្ខណៈជនល្មើស ហើយច្បាប់ចែងឲ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះរួចផុត ពីការទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថា ជនល្មើសមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ។ ពុំមានបទល្មើសទេ ប្រសិនបើបើគ្មានចេតនាប្រព្រឹត្ត ។[46]

ដោយឡែកមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌរួមមាន៖ ជនល្មើសជាជនវិបល្លាសស្មារតី ការការពារស្របច្បាប់ ស្ថានភាពចាំបាច់ ការអនុញ្ញាតដោយច្បាប់ អានុភាពនៃកម្លាំងបង្ខំ និង ជនល្មើសជាអនីតិជន ។

#### ១.៣.១ ជនល្មើសជាជនវិបល្លាសស្មារតី

បើកាលណាជនល្មើស ជាជនមានវិបល្លាសស្មារតី ដែលនាំឲ្យជននោះខូចប្រព័ន្ធប្រសាទ មិនអាចយល់ដឹង ចុះខ្សោយការគិតខ្លាំង ឬ គ្មានការវិនិច្ឆ័យពីអំពើរបស់ខ្លួនទេ បន្ទាប់មកជននោះ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក្នុងករណីនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។[47] ម្យ៉ាងវិញទៀតជនល្មើសមាន វិបល្លាសស្មារតីដោយប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬ សារជាតិដែលច្បាប់បានហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។[48]

[46] កថាខណ្ឌទី១ មាត្រា៤ នៃក្រមព្រហ្មទណ្ឌ

[47] កថាខណ្ឌទី៣ មាត្រា៣១ នៃក្រមព្រហ្មទណ្ឌ

[48] កថាខណ្ឌទី៣ មាត្រា៣១ នៃក្រមព្រហ្មទណ្ឌ

### ១.៣.២ ការការពារស្របច្បាប់

ក្នុងករណីមានជនដែលបានប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ ពិតណាស់ជននេះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ។ ការការពារស្របច្បាប់ ត្រូវតែបំពេញនូវលក្ខខណ្ឌដូចខាងក្រោមៈ

-ដោយចាំបាច់ក្នុងការការពារខ្លួន ការពារអ្នកដ៏ទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានដែលមិនត្រឹមត្រូវ

-បទល្មើស និង ការឈ្លានពានត្រូវកើតមានឡើងក្នុងពេលជាមួយគ្នា ។

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និង ទម្ងន់នៃការឈ្លានពាន ។[49]

### ១.៣.៣ ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតក្នុងស្ថានភាពចាំបាច់ ហើយបានប្រព្រឹត្តបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

-ដើម្បីការពារខ្លួន ការពារអ្នកដ៏ទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងបទល្មើសដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន ។

-មានវិសមាមាត្ររវាងមធ្យោបាយការពារ និង ទម្ងន់នៃគ្រោះថ្នាក់ ។[50]

### ១.៣.៤ ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ

ជនណាដែលបានប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះ គឺមិនប្រព្រឹត្តបទល្មើសទេ ហើយជនណាដែលប្រព្រឹត្តតាមការបញ្ជារបស់អាជ្ញាធរស្របច្បាប់ ជននោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់ ។[51]

### ១.៣.៥ អានុភាពនៃកម្លាំង ឬ ការបង្ខំ

ជនណាដែលបានប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលជននោះមិនអាចទប់ទល់បាន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ការបង្ខាំង ឬ ការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈ របស់ជននោះតែប៉ុណ្ណោះ ។ ចំពោះ កម្លាំង ឬ ការបង្ខំនេះត្រឹមតែមិនអាចមើលឃើញជាមុនបាន និង មិនអាចជៀសវៀងបាន ។[52]

---

[49] មាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ

[50] មាត្រា៣៥ នៃក្រមព្រហ្មទណ្ឌ

[51] មាត្រា៣២ នៃក្រមព្រហ្មទណ្ឌ

[52] មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ

### ១.៣.៦ ជនល្មើសជានីតិជនអាយុក្រោម១៤ឆ្នាំ

បុគ្គលគ្រប់រូប ទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។[53] នីតិភាពទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ៨ឆ្នាំ ឡើងទៅ ។[54] ក៏ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្ម ត្រូវបានកំណត់អាយុចាប់ពី ១៤ឆ្នាំឡើងទៅ ។[55] ដូច្នេះ បើអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ អនីតិជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហើយក៏មិនអាចចាប់បង្ខំឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ដែរ ។ ប៉ុន្តែ ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភ ជាដើម ។[56]

### ១.៤ អភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិគឺ ជាសិទ្ធិពិសេសរបស់បុគ្គលម្នាក់ដែលលច្បាប់បញ្ញត្តិអំពីលក្ខខណ្ឌពិសេសទាក់ទងទៅនឹងកិច្ចនីតិវិធីការទទួលខុសត្រូវ ឬ ទទួលបានស្ថានសម្រាល ចំពោះការប្រព្រឹត្តបទល្មើសណាមួយនៅក្នុងច្បាប់ជាធរមាន ។ តាមគោលការណ៍ នៃការអនុវត្តអភ័យឯកសិទ្ធិនេះ គឺត្រូវបានបញ្ញត្តិចំពោះបុគ្គលមួយចំនួនដែលត្រូវបានកំណត់ទុកជាមុនក្នុងច្បាប់ ។ ក្នុងនោះមានព្រះមហាក្សត្រ តំណាងរាស្ត្រ តំណាងទូត ព្រមទាំងអភ័យឯកសិទ្ធិគ្រួសារចំពោះអំពើលួច ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តភាពជាតិ ។[57] ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ អង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបានឡើយ ។[58] រីឯតំណាងរាស្ត្រដែលជាសមាជិកសភាវិញ ក៏មានអភ័យឯកសិទ្ធិផងដែរ ។ តំណាងរាស្ត្ររូបណាក៏ដោយ ក៏មិនអាចត្រូវចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុធ្វើការសម្តែង យោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ កាឃុំខ្លួនសមាជិកណាមួយ នៃរដ្ឋសភានឹងអាចធ្វើទៅកើតបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ គណៈកម្មាធិការអចិន្ត្រៃយ៍របស់ រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំរដ្ឋសភា វៀរលែងតែក្នុងករណី បទល្មើសជាក់ ស្តែង ។[59]

### ១.៥ អនិយតភាពនៃនីតិវិធី

អនិយតភាពនីតិវិធី ក៏ជាមូលហេតុដែលតំណាងអយ្យការលើកយកមកសំអាងមិនធ្វើការចោទប្រកាន់តាមរយៈដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ផងដែរ ។ ចំពោះអនិយត្តភាពនីតិវិធីមានន័យថា គឺជាភាពមិន

---

[53] មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ

[54] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ

[55] កថាខណ្ឌទី២ មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ

[56] កថាខណ្ឌទី១ មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ

[57] កថាខណ្ឌទី១ មាត្រា៨ នៃរដ្ឋធម្មនុញ្ញ

[58] មាត្រា៧ នៃរដ្ឋធម្មនុញ្ញ

[59] មាត្រា៨០ នៃរដ្ឋធម្មនុញ្ញ

ស្របច្បាប់ នៃនីតិវិធីក្នុងដំណើរប្រត្តិបត្តិការរបស់តំណាងអយ្យការ ឬ មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ស្រាវជ្រាវរកព័ត៌មាន មុននឹងធ្វើការចោទប្រកាន់ ឬ មិនចោទប្រកាន់ ។ ក្នុងករណី បើតំណាងអយ្យការ ប្រើប្រាស់រយៈពេលមួយសមស្របនៅក្នុងការស៊ើបអង្កេត ឬ ស្រាវជ្រាវបន្ថែមរបស់នគរបាលយុត្តិធម៌នោះហើយ ប្រត្តិបត្តិការនេះមិនសមស្របនីតិវិធីច្បាប់ និង មិនបានលទ្ធផល ឬ គ្មានប្រយោជន៍ទេ ច្បាស់ណាស់គឺ តំណាងអយ្យការអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ។

## ផ្នែកទី៣៖ បញ្ហាប្រឈមក្នុងការតម្កល់រឿងទុកឥតចាត់ការ

បើពិចារណាឲ្យបានស៊ីជម្រៅ ជារឿយៗការតម្កល់រឿងទុកឥតចាត់ការ ជាហេតុនាំឲ្យសង្គមសម្បូរទៅដោយបទល្មើសកាន់តែច្រើន ដោយសារតែជនល្មើសយល់ថាខ្លួននឹងមិនត្រូវបានចោទប្រកាន់ចំពោះទង្វើរបស់ខ្លួនទេ នោះបុគ្គលម្នាក់ៗនឹងមិនខ្លាចការផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌឡើយ ។ ការកំណត់ទណ្ឌកម្ម តាមរយៈស្មារតីនៃមាត្រានីមួយៗ គឺដើម្បីបង្ការ ឬ បំភ័យមនុស្សថាកាលណាជននោះហ៊ានប្រព្រឹត្តនូវបទល្មើស ជននោះនឹងទទួលទណ្ឌកម្មដោយការចោទប្រកាន់របស់ព្រះរាជអាជ្ញាទៅតុលាការ ។ មិនត្រឹមតែប៉ុណ្ណោះ វាអាចជាចំណុចចន្លោះប្រហោងនៃច្បាប់ដែលទុកឱកាសឲ្យមន្ត្រីអនុវត្តទាញយកផលប្រយោជន៍ណាមួយដែលគាត់ទទួលបានពីការតម្កល់រឿងទុកឥតចាត់ការទៅវិញ ។ ជារួម ការតម្កល់រឿងទុកឥតចាត់ការ ជះឥទ្ធិពលដល់ ការរីកចំរើនរបស់សង្គម តែក៏ជាចំណុចអនថយក្នុងការការពារសណ្តាបធ្នាប់សាធារណៈដែរ ។

បើយើងក្រឡេកទៅមើល ការអនុវត្តនេះក៏អាចកើតមាន ផលអវិជ្ជមានមួយចំនួនផងដែរដូចជា ចៅក្រមអយ្យការមានអំណាចធំធេង ហើយគាត់អាចប្រើប្រាស់សិទ្ធិអំណាចនេះដើម្បីការពារផលប្រយោជន៍ និង បក្ខពួករបស់ខ្លួន ប្រសិនបើគាត់គ្មានមនសិការជាតិ និង វិជ្ជាជីវៈ ។ មួយវិញទៀត ជនរងគ្រោះផ្ទាល់នៃអំពើល្មើស មិនអាចទទួលបានយុត្តិធម៌ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីវិញ ក៏មិនអាចទទួលបាននូវសំណងការខូចខាត ពីតុលាការព្រហ្មទណ្ឌដែរ ពីព្រោះគ្មានការប្រកាសពីសំណងរដ្ឋប្បវេណីឡើយ បើមិនមានប្រកាសពីពិរុទ្ធភាព ។ មិនត្រឹមតែប៉ុណ្ណោះ គោលបំណងនៃទោសព្រហ្មទណ្ឌដែលរួមមាន បង្ការ បង្ក្រាប និង អប់រំ មិនអាចត្រូវបានអនុវត្ត ដែលជាហេតុអាចធ្វើឲ្យមានមនុស្សមើលស្រាលចំពោះច្បាប់ ។

ដើម្បីលុបបំបាត់នូវផលអវិជ្ជមានខាងលើ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវយន្តការជាច្រើនដើម្បីជំរុញឲ្យបណ្តឹងអាជ្ញា ឬ រឿងក្តីព្រហ្មទណ្ឌមានចលនាឡើងវិញ ដូចជាការចែងអនុញ្ញាតចៅក្រមអយ្យការ អាចសើរើដោយឯកឯង ដើម្បីយករឿងក្តីដែលបានតម្កល់រួចហើយមកចាត់ការឡើងវិញ ក្នុងអំឡុងពេលដែលបទល្មើសមិនទាន់ផុតអាជ្ញាយុកាល ឬ បណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ និង ការប្តឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ បន្ទាប់ពីបានទទួលដំណឹងអំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ រួមទាំងការផ្តល់សិទ្ធិអំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ធ្វើអធិបញ្ញាឲ្យចោទប្រកាន់ និង ការរៀបចំពាក្យប្តឹង

ដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ដោយនៅក្នុងបញ្ហាប្រឈមក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ រួមមានចំណុចដូចខាងក្រោម ៖

- **កង្វះធាតុផ្សំនៃបទល្មើស**
- **ការអន្តរាគមន៍របស់អ្នកមានអំណាច**
- **កត្តានយោបាយ**

### ១.១ កង្វះធាតុផ្សំនៃបទល្មើស

ជាទូទៅតំណាងអយ្យការធ្វើការតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើការកង្វះធាតុផ្សំនៃបទល្មើស ប្រសិនបើបទល្មើសមួយបានកើតឡើងដោយមានធាតុផ្សំមិនគ្រប់គ្រាន់នោះ តំណាងអយ្យការនឹងធ្វើការសម្រេចតម្កល់រឿងនោះទុកឥតចាត់ការ ទៅតាមមូលច្បាប់ដែលបានបញ្ញត្តិទុក ។

#### ១.១.១ ធាតុនីត្យានុកូល

ធាតុនីត្យានុគោល ជាធាតុផ្សំនៃបទល្មើសមួយក្នុងចំណោមធាតុផ្សំពីរទៀតដែលអាចកំណត់បានថា អំពើមួយដែលប្រព្រឹត្តដោយបុគ្គលណាម្នាក់គឺជាបទល្មើស ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។ ជាកាពិតណាស់ អំពើដែលអាចចាត់ទុកថា ជាបទល្មើសបានលុះត្រាតែអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ដូចដែលបានលើកឡើងខាងលើ ។ ដោយឡែក ស្ថិតក្នុងស្ថានភាពជាក់ស្តែង សង្កេតឃើញថាព្រះរាជអាជ្ញា មានភាពលំបាកជាខ្លាំងនៅក្នុងការតម្កល់រឿងមួយទុកឥតចាត់ការនៅពេលដែលរឿងនោះ គឺជាបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ដោយហេតុថា នៅពេលមានករណីដូចនេះកើតឡើង ព្រះរាជអាជ្ញា ផ្ទាល់ត្រូវតែពិនិត្យ និង លើកសំអាងហេតុមក ដើម្បីអះអាងថា បទល្មើសនៃរឿងមួយនោះអាចតម្កល់បាន ដោយយោងតាមសំអាងហេតុរបស់ខ្លួន ដូចជាស្ថានភាពសង្គមជាក់ស្តែង ដែលតម្រូវឲ្យមានការតម្កល់រឿងនោះ តាមរយៈអ្នកមានអំណាច ឬ ការស្នើសុំពីសំណាក់ប្រជាជន ។

#### ១.១.២ ធាតុសត្យានុម័ត

យោងតាមខ្លឹមសារនៃការបកស្រាយអំពីធាតុផ្សំសត្យានុម័ត ដែលបានលើកឡើងនៅក្នុងមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ខាងលើនេះ សបញ្ជាក់ឲ្យឃើញថា បទល្មើសមួយអាចកើតឡើងបានលុះត្រាណាវាមានធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ ។ ជាក់ស្តែងនៅក្នុងការអនុវត្តនូវនីតិវិធីផ្ទាល់ ឃើញថានៅពេលលដែលតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាមានផលវិបាននៅក្នុងការស្វែងរក នូវកម្មវត្ថុដែលជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសរបស់ជនល្មើសនោះ ព្រោះថាកម្មវត្ថុ ឬ សម្ភារៈទាំងអស់នោះ ជនសល្មើសអាចបានបោះចោលកប់ចោល ឬ លាក់ទុក នៅទីកន្លែងណាមួយដែលសមត្ថកិច្ចពុំអាចរកបាន ហេតុផលទាំងនោះហើយ ដែលធ្វើឲ្យព្រះរាជអាជ្ញា សម្រេចតម្កល់ទុកឥតចាត់ការចោល ទោះបីជាដឹងថារឿងនេះអាចនឹងមាន កម្មវត្ថុ ឬ សម្ភារៈ ដែល

ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស របស់ជនល្មើសក៏ដោយ ពីព្រោះថាប្រទេសយើងនៅខ្វះខាតខាងបច្ចេកទេសនៅឡើយ ។

### ១.១.៣ . ធាតុអត្តនោម័ត

ស្របតាមការបកស្រាយនៃធាតុផ្សំបទល្មើសទាំងពីរខាងលើនេះ បញ្ហាប្រឈមនៃធាតុអត្តនោម័ត ក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ របស់ព្រះរាជអាជ្ញានោះគឺ មានការលំបាកក្នុងការសិក្សាស្វែងយល់នូវអំពើចេតនា ឬ អចេតនា របស់ជនល្មើសឲ្យកាន់តែច្បាស់ ។ ផ្ទុយពីការចោទការប្រកាន់ ធាតុអត្តនោម័ត ត្រូវបានគេសន្មតថា ជាផ្នែកខាងក្នុងនៃបទល្មើស ឬ ជាផ្នែកបញ្ញាស្មារតី ដែលនាំឲ្យជនល្មើសបង្កឡើងក្នុងគោលបំណងដើម្បីបំពេញសេចក្ដីសម្រេចរបស់ខ្លួន ហើយអំពើនេះបង្កឲ្យមានព្យសនកម្មកើតមានឡើងដល់សង្គម ។ កត្តារួមផ្សំនៃបទល្មើសរួមមាន៖ កំហុសដោយចេតនា ឬ អចេតនា គំនិតផ្ដួចផ្ដើមប្រព្រឹត្តបទល្មើស និង គោលដៅនៃការប្រព្រឹត្តបទល្មើស។

## ១.២ ការអន្តរាគមន៍របស់អ្នកមានអំណាច

យើងបានដឹងហើយថាតំណាងអយ្យការ គឺជាម្ចាស់នៃបណ្ដឹងអាជ្ញាដែលច្បាប់បានកំណត់ និង ឲ្យសិទ្ធិអំណាចក្នុងការការពារផលប្រយោជន៍សាធារណៈ ។ ប៉ុន្តែដោយការអនុវត្តច្បាប់មួយចំនួន យើងឃើញមានការប្រឈមពាក់ព័ន្ធនឹងការអន្តរាគមន៍របស់អ្នកមានអំណាចនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ដែលជាហេតុនាំឲ្យមានការលំបាកក្នុងការអនុវត្តច្បាប់របស់មន្ត្រីអនុវត្តច្បាប់ ។

បញ្ហាប្រឈមរបស់តំណាងអយ្យការ នៅក្នុងនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ដោយមានការអន្តរាគមន៍របស់អ្នកមានអំណាចមានដូចជា៖

ធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ តែតំណាងអយ្យការត្រូវធ្វើការតម្កល់រឿងទុកឥតចាត់ការ តាមរយៈការចង្អុលបង្ហាញរបស់អ្នកមានអំណាចណាមួយ ទៅដល់ជនណាម្នាក់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ក្រោមការគៀបសង្កត់ណាមួយ ។ ប្រយោជន៏ផ្ទាល់ខ្លួនរបស់អ្នកមានអំណាចទាំងអស់នេះ ទៀតសោត គឺកើតឡើងដោយការគុំគួន និង កំហឹង ឬ មានបំណងចង់ធ្វើបាបជនណាម្នាក់ដែលនិយាយប៉ះពាល់ ឬ ធ្វើអ្វីមួយដែលនាំឲ្យខាតបង់ប្រយោជន៍ផ្ទាល់ខ្លួន ។ ត្រង់ចំណុចនេះធ្វើឲ្យព្រះរាជអាជ្ញា មានផលវិបាក ហើយវាខុសពីបញ្ញត្តិនៃច្បាប់ចែង និង ជាពិសេសនោះ គឺខុសពីសតិសម្បជញ្ញៈ និង វិជ្ជាជីវៈ ទៀតផង ។

ធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ តែតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការដោយហេតុថា មានការអន្តរាគមន៍ ពីសំណាក់អ្នកមានអំណាច ដែលនាំឲ្យមានការខូចប្រយោជន៍សាធារណៈ ។ ជាក់ស្ដែង នៅក្នុងសង្គមរស់នៅសព្វថ្ងៃ មនុស្សភាគច្រើន គឺស្រឡាញ់ នូវអំណាច បុណ្យសក្តិ និងទ្រព្យសម្បត្តិរបស់ខ្លួន នៅពេលដែលមានការប្រព្រឹត្តនៅទោសកំហុសអ្វីមួយដែលខុសពីច្បាប់ និយាយរួមគឺប្រព្រឹត្តនូវបទល្មើសណាមួយដែល

មានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា គឺរមែងតែប្រើប្រាស់នូវអំណាច និងទឹកប្រាក់របស់ខ្លួន មកធ្វើការគៀបសង្កត់លើ ឆន្ទានុសិទ្ធិ ក្នុងការតម្កល់រឿងទុកឥតចាត់ការ របស់ព្រះរាជអាជ្ញា ។

### **១.៣. កត្តានយោបាយ**

ចំពោះកត្តានយោបាយក្នុងការតម្កល់រឿងទុកឥតចាត់ការនេះផងដែរ វាក៏មិនខុសគ្នាពីកត្តានយោបាយ ដែលជាបញ្ហាប្រឈមក្នុងការចោទប្រកាន់ដែរ ហើយវាកើតឡើងដោយការអន្តរាគមន៍ពីអ្នកកាន់អំណាចនោះ ក៏មានកត្តានយោបាយ ដែលជាកត្តាចម្បងមួយ និង មានការពិបាកជាងកត្តាផ្សេងៗខាងលើទៅទៀត ។ យើងដឹងហើយថា ប្រទេសកម្ពុជាទោះបីជាមានច្បាប់គ្រប់គ្រង់សម្រាប់ឲ្យអនុវត្តយ៉ាងណាក្តី ក៏កត្តានយោបាយនៅតែជាកត្តាមួយដែលជះឥទ្ធិពលដែលអាចធ្វើអោយមានការប្រែប្រួលនៃការអនុវត្តច្បាប់ ។

ម្យ៉ាងវិញទៀតនៅក្នុងរឿងក្តីនយោបាយ គឺនៅពេលដែលមានចុងចម្លើយជាសកម្មជននយោបាយ តំណាងអយ្យការ ត្រូវធ្វើការមើលពីធាតុផ្សំនៃបទល្មើស ការប្រព្រឹត្ត និងការស៊ើបអង្កេតទៅលើអង្គហេតុ ឲ្យបានច្បាស់លាស់ ។ ជាពិសេសទៅទៀត គឺត្រូវធ្វើការពិនិត្យទៅលើភស្តុតាងដែលប្រមូលបាន មុននឹងធ្វើការចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ លើជននោះ ។ បន្ថែមពីនេះទៅទៀត នៅក្នុងការកាន់នូវសំណុំរឿងដែលទាក់ទងទៅនឹងរឿងក្តីនយោបាយ ព្រះរាជាអាជ្ញា ត្រូវធ្វើការផ្ទិតផ្ទង់ ពិនិត្យ នូវទម្រង់ អក្ខរាវិរុទ្ធ នៃដីកានីមួយៗ ឬលិខិតបទដ្ឋានគតិយុត្ត ឲ្យម៉ត់ចត់បំផុត តាមដែលអាចធ្វើបាន ។

ជាពិសេសទៅទៀតនោះ បើយើងក្រឡេកទៅមើលទិដ្ឋភាពជាក់ស្តែងវិញ ពាក់ព័ន្ធជាមួយសុវត្ថិភាពរបស់តំណាងយ្យការវិញ យើងឃើងថា វាពិតជាមានភាពអសុវត្ថិភាពមែនទែន នៅពេលដែលកាន់សំណុំរឿងនយោបាយ ព្រោះនាពេលសវនាការរឿងក្តីនយោបាយម្តងៗ សង្កេតឃើញថា តែងតែមានសកម្មជនរបស់បក្សនយោបាយទាំងនោះ ទៅធ្វើបាតុកម្មជានិច្ច ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក ក្រុមយើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថា អង្គការអយ្យការបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីនៃការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ ហើយការអនុវត្តរបស់អង្គការអយ្យការនេះគឺធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺត្រូវធ្វើឡើងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ជាធរមាន ហើយក្នុងការចោទប្រកាន់នេះគឺសំដៅដល់ការចោទប្រកាន់ទៅលើជនណាដែលប្រព្រឹត្តអំពើដែលល្មើសច្បាប់ដែលមានចែង យ៉ាងណាមិញការអនុវត្តនីតិវិធីនៃការចោទប្រកាន់នេះ យើងសង្កេតឃើញថា មានបញ្ហាប្រឈមដល់ការអនុវត្តនីតិវិធីពីសំណាក់ ការអន្តរាគមន៍របស់អ្នកមានអំណាច និងកត្តានយោបាយដែលនាំឲ្យការសម្រេចរបស់ព្រះរាជអាជ្ញាមានការលំបាកជាហេតុឲ្យមានការចោប្រកាន់ខុសនីតិវិធីនៃច្បាប់ ។ លើសពីនេះទៀតការចោទប្រកាន់ដែលស្ថិតក្រោមឥទ្ធិពលនៃអ្នកមានអំណាចនេះបានធ្វើឲ្យមានការរិះគន់ពីសំណាក់ពីប្រជាពលរដ្ឋទូទៅផងដែរ ។

រីឯនៅក្នុងការតម្កល់រឿងទុកឥតចាត់ គឺនៅពេលដែលការព្រះរាជអាជ្ញាយល់ឃើញថានៅក្នុងពាក្យបណ្តឹងពុំមានលក្ខណគ្រប់គ្រាន់ពោលគឺ ធាតុផ្សំនៃបទល្មើសពុំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ដែលជាហេតុនាំឲ្យមានការតម្កល់រឿងទុកឥតចាត់ការ ។ ហើយការអនុវត្តការសម្រេចការតម្កល់រឿងទុកឥតចាត់ការនេះផងដែរ ការអនុវត្តនីតិវិធីសង្កេតឃើញថា ក៏មានបញ្ហាប្រឈមផងដែរដូចជា ការអន្តរាគមន៍របស់អ្នកមានអំណាច និង កត្តានយោបាយជាដើម ។ ជាមួយគ្នានេះផងដែរ ប្រសិនបើការតម្កល់រឿងទុកឥតចាត់របស់ព្រះរាជអាជ្ញា នាំឲ្យមានការសម្រេចខុសនីតិវិធី ពោលគឺបណ្តឹងមានធាតុផ្សំគ្រប់គ្រាន់ហើយតែព្រះរាជអាជ្ញាបែរជាតម្កល់រឿងទុកឥតចាត់ការនោះ គឺបានបង្ហាញពីភាពអយុត្តិធម៌សង្គម នាំឲ្យមានបទល្មើសមានការកើនឡើង និង មានភាពលំអៀងក្នុងការអនុវត្តច្បាប់ ។

សរុបមក នៅក្នុងនីតិវិធីនៃការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការនេះ គឺព្រះរាជអាជ្ញាត្រូវធ្វើឡើងតាមនីតិវិធីនៃច្បាប់ ដែលរួមមានរដ្ឋធម្មនុញ្ញ និង ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងនីតិវិធីនេះបានបង្ហាញឲ្យឃើញពីសារៈសំខាន់ និង តួនាទីភារៈកិច្ចរបស់ព្រះរាជអាជ្ញានៅក្នុងដំណើរ ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ព្រមទាំងបានដឹងពីស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ ។ លើសពីនេះទៀត បានដឹងពីបញ្ហាប្រឈមនានាដែលបានកើតមានឡើងនៅក្នុងដំណើរការនីតិវិធី ដែលជាហេតុធ្វើឲ្យការអនុវត្តមានភាពលំបាក ក្នុងការចេញដីកាសម្រេចនានា របស់

ព្រះរាជអាជ្ញា ។ ហើយនៅក្នុងការអនុវត្តការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ ដើម្បីឲ្យមានភាពប្រសើរឡើង ក្រុមយើងខ្ញុំនឹងធ្វើការផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម ក្នុងគោលបំណងជួយក្នុងការកែលំអនៅភាពអសកម្មមួយចំនួនដែលកើតមានឡើងនាពេលបច្ចុប្បន្ននេះ ។

# អនុសាសន៍

យោងទៅតាមបរិបទសង្គមបច្ចុប្បន្ន ដោយមានការវិវត្តន៍នៃការពង្រឹងនៃការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ដែលមានក្រសួងយុត្តិធម៌ជាសេនាធិការ ក្នុងការតាក់តែងច្បាប់ និងធ្វើការកែទម្រង់លើវិស័យយុត្តិធម៌នៅប្រទេសកម្ពុជា ដោយបានដាក់ចេញនូវផែនការ យុទ្ធសាស្ត្រ និង ការអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះមន្ត្រីដែលធ្វើការអនុវត្តច្បាប់ផ្ទុយនឹងបទបញ្ញត្តិដែលមាន ក្នុងគោលបំណងឲ្យការអនុវត្តច្បាប់មានប្រសិទ្ធិភាពខ្ពស់ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ដូចគ្នានេះផងដែរ ស្ថាប័នអយ្យការដែលមានតួនាទី ក្នុងការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ គឺបានអនុវត្តសកម្មភាពបំពេញការងាររបស់ខ្លួនបានយ៉ាងល្អប្រសើរច្រើន ដោយហេតុថា ស្ថាប័នមួយនេះបានអនុវត្តសកម្មភាពយ៉ាងសកម្ម ស្របតាមច្បាប់ដែលមានចែង និង ការប្តេជ្ញាចិត្តធ្វើការបម្រើប្រជាជននៅតាមដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាដល់ការបង្ការកុំឲ្យមានបទល្មើសមានការកើនឡើង និង បង្ក្រាបបទល្មើសផ្សេងៗ ដែលបានកើតមានឡើងនៅក្នុងសង្គមនាពេលខាងមុខ ដោយអនុវត្តផ្តន្ទាទោសទៅតាមច្បាប់ (ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩) និង ការអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ។

ប៉ុន្តែទន្ទឹមនឹងមានចំណុចល្អប្រសើរយ៉ាងណាក៏ដោយ ក្នុងនោះគឺនៅតែមាននូវការខ្វះខាត និង ការខ្វះចន្លោះនូវការងារមួយចំនួនផងដែរ ។

ដូចនេះដើម្បីឲ្យការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ របស់តំណាងអយ្យការមានកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុន យើងខ្ញុំសូមការអនុញ្ញាតផ្តល់ជាអនុសាសន៍មួយចំនួន ក្នុងការអនុវត្តការងាររបស់តំណាងអយ្យការ ដូចខាងក្រោមនេះ ៖

១. ការសម្រេចក្នុងការចោទប្រកាន់ និង ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដែលប្រកបដោយភាពល្អប្រសើរនោះគឺ ការចោទប្រកាន់ និង ការតម្កល់រឿងទុកឥតចាត់ការ មួយដែលមានលក្ខណៈប្រកបដោយវិជ្ជាជីវៈ ដោយធ្វើការងារឈរលើគោលការណ៍ច្បាប់ឲ្យបានតឹងរឹងបំផុត ពុំមានការលើកលែងណាមួយឡើយ ស្របតាមអង្គហេតុ និង អង្គច្បាប់ សុចរិតភាព និង ភាពស្មោះត្រង់ ពោលគឺសម្រេចចោទប្រកាន់ និង តម្កល់រឿងទុកឥតចាត់ការ ដោយពិនិត្យទៅលើភស្តុតាង និង សាក្សី ហើយការសម្រេចទាំងនោះគឺ ដើម្បីជាផលប្រយោជន៍ដល់សង្គមជាតិ ។

២. ពាក់ព័ន្ធការយល់ដឹងពីច្បាប់ដូចជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ គួរមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ និង មានការអប់រំ ទៅដល់ប្រជាពលរដ្ឋ ដើម្បីងាយស្រួយក្នុងការអនុវត្តច្បាប់ និង មិនមានការលំលោភបំពានលើសិទ្ធិនានា មានការការពារដោយច្បាប់ មួយវិញទៀតមិនមានការគំរាមកំហែងពីសំណាក់អ្នកមានអំណាចដែលរំលោភបំពានច្បាប់ ដោយអ្នកមានអំណាចមួយចំនួនប្រើប្រាស់ច្បាប់ក្នុងការគំរាមកំហែងទៅលើបុគ្គលដែលមិនបានយល់ដឹងពីច្បាប់បានទូលំទូលាយ ។ នៅពេលដែលប្រជាពលរដ្ឋមានចំណេះដឹងផ្នែកច្បាប់ច្រើន នោះតំណាងអយ្យការអាច នឹងទទួលបានការប្តឹងបរិហាពីសំណាក់ប្រជាពលរដ្ឋផ្ទាល់ ឬ ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ព្រោះដោយសារពួកគាត់ដឹងថាអ្វីជាបទល្មើសព្រហ្មទណ្ឌ ហើយវាអាចជួយកាត់បន្ថយបទល្មើសដែលកើតមានឡើងក្នុងសង្គម ផងដែរ ។

៣. ផ្តល់ជាសម្ភារៈ និង ឧបករណ៍បច្ចេកទេស សម្រាប់ការធ្វើកោសលវិច័យក្នុងរឿងក្តីដែលបានកើតមានឡើងដល់មន្ត្រីមានសមត្ថកិច្ច ដើម្បីជាការងាយស្រួលសម្រាប់តំណាងអយ្យការ ធ្វើការចោទប្រកាន់លើជនល្មើសឲ្យបានច្បាស់ ដោយមិនមានការយល់ច្រឡំណាមួយឡើយ ។

# ឯកសារយោង

## I. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
2. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
3. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
4. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
5. ច្បាប់ស្តីពីការទប់ស្កាត់អំពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

## II. សៀវភៅ និងអត្ថបទផ្សេងៗ

លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងកែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌទូទៅ* ឆ្នាំ២០០៦

## III. គេហទំព័រ

អាចរកបាននៅ https://www.pheakdeylaw.com/kh/publication/45

https://www.facebook.com/329066187511534/posts/902049593546521/?d=n

# ឧបសម្ព័ន្ធ

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

**មាត្រា ៥.-**

ភាសា និងអក្សរដែលប្រើជាផ្លូវការគឺ ភាសា និងអក្សរខ្មែរ ។

**មាត្រា ៦.-**

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១,២ និង ៣ ។

## ជំពូកទី ២
## អំពីព្រះមហាក្សត្រ

**មាត្រា ៧ .-**

ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ ។

**មាត្រា ៨.-**

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការ

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសម្រេចដោយមតិយល់ព្រម ពីរភាគបីយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៧៩.-**

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗ នៃរដ្ឋសភា ។

**មាត្រា ៨០.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្របណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨១.-**

រដ្ឋសភាមានថវិកាស្វយ័ត សម្រាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ៩០.-ថ្មី (ពីរ)**

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩១.-ថ្មី**

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

**មាត្រា ១៣០ . _ ថ្មី (មាត្រា ១១១ ចាស់)**

គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ ។

**មាត្រា ១៣១ . _ ថ្មី (មាត្រា ១១២ ចាស់)**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

**មាត្រា ១៣២ . _ ថ្មី (មាត្រា ១១៣ ចាស់)**

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**មាត្រា ១៣៣ . _ ថ្មី (មាត្រា ១១៤ ចាស់)**

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រម ដែលបានប្រព្រឹត្តខុស ។

**មាត្រា ១៣៤ . _ ថ្មី (មាត្រា ១១៥ ចាស់)**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និងមុខងារ។

# ក្រមព្រហ្មទណ្ឌ

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី ១
## ច្បាប់ព្រហ្មទណ្ឌ
### ជំពូកទី ១
### គោលការណ៍ទូទៅ

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខុសរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ នៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស

គ្មានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសក៏អាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះ មិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬ អនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬ ត្រូវតែឈប់អនុវត្ត ។

**មាត្រា ១០.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទា-

ទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទបញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទបញ្ញត្តិនោះ ។

**មាត្រា ១១.–** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទបញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទបញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ

### ផ្នែកទី ១

### បទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.–** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.–** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានទង់សញ្ញាជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទ-ល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុន-ប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬ មិនបានប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុ របស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថាជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២

## មូលហេតុនៃការមិនទទួលខុសត្រូវ ឬ ការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.–** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬ សារធាតុដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.–** ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬ មិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ នឹងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍ នេះត្រូវរលាយដោយភស្តុតាងផ្ទុយ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈ របស់អនីតិជនតម្រូវ ។

**មាត្រា ៤០.- ប្រភេទនៃវិធានការ**

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.- ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ**

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញានូវព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទ-

# ក្រមនីតិវិធីព្រហ្មទណ្ឌ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៤. – ការចាប់ផ្ដើមចំណើរការនៃបណ្ដឹងអាជ្ញាដោយអយ្យការ**

បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ។

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

**មាត្រា ៥. – ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ**

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្ដឹងដោយមានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្ដឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តដោយមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

យុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលបណ្ដឹងពីមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យផងដែរ ។

**មាត្រា ៦. – ការដាក់ពាក្យប្ដឹងទាមទារដោយជនរងគ្រោះ**

បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្ដឹងបាន ។ ពាក្យប្ដឹងសាមញ្ញ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ ។

នៅក្នុងករណីដែលពាក្យប្ដឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅតាមរបៀបដូចដែលមានចែងទុកដោយមាត្រា ៤១ (ការតម្កល់រឿងទុកឥតចាត់ការ) នៃក្រមនេះ ។

**មាត្រា ៧. – ការរលត់នៃបណ្ដឹងអាជ្ញា**

មូលហេតុនៃការរលត់បណ្ដឹងអាជ្ញាមានដូចតទៅគឺ :

១-មរណភាពនៃជនល្មើស ។

២-ការផុតអាជ្ញាយុកាល ។

៣-ការលើកលែងទោសជាទូទៅ ។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

៥-អាជ្ញាអស់ជំនុំ ។

កាលណាបណ្ដឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមបានទៀតទេ ឬត្រូវតែបញ្ឈប់ ។

## គន្ថីទី ២
## អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ស៊ើបសួរ និងស៊ើបអង្កេត
## មាតិកាទី ១
## អង្គការអយ្យការ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧.** – តួនាទីរបស់អង្គការអយ្យការ

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការធានាភាប់រងការអនុវត្តសេចក្ដីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។

ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ ។

**មាត្រា ២៨.** – ចៅក្រមអយ្យការ

ចៅក្រមអយ្យការមាន :

១-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។

២-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

**មាត្រា ២៩.** – ឋានានុក្រមនៃអង្គការអយ្យការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្ដឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្ដីព្រហ្មទណ្ឌណាមួយបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យ

## គន្ថីទី ២
## អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ស៊ើបសួរ និងស៊ើបអង្កេត
## មាតិកាទី ១
## អង្គការអយ្យការ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧.** – តួនាទីរបស់អង្គការអយ្យការ

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។

ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ ។

**មាត្រា ២៨.** – ចៅក្រមអយ្យការ

ចៅក្រមអយ្យការមាន :

១-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។

២-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

**មាត្រា ២៩.** – ឋានានុក្រមនៃអង្គការអយ្យការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យ

ព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៤១.** – ការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៤០ (បញ្ជីនៃពាក្យប្តឹង) នៃក្រមនេះ ។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ ។ ការតម្កល់ទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ ។

ព្រះរាជអាជ្ញាអាចសើពីកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ ។

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។

ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ ។ បន្ទាប់មក សំណុំរឿងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់ ។ អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញា តាមការណែនាំជាលាយលក្ខណ៍អក្សរ ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ទុកជាបានការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា ។

**មាត្រា ៤២.** – កាតព្វកិច្ចធ្វើបណ្តឹងហើហារចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៣៧.** – អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ប៉ុន្តែ កាលណាអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។

ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនេះបានទទួលស្គាល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួនជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។

**មាត្រា ៣៨.** – អំណាចរបស់ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស ។

**មាត្រា ៣៩.** – សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ :

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

## ផ្នែកទី ២
## ការអនុវត្តបណ្តឹងអាជ្ញា

**មាត្រា ៤០.** – ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើស

ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះ ភ្ជាប់ជាមួយផង ។

មិនអាចមានការលើកលែងផ្សេងណា ក្រៅពីការលើកលែងស្ដីអំពីអាថ៌កំបាំងខាងវិជ្ជាជីវៈ ក្នុងករណីដែលច្បាប់បានចែងយ៉ាងជាក់លាក់នោះទេ ។

**មាត្រា ៤៣.** – ការចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម :

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**មាត្រា ៤៤.** – ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ការស៊ើបសួរត្រូវបានបើក តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរ អាចបើកប្រឆាំងលើ បុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន :

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា ៤៥.** – ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាច :

- បើកការស៊ើបសួរដោយធ្វើដូចដែលបានចែងដោយមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ
- បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចបាន

ចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ឬ

-បង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចដែលបានចែងក្នុងមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) និងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

**មាត្រា ៤៦.** – ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន :

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

**មាត្រា ៤៧.** – ការបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

-បទល្មើសជាបទល្មើសជាក់ស្ដែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្ដែង) នៃក្រមនេះ

-បទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្ដីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**មាត្រា ៤៨.** – នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្ដីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។

មេធាវីជ្រើសរើស ឬចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម ។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

តុលាការជាន់ដំបូង ត្រូវបានទទួលបណ្ដឹងតាមកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្ដង ។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន ។

ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ ។

តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ ។ នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ ។ តុលាការចេញដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន ។

សាលក្រមលើអង្គសេចក្ដី ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្ដាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ ។ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ក្រោយពីផុតរយៈពេល ២ (ពីរ) សប្ដាហ៍ ។

ប្រសិនបើតុលាការដែលបានទទួលបណ្ដឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថា លក្ខខណ្ឌនៃមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពស្មុគស្មាញនៃសំណុំរឿង តម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្ដងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែ

ដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

**មាត្រា ៤៩.** - ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុ

ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ។

**មាត្រា ៥០.** - បញ្ជីនៃពាក្យប្តឹង

នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។

គ្រប់បណ្តឹងទាំងអស់ត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យប្តឹង

-ប្រភពនៃបណ្តឹង : បណ្តឹងផ្ញើមកផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

-ប្រភេទនៃរឿងហេតុដែលអ្នកប្តឹងបានរាយការណ៍

-ចំណាត់ការលើពាក្យប្តឹង : ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

បញ្ជីនៃពាក្យប្តឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

## មាតិកាទី ២
## ចៅក្រមស៊ើបសួរ
### ជំពូកទោល
### ចៅក្រមស៊ើបសួរ

**មាត្រា ៥១.** - ការចាត់តាំងដោយប្រធានតុលាការ

កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជំងឺ ឬដោយមានមូលហេតុដទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀត

# ច្បាប់

## ស្ដីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

២/៣៩

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន នោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី បាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុង ជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយក មកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណី ជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែន ការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារ សង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេច បង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈ របស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការឲ្យដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយ ផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នក តំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយ [illegible]អនីតិជន ។

# ច្បាប់

# ស្តីពី

# ការទប់ស្កាត់អំពើហិង្សា

# ក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

3/12

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.–**

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៦.–**

ការៈចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

នស/រកម/១០០៥/០៣១ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ហត្ថលេខា**

**អ៊ឹង កន្ថាផាវី**

លេខ ៤៤៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

15/16

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៣១៨២
ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២១
លេខ: ២៤៦០.....អ.យ.ណ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

## យើង ចែ សុខ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញរបាយការណ៍សំយោគលេខ: ០៩៦/២១ រ.ប.ក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ៣១៨២ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញមានតម្រុយសន្មតថា៖

១-នាមត្រកូល និងនាមខ្លួន៖ ភេទប្រុស អាយុ ២៥ឆ្នាំ, ជនជាតិខ្មែរ, មានទីកន្លែងកំណើតនៅភូមិអំពិលស្រោម ឃុំអំពិលលើ ស្រុកកំពង់សៀម ខេត្តកំពង់ចាម, កាន់សាសនាព្រះពុទ្ធ, មុខរបរ កម្មករ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់ នៅភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ, នៅលីវ, ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់", កម្រិតវប្បធម៌ ថ្នាក់ទី០៧ រៀ, ទោសពីមុនគ្មាន, ធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល ០២ឆ្នាំ ។ (ឃាត់ខ្លួន)

២-នាមត្រកូល និងនាមខ្លួន៖ ( ) ភេទប្រុស អាយុ២២ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ខណ្ឌ រដ៏យ រាជធានីភ្នំពេញ, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌ អំពៅ រាជធានីភ្នំពេញ, មុខរបរកម្មករ, ប្រពន្ធឈ្មោះ "រស់", ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "រស់",កម្រិតវប្បធម៌ ថ្នាក់ទី ០៨ថ្មី, ទោសពីមុន ធ្លាប់ជាប់មណ្ឌលអប់រំកែប្រែទី១ (ម១) រយៈពេល០២ឆ្នាំ ក្នុងឆ្នាំ២០១៧ ពីបទ: លួចកូតូ និងធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល ០១ឆ្នាំ ។ (ឃាត់ខ្លួន)

៣-បុរសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល ៤០ឆ្នាំ (គ្មានសាវតារជាតិ) ។ (គេចខ្លួន)

បានប្រព្រឹត្តអំពើដូចតទៅ[1]៖ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ០២ និង ២០ នាទី រំលងអធ្រាត្រ មានជនសង្ស័យចំនួន០២នាក់មានឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ និងឈ្មោះ ( ) ភេទប្រុស អាយុ ២២ឆ្នាំ ជាកម្មករធ្វើការក្នុងរោងចក្រទឹកកក បានធ្វើសកម្មភាពលួចយកសម្ភារៈរួមមាន៖ ម៉ូទ័របូមទឹកចំនួន០២គ្រឿង, ស៊ីមីម៉ាស៊ីនចំនួន០៦ និង ធុងហ្គាស ចំនួន ០១គ្រឿង នៅក្នុងរោងចក្រផលិតទឹកកក ផ្លូវ៣៦៩ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ រ ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៧៤ ឆ្នាំ ច្រកចូលបាវលើកដាក់លើរថយន្តដឹកទឹកកកម៉ាកHyundai ពណ៌ ក្រ មិនចាំផ្លាកលេខរបស់ជនរងគ្រោះ យកទៅលក់ឲ្យបុរសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល៤០ឆ្នាំ នៅតាមផ្លូវ ស្ថិតនៅសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ បានប្រាក់ចំនួន៧ម៉ឺនរៀល យកទៅទិញគ្រឿងញៀនជក់ និងស៊ីចាយអស់ រួចបើករថយន្តរបស់ជនរងគ្រោះមកទុកនៅរោងចក្រទឹកកកវិញ ។ លុះនៅព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ ជនរងគ្រោះបានមកធ្វើការនៅរោងចក្រផលិតទឹកកក ស្រាប់តែបាត់សម្ភារៈរបស់ខ្លួនក៏ទៅឆែកកាមេរ៉ាសុវត្ថិភាពមើលឃើញជនសង្ស័យទាំង០២នាក់លួចយកសម្ភារៈរបស់ខ្លួន ។ បន្ទាប់មកនៅវេលាម៉ោង ១៤ និង ០០ នាទី ថ្ងៃខែឆ្នាំដដែល ជនរងគ្រោះបានឃើញជនសង្ស័យទាំង០២នាក់ នៅភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏ឃាត់ខ្លួនប្រគល់ឲ្យ

---

[1] សេចក្តីសង្ខេបអង្គហេតុ

សមត្ថកិច្ចនគរបាលខណ្ឌច្បារអំពៅធ្វើការសោកស្ទរ និងធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀនជាលទ្ធផលវិជ្ជមាន កសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-អំពើប្រព្រឹត្តខាងលើជាបទល្មើស៖ **លួច ,ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** និង **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចរោងចក្រផលិតទឹកកក ផ្លូវ៣៦៩ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ ៨៤ មាត្រា ៨៨ និងមាត្រា ៣៩៩ មត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ: មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☐ ដាក់ឲ្យស្ថិតក្រោមការពិនិត្យ[2] ៖

១-ឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ ។ (ឃាត់ខ្លួន)

ពីបទ៖ **លួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរោងចក្រផលិតទឹកកក ផ្លូវ៣៦៩ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ ( ) ភេទប្រុស អាយុ ២២ឆ្នាំ ។ (ឃាត់ខ្លួន)

ពីបទ៖ **លួច ,ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរោងចក្រផលិតទឹកកក ផ្លូវ៣៦៩ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ មាត្រា ៨៤ មាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-បុរសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល ៤០ឆ្នាំ (គ្មានសាវតារជាតិ) ។ (គេចខ្លួន)

ពីបទ៖ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចរោងចក្រផលិតទឹកកក ផ្លូវ៣៦៩ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៩៩ មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

☐ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3] ៖..............................................................................

☑ ដាក់ឲ្យស្ថិតនៅការឃុំខ្លួនបណ្តោះអាសន្ន[4] ជនសង្ស័យខាងលើ

ថ្ងៃសៅរ៍ ៦កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**

[2] ឈ្មោះជនត្រូវចោទ

[3] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[4] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ:៥២៩៨
ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០
លេខ:..2258...........អ.យ.ណ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ: ពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់ឈ្មោះ ។

-បានឃើញ: ពាក្យបណ្តឹងតប ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ របស់ឈ្មោះ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ៥២៩៨ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញមានតម្រុយសន្មតថា៖

១-គោត្តនាម និងនាម៖ ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ, មុខរបរ យោធា, ទីកន្លែងកំណើតនៅភូមិធ្លក ឃុំស្ពឺ ស្រុកបាភ្នំ ខេត្តព្រៃវែង, កាន់សាសនាព្រះពុទ្ធ, ទីលំនៅសព្វថ្ងៃស្នាក់នៅបន្ទប់ជួល ភូមិព្រលួ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ, ប្រពន្ធឈ្មោះ ( ) "រ" មានកូន១នាក់, ឪពុកឈ្មោះ "រ", ម្តាយឈ្មោះ "រ", ទោសពីមុន គ្មាន, កំរិតវប្បធម៌ថ្នាក់ទី ៨ថ្មី។ (ក្រៅឃុំ)

២-គោត្តនាម និងនាម ( ) ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ, មុខរបរ នៅផ្ទះ, ទីកន្លែងកំណើតនៅភូមិធ្លក ឃុំស្ពឺ( )ត ស្រុកបាភ្នំ ខេត្តព្រៃវែង, កាន់សាសនាព្រះពុទ្ធ, ទីលំនៅសព្វថ្ងៃស្នាក់នៅបន្ទប់ជួលលេខ១០ ផ្លូវម៉ុងឫទ្ធី ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ, ប្តីឈ្មោះ "រ" មានកូន១នាក់, ឪពុកឈ្មោះ "រ", ម្តាយឈ្មោះ "រ", ទោសពីមុន គ្មាន, កំរិតវប្បធម៌ថ្នាក់ទី ១២ថ្មី។ (ក្រៅឃុំ)

បានប្រព្រឹត្តអំពើដូចតទៅ[1]៖ ឈ្មោះ និងឈ្មោះ ( ) បានរៀបអាពាហ៍ពិពាហ៍ នៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៩ និងមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ។ លុះដល់ឆ្នាំ២០១៧ ការរស់នៅមិនសូវចុះសម្រុងនឹងគ្នា ។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ឈ្មោះ ( ) បានលួចផិត ក្បត់ជាមួយឈ្មោះ នៅក្នុងបន្ទប់ជួល ហើយត្រូវបានឈ្មោះ តាមទាន់ ។ ដោយឡែក នៅចុងឆ្នាំ២០១៨ ឈ្មោះ បានលួចផិតជាមួយស្រីផ្សេង នៅរាជធានីភ្នំពេញ ហើយរៀបការជាមួយស្រីនោះនៅខេត្តកំពត នាថ្ងៃ ទី១២ ខែមករា ឆ្នាំ២០១៩ ។

-អំពើប្រព្រឹត្តរបស់ឈ្មោះ ភេទប្រុស អាយុ ៣៦ឆ្នាំ ជាបទល្មើស៖ **ផិត** ប្រព្រឹត្តនៅ ខេត្តកំពត កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ និងមាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព ។

-អំពើប្រព្រឹត្តរបស់ឈ្មោះ ( ) ភេទស្រី អាយុ ២៨ឆ្នាំ ជាបទល្មើស៖ **ផិត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ និងមាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព ។

[1]សេចក្តីសង្ខេបអង្គហេតុ

-បានឃើញៈ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☐ ដាក់ឱ្យស្ថិតក្រោមការពិនិត្យ[2] ៖

១-ឈ្មោះ ភេទប្រុស អាយុ ៣៦ឆ្នាំ ( ក្រៅឃុំ ) ។

ពីបទ៖ ផិត ប្រព្រឹត្តនៅ ខេត្តកំពត កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ និងមាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព ។

២-ឈ្មោះ ( ) ភេទស្រី អាយុ ២៨ឆ្នាំ ( ក្រៅឃុំ ) ។

ពីបទ៖ ផិត ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ និងមាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព ។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3] ៖.............................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន លើ[4] ៖

ថ្ងៃពុធ ៤រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦[redacted]

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១

**តំណាងអយ្យការ**

---

[2] ឈ្មោះជនត្រូវចោទ

[3] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[4] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា២០៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ: ០៥០ អ.យ.គ

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

## តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**យើង**

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ២០៦៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញមាត្រា ៤៦, ៤៩, ២៩១, ២៩៥, ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

## ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

ឃើញថា៖

កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ២៣ និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លា សហការជាមួយកម្លាំងផ្នែកជំនាញ នៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានចុះបង្ក្រាបជាក់ស្តែងលើករណី ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានទីតាំងត្រង់ចំណុចផ្លូវបេតុង ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ៣នាក់៖ ១-ឈ្មោះ ភេទស្រី អាយុ២៧ ឆ្នាំ ២-ឈ្មោះ ភេទប្រុស អាយុ៣៨ ឆ្នាំ និង៣-ឈ្មោះ ភេទប្រុស អាយុ៤០ ឆ្នាំ ។ ក្រោយពីឃាត់ខ្លួនជនសង្ស័យខាងលើ សមត្ថកិច្ចបាននាំខ្លួនជនសង្ស័យទៅធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន ជាលទ្ធផលបង្ហាញថា: វិជ្ជមាន (មានសារធាតុញៀន) ។

**បានឃើញ៖**

-របាយការណ៍សំយោគលេខ: ០៥៥/២១ រ.ប.ក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ឈ្មោះ ឈ្មោះ នៅដំណាក់កាលសមត្ថកិច្ច និងនៅអយ្យការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ពួកខ្លួនពិតជាធ្លាប់ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

-ឯកសារគតិយុត្តដែលពាក់ពន្ធ័ក្នុងសំណុំរឿង ។

## យល់ឃើញថា៖

-តាមចម្លើយរបស់ឈ្មោះ ភេទស្រី អាយុ២៧ ឆ្នាំ ឈ្មោះ ភេទប្រុស អាយុ៣៨ ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ៤០ ឆ្នាំ បានឆ្លើយសារភាពមានភាពស៊ីសង្វាក់ទៅរបាយការណ៍សំយោគលេខ: ០៥៥/២១ រ.ប.ក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ និងភស្តុតាងនានាថា: កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ២៣ និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លា សហការជាមួយកម្លាំងផ្នែកជំនាញ នៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានចុះបង្ក្រាបជាក់ស្តែងលើករណី ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានទីតាំងត្រង់ចំណុចផ្លូវបេតុង ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ៣នាក់៖ ១-ឈ្មោះ ភេទស្រី អាយុ២៧ ឆ្នាំ ២-ឈ្មោះ ភេទប្រុស អាយុ៣៨ ឆ្នាំ និង៣-ឈ្មោះ ភេទប្រុស អាយុ៤០ ឆ្នាំ ។ ក្រោយពីឃាត់ខ្លួនជនសង្ស័យខាងលើ សមត្ថកិច្ចបាននាំខ្លួនជនសង្ស័យទៅធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន ជាលទ្ធផលបង្ហាញថា: វិជ្ជមាន (មានសារធាតុញៀន) ។

-អំពើរបស់ជនជាប់ចោទឈ្មោះ ភេទស្រី អាយុ២៧ ឆ្នាំ ២-ឈ្មោះ ភេទប្រុស អាយុ៣៨ ឆ្នាំ និង៣-ឈ្មោះ ភេទប្រុស អាយុ៤០ ឆ្នាំ គឺមានចេតនាក្នុងការប្រព្រឹត្តសកម្មភាព ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីចោទប្រកាន់លើឈ្មោះ  ភេទស្រី អាយុ២៧ ឆ្នាំ ២-ឈ្មោះ  ភេទប្រុស អាយុ៣៨ ឆ្នាំ និង៣-ឈ្មោះ  ភេទប្រុស អាយុ៤០ ឆ្នាំ ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## **ហេតុដូច្នេះសម្រេច**

ចោទប្រកាន់៖

១-ឈ្មោះ  ហៅ  ភេទស្រី អាយុ២៧ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅឃុំព្រែកកំបៅ ស្រុកកងមាស ខេត្តកំពង់ចាម, កាន់សាសនាព្រះពុទ្ធ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ, មុខរបរ មិនពិតប្រាកដ, ប្តីឈ្មោះ  (លែងលះ) មានកូន៤នាក់, ឪពុកឈ្មោះ  "រស់" ម្តាយឈ្មោះ  "រស់", កំរិតវប្បធម៌ ថ្នាក់ទី៥ថ្មី, ទោសពីមុន គ្មាន ។

២-ឈ្មោះ  ភេទប្រុស អាយុ៣៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង, កាន់សាសនាព្រះពុទ្ធ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ, មុខរបរ មិនពិតប្រាកដ, ប្រពន្ធឈ្មោះ  (លែងលះ) មានកូនចំនួន០១នាក់, ឪពុកឈ្មោះ  "រស់" ម្តាយឈ្មោះ  "រស់", កំរិតវប្បធម៌ ថ្នាក់ទី៥ថ្មី, ទោសពីមុន គ្មាន ។

៣-ឈ្មោះ  ភេទប្រុស អាយុ៤០ ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៥១$E_2$ ផ្លូវលេខ១១០ ភូមិទី២៤ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ, មុខរបរ កសិករ, ប្រពន្ធឈ្មោះ  "រស់" មានកូន៦នាក់, ឪពុកឈ្មោះ  "ស្លាប់" ម្តាយឈ្មោះ  "ស្លាប់", កំរិតវប្បធម៌ ថ្នាក់ទី៩ថ្មី, ទោសពីមុន គ្មាន ។

ត្រូវជាប់ចោទពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ និងសំណុំរឿងព្រហ្មទណ្ឌលេខ...២០៦៥...ចុះថ្ងៃទី...២៧...ខែឧសភា ឆ្នាំ២០២១ និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងសំណុំរឿងនេះទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១
**អំណាចអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ទទួល ថ្ងៃទី ៤ ខែ ២ ឆ្នាំ ២០២១

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខៈ ១៦០ អ.យ.ណ

## ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

**យើង** **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៨៣០ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញៈ មាត្រា ៤៦, ៤៩, ២៩១, ២៩៥, ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

### ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

**ឃើញថាៈ**

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ២០ នាទី ក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័ត នៃរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយរដ្ឋបាលជលផល និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានចុះប្រតិបត្តិការបង្ក្រាបបទល្មើស សត្វព្រៃ និងសំណាកសត្វព្រៃ នៅចំណុចអាហារដ្ឋាន វិចិត្រ៣ ស្ថិតតាមបណ្តោយផ្លូវ២៨៥ ផ្ទះលេខ៤២ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឆែកឆេរកឃើញមានសំណាកសត្វចាបពួក(បោចរួច) ចំនួន ៣២៤ក្បាល ដែលមានឈ្មោះ ភេទប្រុស អាយុ ២៧ឆ្នាំ ជាអ្នកទទួលខុសត្រូវ ។ ក្រោយការឆែកឆេរឈ្មោះ បានសារ ភាពថាៈ ខ្លួនពិតជាបានទទួលទិញយកមករក្សាទុកដើម្បីធ្វើម្ហូបលក់បន្តដោយគ្មានលិខិតអនុញ្ញាត ពីរដ្ឋបាលព្រៃឈើ ពិតប្រាកដមែន ។

**បានឃើញៈ**

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ភេទ ប្រុស អាយុ ២៧ឆ្នាំ ឆ្លើយនៅ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឆ្លើយបញ្ជាក់ថាៈ ខ្លួនដឹងថាការការធ្វើពាណិជ្ជកម្ម សំណាកសត្វព្រៃជាអំពើខុសច្បាប់ ។ ចំពោះសំណាកជាសត្វព្រៃទាំងអស់ខាងលើ ខ្លួនទិញពីខេត្តព្រៃវែង មានរយៈពេល២សប្តាហ៍ហើយ ដើម្បីធ្វើម្ហូបលក់បន្តនៅអាហារដ្ឋាន វិចិត្រ៣ ដោយគ្មានការអនុញ្ញាត ពីរដ្ឋបាលព្រៃឈើឡើយ ។ សូមបញ្ជាក់ថាៈ ខ្លួនមិនបានយល់ច្បាស់លាស់ថាការលក់សត្វចាបពួក នេះជាអំពើល្មើសនោះទេ ។

-ចម្លើយរបស់ឈ្មោះ ភេទស្រី អាយុ ៦២ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ ៧០ឆ្នាំ នៅអយ្យការបានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ ពួកខ្លួន រួមទាំងកូនៗ បានបើកអាហារដ្ឋាន "វិចិត្រ៣" មានរយៈពេលប្រហែល៤ឆ្នាំ មកហើយ ដោយកន្លែងអាហារដ្ឋានពួកខ្លួនមិនមានបើកលក់ម្ហូបអាហារ សត្វព្រៃលក់ជូនភ្ញៀវឡើយ គឺលក់អាហារធម្មតា ។ រហូតដល់ថ្ងៃខែមិនចាំ ឆ្នាំ២០២០ វេលាចន្លោះម៉ោង ៩ ទៅ ១០ ព្រឹក ស្រាប់តែមានសមត្ថកិច្ចប៉េអឹម និងមេព្រៃ បានចុះមកអាហារដ្ឋានពួកខ្លួនសុំត្រួតពិនិត្យ ក៏រកឃើញ ចាបពួក(បោចរួច) នៅក្នុងទូរទឹកកកចុងភៅ ហើយសមត្ថកិច្ចក៏ដកហូតសត្វព្រៃទាំងនោះយកទៅ ។ ចំពោះសត្វព្រៃដែលសមត្ថកិច្ចដកហូតខាងលើគឺឈ្មោះ ជាចុងភៅនៅអាហារដ្ឋានរបស់ពួកខ្លួនបានឲ្យកូនចៅគាត់ទៅលេងស្រុកកំណើតទិញយកមកទុកចំអិនហូបរួមគ្នាប៉ុណ្ណោះ មិនមែនទិញយកមកចំអិនលក់ឲ្យភ្ញៀវទេ ហើយការទិញសត្វព្រៃនេះ ខ្លួនមិនបានដឹងឡើយ ទាល់តែសមត្ថកិច្ចចុះមកត្រួត ពិនិត្យទើបខ្លួនដឹង ។ នៅក្នុងអាហារដ្ឋានយើងមិនមានបើកលក់អាហារសត្វព្រៃឡើយ ។

-កំណត់ហេតុនៃបទល្មើសលេខៈ ២៤ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ របស់ក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័ត នៃរដ្ឋបាលព្រៃឈើ ចោទប្រកាន់ចំពោះឈ្មោះ ។

-ដីកាអមលេខៈ ១៤១៣ រព.នន៣ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ របស់រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងឯកសារភ្ជាប់ជាមួយ ។

-ឯកសារគតិយុត្តដែលពាក់ពន្ធ័ក្នុងសំណុំរឿង ។

**យល់ឃើញថាៈ**

១-កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ២០ នាទី ក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័ត នៃរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយរដ្ឋបាលជលផល និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានចុះប្រតិបត្តិការបង្ក្រាបបទល្មើស សត្វព្រៃ និងសំណាកសត្វព្រៃ នៅចំណុចអាហារដ្ឋាន វិចិត្រា ស្ថិតតាមបណ្តោយផ្លូវ២៨៥ ផ្ទះលេខ៤២ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឆែកឆេរឃើញមានសំណាកសត្វចាបពួក(ចោចរួច) ចំនួន ៣២៤ក្បាល ដែលមានឈ្មោះ                    ភេទប្រុស អាយុ ២៧ឆ្នាំ ជាអ្នកទទួលខុសត្រូវ ។ ក្រោយការឆែកឆេរឈ្មោះ                    បានសារ ភាពថាៈ ខ្លួនពិតជាបានទទួលទិញយកមករក្សាទុកដើម្បីធ្វើម្ហូបលក់បន្តដោយគ្មានលិខិតអនុញ្ញាត ពីរដ្ឋបាលព្រៃឈើ ពិតប្រាកដមែន ។

២-ចម្លើយរបស់ឈ្មោះ **យន ដាង** ភេទ ប្រុស អាយុ ២៧ឆ្នាំ ឆ្លើយនៅ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឆ្លើយបញ្ជាក់ថាៈ ខ្លួនដឹងថាការកាធ្វើពាណិជ្ជកម្ម សំណាកសត្វព្រៃជាអំពើខុសច្បាប់ ។ ចំពោះសំណាកជាសត្វព្រៃទាំងអស់ខាងលើ ខ្លួនទិញពីខេត្តព្រៃវែង មានរយៈពេល២សប្តាហ៍ហើយ ដើម្បីធ្វើម្ហូបលក់បន្តនៅអាហារដ្ឋាន វិចិត្រា ដោយគ្មានការអនុញ្ញាត ពីរដ្ឋបាលព្រៃឈើឡើយ ។

៣-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីចោទប្រកាន់លើឈ្មោះ                    ភេទប្រុស កើតថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ ពីបទៈ **ធ្វើពាណិជ្ជកម្មសត្វព្រៃ និងសំណាកសត្វព្រៃដោយគ្មានលិខិតអនុញ្ញាត** ប្រព្រឹត្តនៅអាហារដ្ឋាន វិចិត្រា ផ្ទះលេខ៤២ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥០ និងមាត្រា ៩៦ កថាខណ្ឌ ១ ចំណុច ១៩ នៃច្បាប់ស្តីពីព្រៃឈើ ។

## **ហេតុដូច្នេះសម្រេច**

ចោទប្រកាន់៖

-ឈ្មោះ                    ភេទប្រុស កើតថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិព្រៃកគ្រីស ស្រុកកំពង់ត្រាច ខេត្តកំពត, កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិកោះត្នោត ឃុំព្រៃកគ្រីស ស្រុកកំពង់ត្រាច ខេត្តកំពត, មុខរបរ ចុងភៅ ,ប្រពន្ធឈ្មោះ                    "រស់", មានកូនចំនួន ០២នាក់, ឪពុកឈ្មោះ                    "រស់", ម្តាយឈ្មោះ                    "រស់" កំរិតវប្បធម៌ ថ្នាក់ទី ១០ថ្មី , ទោសពីមុន គ្មាន ។

-ត្រូវជាប់ចោទពីបទៈ **ធ្វើពាណិជ្ជកម្មសត្វព្រៃ និងសំណាកសត្វព្រៃដោយគ្មានលិខិតអនុញ្ញាត** ប្រព្រឹត្តនៅអាហារដ្ឋាន វិចិត្រា ផ្ទះលេខ៤២ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥០ និងមាត្រា ៩៦ កថាខណ្ឌ ១ ចំណុច ១៩ នៃច្បាប់ស្តីពីព្រៃឈើ ។

-បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៨៣០ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០២០ និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងសំណុំរឿងនេះទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់ ។

ថ្ងៃ [illegible].......... [illegible]..... ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី .....16..... ខែធ្នូ ឆ្នាំ២០២០

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ថ្ងៃទី 09 ខែ 02 ឆ្នាំ 2021

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៧៣៦
ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២១
លេខ:..........016..........អ.យ.ណ

## កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ឆ្នាំពីរពាន់ម្ភៃមួយ ខែកុម្ភៈ ថ្ងៃទី...09... វេលាម៉ោង ...3..... និង..40...នាទី

**យើង ចែ សុខ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញរបាយការណ៍សំយោគលេខ: ០៧០/០២១ រ.ប.ក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ៣០ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិកាយបាំង ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅបច្ចុប្បន្នស្នាក់នៅកាយបាំង ឃុំសឹង្ហ ខេត្តតាកែវ, មុខរបរ ជាងបោះពុម្ព, នៅលីវ, ឪពុកឈ្មោះ "រស់", ម្តាយឈ្មោះ "រស់", ទោសពីមុន គ្មាន ។

**យើងប្រាប់ដល់បុគ្គលទាំងនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ:** កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ៨ និង ០០ នាទី ត្រង់ចំណុចមុខការដ្ឋានចិន លើផ្លូវ៦០ម៉ែត្រ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងរវាងម៉ូតូម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ តាកែវ 1T-3547 បើកបរដោយឈ្មោះ ភេទប្រុស អាយុ ៣០ឆ្នាំ ធ្វើដំណើរតាមបណ្តោយផ្លូវ៦០ម៉ែត្រ ទិសដៅពីត្បូងទៅជើង លុះមកដល់ចំណុចកើតហេតុខាងលើ បានបុកអ្នកថ្មើរជើងឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ ដែលដើរឆ្លងថ្នល់ ទិសដៅពីលិចទៅកើត បណ្តាលឲ្យស្លាប់ក្រោយពេលព្យាបាលនៅមន្ទីរពេទ្យព្រះកុសុមៈ ។

**អង្គហេតុនេះជាបទល្មើស ៖ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា និងមិនប្រុងប្រយ័ត្ន បណ្តាលឲ្យស្លាប់ដល់**អ្នកដទៃ ប្រព្រឹត្តនៅចំណុចមុខការដ្ឋានចិន ផ្លូវ៦០ម៉ែត្រ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**យើងបានទទួលចម្លើយពីជនទាំងនេះដូចតទៅថា៖** មូលហេតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ចរាចរណ៍ កើតឡើង គឺដោយសារអ្នកបើកបរម៉ូតូមានល្បឿនខ្វះការប្រុងប្រយ័ត្ន បណ្តាលឲ្យមានមនុស្សស្លាប់០១នាក់ និងរបួសស្រាល០១នាក់ ដូច្នេះការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក ស្នើសុំបញ្ជូនសំណុំរឿង និងវត្ថុតាង ព្រមទាំងអ្នកបើកបរម៉ូតូមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ បន្ទាប់ពីជនបង្កឈ្មោះ បានធ្វើការសងសំណងទៅឲ្យគ្រួសារសពរួច ឈ្មោះ (ជាប្រពន្ធសពឈ្មោះ ) បានសំណើសុំដកពាក្យបណ្តឹងឈប់ប្តឹងផ្តល់លើឈ្មោះ ភេទប្រុស អាយុ ៣០ឆ្នាំ ។

ឲ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

**ជននេះបានឆ្លើយថា:**

☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី.......................................................................................។

☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

**យើងបានបញ្ជាក់ថា:**

☐ លោក/លោកស្រី.................................អាចពិនិត្យសំណុំរឿងនឹងទាក់ទងជាមួយជនជាប់ចោទ ។

☐ យោងលើសំណុំសុំឲ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ ស្តីពីលក្ខន្តិកៈមេធាវីតំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐ លោក/លោកស្រីមេធាវី.............................................................................អវត្តមាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**សម្រេច:**

បញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣០ឆ្នាំ ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

**ជនជាប់ចោទ** **តំណាងអយ្យការ**





**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ចូល ថ្ងៃទី 07 ខែ 02 ឆ្នាំ 2021

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៧០២
ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១
លេខ: 015 អ.យ.ណ

## កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ឆ្នាំពីរពាន់ម្ភៃមួយ ខែកុម្ភៈ ថ្ងៃទី 07 វេលាម៉ោង 11 និង 00 នាទី

**យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញរបាយការណ៍សំយោគលេខ: ០១៥/២១ ស.ប.ក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

១-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ២២ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិធ្លករលើង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅក្នុងការដ្ឋានភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ, មុខរបរ កម្មករសំណង់, នៅលីវ, ឪពុកឈ្មោះ "រស់", ម្តាយឈ្មោះ "រស់", ទោសពីមុន គ្មាន ។ (ឃាត់ខ្លួន)

២-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ២១ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិធ្លករលើង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ស្ពឺ, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅក្នុងរោងកម្មករ ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ, មុខរបរ កម្មករសំណង់, នៅលីវ, ឪពុកឈ្មោះ "រស់", ម្តាយឈ្មោះ "រស់" ទោសពីមុន គ្មាន, ។ (ឃាត់ខ្លួន)

៣-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ១៩ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិត្រពាំងត្បាល ឃុំមុខដា ស្រុករមាសហែក ខេត្តស្វាយរៀង, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅក្នុងរោងកម្មករ ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ, មុខរបរ កម្មករសំណង់, នៅលីវ, ឪពុកឈ្មោះ "រស់", ម្តាយឈ្មោះ "រស់" ទោសពីមុន គ្មាន, កម្រិតវប្បធម៌ ថ្នាក់ទី៧ថ្មី ។ (ឃាត់ខ្លួន)

៤-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ២១ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិធ្លករលើង ឃុំលោផ្ទៀ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅក្នុងរោងកម្មករ ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ, មុខរបរ កម្មករសំណង់, ប្រពន្ធឈ្មោះ សោ សុភា (លេងលះ) មានកូន ០១នាក់, ឪពុកឈ្មោះ "រស់", ម្តាយឈ្មោះ "រស់", ទោសពីមុន គ្មាន, កម្រិតវប្បធម៌ ថ្នាក់ទី៧ថ្មី ។ (ឃាត់ខ្លួន)

៥-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ២០ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិឫស្សីជុកត្បូង ឃុំកា ស្រុកពារាំង ខេត្តព្រៃវែង, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅក្នុងរោងកម្មករ ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ, មុខរបរ កម្មករសំណង់, នៅលីវ, ឪពុកឈ្មោះ "រស់", ម្តាយឈ្មោះ "រស់", ទោសពីមុន គ្មាន, កម្រិតវប្បធម៌ ថ្នាក់ទី៥ថ្មី ។ (ឃាត់ខ្លួន)

**យើងប្រាប់ដល់បុគ្គលទាំងនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ:** កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ២១ និង ៣០ នាទី មុនពេលកើតហេតុ ជនសង្ស័យ រួមមាន៖ ១.ឈ្មោះ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ២.ឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ៣.ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ៤. ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ជាកម្មករសំណង់ របស់ការដ្ឋានសំណង់បុរីអ័រគីដេ (សង្កាត់អូរបែកក្អម) ។ នៅយប់ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ជនសង្ស័យ ១.ឈ្មោះ ២.ឈ្មោះ ៣.ឈ្មោះ បានធ្វើសកម្មភាពលួច យកខ្សែភ្លើង (ខ្សែទោល) មួយចំនួន របស់ការដ្ឋាន រុំជាប់នឹងដងខ្លួនពាក់ អាវគ្របពីលើដើរចេញមកក្រៅការដ្ឋាន ត្រូវជន រងគ្រោះឈ្មោះ

កេទប្រុស អាយុ ៥៨ឆ្នាំ ជនជាតិពីលីពីន (ជាប្រធានគ្រប់គ្រងផ្នែកសុវត្ថិភាពរបស់ ការដ្ឋាន) និងឈ្មោះ សយ សុខដាលី កេទប្រុស អាយុ ៣៥ឆ្នាំ (ជាសន្តិសុខយាមប្រចាំការរបស់ការដ្ឋាន) ឆែកឆេរលើដងខ្លួនជនសង្ស័យ ឃើញ បានឲ្យជនសង្ស័យស្រាយខ្សែភ្លើងចេញពីដងខ្លួន ហើយជនរងគ្រោះ និងឈ្មោះ សយ សុខដាលី បាននាំខ្លួនជនសង្ស័យ ១.ឈ្មោះ ២.ឈ្មោះ ៣.ឈ្មោះ ៤.ឈ្មោះ ៥.ឈ្មោះ រួមទាំងវត្ថុតាងខ្សែភ្លើង យកមកប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលបាលអូរបែកក្អម ធ្វើការសាកសួរ ។

នៅពេលសាកសួរ ជនសង្ស័យឈ្មោះ និងឈ្មោះ បានសារភាពនូវសកម្មភាពនៅពេល ថ្ងៃត្រង់ ថ្ងៃ (មិនចាំ) ក្នុងធ្នូ ឆ្នាំ២០២០ ជនសង្ស័យឈ្មោះ និងឈ្មោះ បានធ្វើការសកម្មភាពលួច យកខ្សែភ្លើងរបស់ការដ្ឋាន យកទៅលក់បានប្រាក់ចំនួន ២៨,០០០ រៀល ហើយជនរងគ្រោះ បានដាក់ពាក្យបណ្តឹងចោទប្រកាន់លើជនសង្ស័យទាំង០៥នាក់ (នាក់លើ) តែម្តង ។

អង្គហេតុនេះជាបទល្មើស ៖ លួច ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

យើងបានទទួលចម្លើយពីជនទាំងនេះដូចតទៅថា៖ បានជាសមត្ថកិច្ចឃាត់ខ្លួនពួកខ្លួន គឺដោយសារកាលពីថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ២១ និង ៣០ នាទី ពួកខ្លួនបានធ្វើសកម្មភាពលួចយកខ្សែភ្លើងមករុំលើខ្លួននៅលើអគារក្នុងការដ្ឋានជាន់ទី៦ ហើយដើរជិះជណ្តើរយន្តចុះមកក្រោម ជាន់ផ្ទាល់ដី ស្រាប់តែត្រូវសន្តិសុខដែលយាមនៅការដ្ឋាន មានការសង្ស័យលើពួកខ្លួនក៏ហៅឈប់ និងត្រួតពិនិត្យ រកឃើញខ្សែភ្លើងលើដងខ្លួនពួកខ្លួន រួចប្រគល់ឲ្យសមត្ថកិច្ចធ្វើការឃាត់ខ្លួនពួកខ្លួន និងដកហូតវត្ថុតាងតែម្តង ។ បន្ទាប់ពីជនសង្ស័យទាំង០៥នាក់ ឆ្លើយសារភាពរួច ដើមបណ្តឹងបានធ្វើការដកពាក្យបណ្តឹង ។

ឲ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

ជននេះបានឆ្លើយថា:

☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី.......................................................................................។

☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

យើងបានបញ្ជាក់ថា:

☐ លោក/លោកស្រី................................អាចពិនិត្យសំណុំរឿងនឹងទាក់ទងជាមួយជនជាប់ចោទ ។

☐ យោងលើសំណុំសុំឲ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ ស្តីពីលក្ខន្តិកៈមេធាវីតំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐ លោក/លោកស្រីមេធាវី.......................................................................អវត្តមាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**<u>សម្រេច:</u>**

បញ្ជូនជនជាប់ចោទឈ្មោះ កេទប្រុស អាយុ ២២ឆ្នាំ , ឈ្មោះ កេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ ,កេទប្រុស អាយុ ១៩ឆ្នាំ , ឈ្មោះ កេទប្រុស អាយុ ២១ឆ្នាំ និងឈ្មោះ កេទប្រុស អាយុ ២០ឆ្នាំ ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើស ដូចខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

**ជនជាប់ចោទ** **តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូង រាជធានីភ្នំពេញ

លេខ : ៦៣១ អ.យ.ណ

## ដីកាតម្កល់រឿងទុកឥតចាត់ការ

### យើង ថៃ សុខ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ១៤៤៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងកស្តុតាងនានា ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា:

១. អវត្តមានបទល្មើស

☐ អវត្តមានបទល្មើស

២.ជាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ជាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣.មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយវង្វេ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូ

៤.៤. ☐ ការខកខានរបស់ដើមបណ្តឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

---

[1] ដូចជាមួយហេតុផលដទៃ ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ដើមបណ្តឹងឈប់ប្តឹង

៤.៦. ☐ ជនរងគ្រោះមិនតាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[3]

៤.៨. ☐ ព្យសនកម្ម ឬ ការខាតតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[4]

៥.៣. ☐ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្តឹងតាមការបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរំលឹកពីអត្ថបទច្បាប់ / ការព្រមាន[5]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ពន្ធ័សុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☑ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

ការសង្កេតផ្សេងៗ៖ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ឈ្មោះ កេទស្រី អាយុ៣៤ ឆ្នាំ បានខ្ចីចងការប្រាក់ចំនួន USD២,០០០(ពីរពាន់ដុល្លារអាមេរិក) មានអាត្រាការប្រាក់ចំនួន១៥% ពីឈ្មោះ ។ បន្ទាប់មកនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ បានខ្ចីចងការប្រាក់ចំនួន USD១,០០០ (មួយពាន់ដុល្លារអាមេរិក) មានអាត្រាការប្រាក់ចំនួន១៥% ពីឈ្មោះ បន្ថែមទៀត ហើយឈ្មោះ បានបង់រំលស់ប្រាក់ដើម និងការប្រាក់ ឱ្យទៅឈ្មោះ ជាទៀងទាត់ ។ លុះនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ឈ្មោះ ត្រូវបង់ប្រាក់ដើម និងការប្រាក់ផ្តាច់សរុបចំនួន USD៦០០ (ប្រាំមួយរយដុល្លារអាមេរិក)ឱ្យទៅឈ្មោះ ប៉ុន្តែបានបង់យឺតយ៉ាវ ។ រហូតដល់អំឡុងខែមីនា ឆ្នាំ២០២១ ឈ្មោះ បានបង្ហោះហ្វេសប៊ុកតាមគណនីហ្វេសប៊ុកឈ្មោះ Thearith Sing Sing Ruos ពាក់ព័ន្ធនឹងឈ្មោះ មិនព្រមសងប្រាក់ខ្លួន និងពាក្យពេជន៍ផ្សេងៗទៀត ... ។ល។ បន្ទាប់មកនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ឈ្មោះ បានដាក់ពាក្យបណ្តឹងនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ប្តឹងចោទប្រកាន់ឈ្មោះ ហៅ ពីបទ៖ បរិហារកេរ្តិ៍, ជេរប្រមាថជាធារណៈ និងញុះញង់ឱ្យមានការរើសអើង ។

**បានឃើញ៖**

-ពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ឈ្មោះ កេទស្រី អាយុ៣៤ឆ្នាំ និងកស្តុតាងភ្ជាប់ជាមួយ ។

-កំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងឈ្មោះ កេទស្រី អាយុ៣៤ ឆ្នាំ នៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឆ្លើយអះអាងថា៖ខ្លួនសុំរក្សាពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ខ្លួនទុកទាំងស្រុង និងសុំឆ្លើយបញ្ជាក់បន្ថែមទៀតថា នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ខ្លួនបានខ្ចីចងការប្រាក់ចំនួន

---

[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[4] ករណីចែងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6] ករណីចែងដោយច្បាប់

USD២,០០០ (ពីរពាន់ដុល្លារអាមេរិក) មានអាត្រាការប្រាក់ចំនួន១៥% ពីឈ្មោះ ហើយគាត់បានបាញ់ប្រាក់ចំនួន UDS ១,៧០០ (មួយពាន់ប្រាំពីររយដុល្លារអាមេរិក)តាមអាគរខោនធនាគារ ABA ឱ្យមកខ្លួន ដោយដកការប្រាក់មុនចំនួន USD៣០០ (បីរយដុល្លារអាមេរិក) ។ បន្ទាប់មកនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានខ្ចីចងការប្រាក់ចំនួន USD១,០០០(មួយពាន់ដុល្លារអាមេរិក)មានអាត្រាការប្រាក់ចំនួន១៥% ពីឈ្មោះ បន្ថែមទៀត ហើយគាត់បានបាញ់ប្រាក់ចំនួន UDS៧០០ (ប្រាំពីររយដុល្លារអាមេរិក)តាមអាគរខោនធនាគារ ABA ឱ្យមកខ្លួន ដោយដកការប្រាក់មុន USD៣០០(បីរយដុល្លារអាមេរិក) ទៀត ។ ក្រោយពីខ្លួនខ្ចីចងការប្រាក់ពីឈ្មោះ ខ្លួនបានបង់រំលស់ប្រាក់ដើម និងការប្រាក់ ឱ្យទៅឈ្មោះ ជាទៀងទាត់ ។ លុះនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ខ្លួនត្រូវបង់ប្រាក់ដើម និងការប្រាក់ផ្តាច់សរុបចំនួន USD៦០០ (ប្រាំមួយរយដុល្លារអាមេរិក)ឱ្យទៅឈ្មោះ ប៉ុន្តែខ្លួនបានបង់យឺតត្រឹមតែពីរថ្ងៃដោយសារមូលហេតុខ្លួនបិទហាង និងអត់នៅផ្ទះ ។ រហូតដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ និងរំលងបានមួយសប្តាហ៍ និងមួយសប្តាហ៍ក្រោយទៀត ក្នុងអំឡុងខែមីនា ឆ្នាំ២០២១ បែរជាឈ្មោះ បានបង្ហោះហ្វេសប៊ុក បរិហារកេរ្តិ៍ ជេរប្រមាថជាធារណៈ និងញុះញង់ឱ្យមានការរើសអើង មកលើខ្លួនធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ និងប៉ះពាល់ដល់មុខរបររកស៊ីរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរ ដូចខ្លួនបានរៀបរាប់នៅក្នុងពាក្យបណ្តឹង និងសកម្មភាពនៅក្នុងអង្គចងចាំ ដែលខ្លួនបានដាក់ជូនភ្ជាប់ជាមួយពាក្យបណ្តឹង ។

-ពាក្យការពារក្តី និង តំណាងក្តី ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ របស់មេធាវី និងមេធាវី ។

-ពាក្យស្នើសុំចាត់សំណុំរឿង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ របស់មេធាវី ។

-ដីកាកោះហៅឈ្មោះ ហៅ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលារាជធានីភ្នំពេញ ។

-ឯកសារសំខាន់ផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង ។

**<u>យល់ឃើញថា:</u>**

-ពាក្យបណ្តឹងរបស់ឈ្មោះ បានប្តឹងចោទប្រកាន់លើឈ្មោះ ហៅ ភេទស្រី ពីបទ៖ បរិហារកេរ្តិ៍, ជេរប្រមាថជាធារណៈ និងញុះញង់ឱ្យមានការរើសអើង ។

-ក្រោយការស៊ើបអង្កេតជាបឋមឃើញថាជាបទល្មើសលហុ ហើយឈ្មោះ ហៅ ពុំមានសាវតារគ្រប់គ្រាន់ ដើម្បីដំណើរការនីតិវិធីបន្តទៀតបានឡើយ ។

-ហេតុដូចនេះគប្បីតំណាងអយ្យការសម្រេចតម្កល់សំណុំរឿងនេះទុកឥតចាត់ការ តាមបញ្ញត្តិមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះសម្រេច</u>

□-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ: ១៤៤៦ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកឥតចាត់ការ ។

ថ្ងៃ...១៤ ៣កើត...... ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី...២១...... ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូង រាជធានីភ្នំពេញ

លេខ : ៦២៤ អ.យ.ណ

## ដីកាតម្កល់រឿងទុកឥតចាត់ការ

## យើង ថៃ សុខ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ៥២០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងកស្តុតាងនានា ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា:

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២.ជាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ជាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣.មូលហេតុគតិយុត្ត

៣.១. ☑ ការដកពាក្យបណ្ដឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយរង្វ

៣.៨. ☐ ការបង់ប្រាក់ពិន័យសុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្ដល់ផលប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[2]

៤.៣. ☐ ស្ថានភាពរំលោភសង្គមតិចតួចដែលបន្ថយនូវការដឹងខុសខុសត្រូវ

៤.៤. ☐ ការខកខានរបស់ដើមបណ្ដឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

[1] ដូចជាមួយហេតុផលចៃដន្យ ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ដើមបណ្ដឹងឈប់ប្ដឹង

៤.៦. ☐ ជនរងគ្រោះមិនតាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[3]

៤.៨. ☐ ព្យសនកម្ម ឬ ការខាតបង់តិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ជល់អនីតិជន

៥.២. ☐ សន្ទានកម្ម[4]

៥.៣. ☐ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្តឹងតាមការបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរំលឹកពីអត្ថបទច្បាប់ / ការព្រមាន[5]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ពន្ធ័សុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការបោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

ការសង្កេតផ្សេងៗ៖ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ ភេទប្រុស អាយុ៤០ ឆ្នាំ ជាអគ្គនាយកក្រុមហ៊ុន និងឈ្មោះ ជាម្ចាស់ក្រុមហ៊ុន បានចុះកិច្ចព្រមព្រៀងនៃការទិញលក់ដែកសម្រាប់ផ្គត់ផ្គង់ខួងគ្រឹះ ដោយលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងបានតម្រូវឱ្យភាគីឈ្មោះ ចេញមូលប្បទានប័ត្រលេខ: ២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ នូវទឹកប្រាក់ចំនួន៦០,០០០USD(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដាក់តម្កល់ធានាក្នុងការទិញលក់ដែកនេះ ។ លុះរហូតដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ក្រុមហ៊ុន បានបញ្ជាទិញដែកពីក្រុមហ៊ុន ដែលមានទឹកប្រាក់ ៤៥,០៥៩USD(បួនម៉ឺនប្រាំពាន់ហាសិបប្រាំបួនដុល្លារអាមេរិក) ហើយខាងក្រុមហ៊ុន និងក្រុមហ៊ុន តំណាងដោយឈ្មោះ បានព្រមព្រៀងគ្នាដោយឱ្យក្រុមហ៊ុន ខុទាត់ប្រាក់ថ្លៃទិញដែកឱ្យក្រុមហ៊ុន ជាដំណាក់កាលៗ រហូតដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១ នៅសល់តែទឹកប្រាក់ចំនួន ៨,៥៥៩USD (ប្រាំបីពាន់ប្រាំរយហាសិបប្រាំបួនដុល្លារអាមេរិក) ។ បន្ទាប់មកនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ

បានយកមូលប្បទានប័ត្រលេខ: ២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ នូវទឹកប្រាក់ចំនួន ៦០,០០០USD (ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលឈ្មោះ ពិសិដ្ឋ ម៉ាក់ឌីន បានដាក់តម្កល់ធានានៃការទិញលក់ដែកខាងលើប្តឹងឈ្មោះ នៅនាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងមហាផ្ទៃ ចាត់ការតាមនីតិវិធីកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ រហូតដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១

[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[4] ករណីចែងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6] ករណីចែងដោយច្បាប់

ឈ្មោះ                                     បានដាក់ពាក្យស្នើសុំដកពាក្យបណ្ដឹងរបស់ខ្លួនវិញដោយលើកឡើងថាឈ្មោះ
បានទូទាត់សងបំណុលខ្លួនគ្រប់ចំនួនហើយ ។

**បានឃើញ៖**

-ពាក្យបណ្ដឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ របស់ឈ្មោះ          ភេទស្រី អាយុ៣០ឆ្នាំ តំណាងឱ្យឈ្មោះ          ភេទប្រុស ជនជាតិកូរ៉េ ប្ដឹងនៅនាយកដ្ឋាននគរបាលប្រហ្មទណ្ឌ និងកស្តុតាងភ្ជាប់ជាមួយ ។

-កំណត់ហេតុបណ្ដឹងរបស់ឈ្មោះ          ភេទស្រី អាយុ៣០ ឆ្នាំ នៅការិយាល័យអនុវត្តដីកា ឆ្លើយអះអាងថា៖ កាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ          ជាអគ្គនាយកក្រុមហ៊ុន          បានទំនាក់ទំនងទិញដែកថ្លាំងអំពៅពីក្រុមហ៊ុន របស់ខ្លួនចំនួន ១០១តោន សរុបទឹកប្រាក់ ៦០,០០០USD(ប្រាំមួយម៉ឺនដុល្លារអាមេរិក)។ បន្ទាប់មកឈ្មោះ          បានចេញមូលប្បទានប័ត្រមួយសន្លឹក ចុះកាលបរិច្ឆេទថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ          មានទឹកប្រាក់ចំនួន៦០,០០០USD(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ពេលដល់កំណត់បើកប្រាក់ ខ្លួនក៏យកមូលប្បទានប័ត្រនេះទៅបើកប្រាក់ ហើយខាងធនាគារបញ្ជាក់ថាគ្មានសាច់ប្រាក់ឡើយ និងកុងធនាគាររបស់ឈ្មោះ          បានបិទ ។

-កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ          មេធាវីការពារក្ដី និងតំណាងដោយអាណត្តិឱ្យដើមបណ្ដឹង          នៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងពាក្យស្នើសុំផ្ដល់ចម្លើយបន្ថែម ឆ្លើយស៊ំអាងថា៖ ឈ្មោះ          បានធ្វើការបញ្ជាការទិញដែកពីក្រុមហ៊ុនកូនក្ដីជាច្រើនលើក សរុប ចំនួន១១តោន ដែលមានតម្លៃសរុបចំនួន USD60,000(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ហើយឈ្មោះ          បានចេញមូលប្បទានប័ត្ររបស់ធនាគារ          លេខ 222158 ចុះថ្ងៃទី២៤ ខែ០៦ ឆ្នាំ២០២០ នូវទឹកប្រាក់ចំនួន USD60,000(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដើម្បីទូទាត់ថ្លៃដែកដែលជំពាក់កូនក្ដីខ្លួន ។ បន្ទាប់មកកូនក្ដីខ្លួនបានយកមូល ប្បទានប័ត្រនេះទៅបើកប្រាក់នៅធនាគារ ហើយខាងធនាគារបានបញ្ជាក់ថាគណនីបានបិទ មិនអាចធ្វើការទូទាត់បានឡើយ ដូចមានលិខិតមូលប្បទានប័ត្របញ្ជូនត្រឡប់ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ          ។ បន្ទាប់មកកូនក្ដីខ្លួនបានទៅជួបឈ្មោះ          ឱ្យទូទាត់សងប្រាក់គ្រប់ចំនួន ប៉ុន្តែឈ្មោះ          បានសងប្រាក់តែចំនួន USD40,000(បួនម៉ឺនដុល្លារអាមេរិក) នៅជំពាក់កូនក្ដីខ្លួន USD20,000(ពីរម៉ឺនដុល្លារអាមេរិក)។

-កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ          ភេទប្រុស អាយុ៤០ ឆ្នាំ នៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឆ្លើយអះអាងថា៖ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ខ្លួន និងឈ្មោះ          បានចុះកិច្ចព្រមព្រៀងនៃការទិញលក់ដែកសម្រាប់ផ្គត់ផ្គង់ការខ្វះគ្រឿ៖ ដោយលក្ខខណ្ឌក្នុងការព្រមព្រៀង បានតម្រូវឱ្យភាគីខ្លួនចេញមូលប្បទានប័ត្រលេខ: ២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ          នូវទឹកប្រាក់ចំនួន ៦០,០០០USD (ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដាក់តម្កល់ធានាក្នុងការទិញលក់ដែក ប៉ុន្តែការទិញលក់ដែកនេះខាងក្រុមហ៊ុនខ្លួនមិនមែនទិញម្ដងស្មើទឹកប្រាក់ចំនួន៦០,០០០USD(ប្រាំមួយម៉ឺនដុល្លារអាមេរិក) នៃការចេញមូលប្បទានប័ត្រនេះទេ ដោយការទិញដែកម្ដងៗគឺក្រុមហ៊ុនខ្លួនបានទូទាត់ថ្លៃទិញដែកជារៀងរាល់ខែ តាមចំនួនថ្លៃទិញដែកជាក់ស្តែងជូនកាលទូទាត់ប្រាក់ឱ្យក្រុមហ៊ុន          តំណាងដោយឈ្មោះ          ជាសាច់ប្រាក់ផ្ទាល់ឬចេញមូលប្បទានប័ត្រឱ្យ ។ លុះហូតដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ក្រុមហ៊ុនខ្លួនបានបញ្ជាទិញដែកពីក្រុមហ៊ុន          ដែលមានទឹកប្រាក់ ៤៥,០៥៩USD(បួនម៉ឺនប្រាំពាន់ហាសិបប្រាំបួនដុល្លារអាមេរិក) ហើយខាងក្រុមហ៊ុនខ្លួន និងក្រុមហ៊ុន          តំណាងដោយឈ្មោះ          បានព្រមព្រៀងគ្នា ដោយឱ្យក្រុមហ៊ុនខ្លួនបង់ប្រាក់ឱ្យក្រុមហ៊ុន          ជាដំណាក់កាលៗ រហូតដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២១ នៅសល់តែទឹកប្រាក់ចំនួន៨,៥៥៩USD (ប្រាំបីពាន់ប្រាំរយហាសិបប្រាំបួនដុល្លារអាមេរិក) ដែលក្រុមហ៊ុនខ្លួននៅមិនទាន់ទូទាត់ឱ្យក្រុមហ៊ុន          ។ ផ្ទុយទៅវិញនៅពេលខ្លួនបានទទួលដីកាកោះលើកទី២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទើបខ្លួនបានដឹងថា: ឈ្មោះ          បានយកមូលប្បទានប័ត្រលេខ: ២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ          នូវទឹកប្រាក់ចំនួន ៦០,០០០USD

(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលខ្លួនបានដាក់តម្កល់ជានា នៃការទិញលក់នេះ យកមកប្តឹងខ្លួននៅក្រសួងមហាផ្ទៃ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ដែលខុសពីការពិតទាំងស្រុង ។ ក្នុងរឿងនេះមានឆន្ទៈក្នុងការដោះស្រាយខូទាត់ប្រាក់ថ្លៃទិញដែកនៅសល់ចំនួន ៨,៥៥៩USD (ប្រាំបីពាន់ប្រាំរយហាសិបប្រាំបួនដុល្លារអាមេរិក) និងការប្រាក់ចំនួន ៤៤១USD (បួនរយសែសិបមួយដុល្លារអាមេរិក) ឱ្យទៅក្រុមហ៊ុន តំណាងដោយឈ្មោះ ។ ខ្លួនសូមសំណូមពរលោកតំណាងអយ្យការមេត្តាជួយតម្កល់រឿងនេះទុកឥតចាត់ការ ។

-ពាក្យតំណាង/ការពារក្តី និងសុំថតចម្លងសំណុំរឿង ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់មេធាវី ។

-ពាក្យស្នើសុំផ្តល់ចម្លើយបន្ថែម និងស្នើសុំឱ្យពិនិត្យកស្តុតាង ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១របស់មេធាវី ។

-ពាក្យសុំការពារក្តី,ពាក្យសុំថតចម្លងសំណុំរឿង និងពាក្យសុំពន្យារពេល ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់មេធាវី សាន់ ម៉ាន់ ។

-ពាក្យសុំបញ្ចូលកស្តុតាង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ របស់ឈ្មោះ ។

-ពាក្យស្នើសុំដកពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ របស់ឈ្មោះ ។

-ឯកសារសំខាន់ផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង ។

__យល់ឃើញថា:__

-តាមចម្លើយរបស់ឈ្មោះ និងចម្លើយរបស់មេធាវី ដែលជាអ្នកតំណាងឱ្យឈ្មោះ រួមទាំងបានពិនិត្យឯកសារពាក់ព័ន្ធបញ្ជាក់ថា: នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន និងឈ្មោះ ជាម្ចាស់ក្រុមហ៊ុន អិលធីឌី បានចុះកិច្ចព្រមព្រៀងនៃការទិញលក់ដែក ហើយឈ្មោះ បានចេញមូលប្បទានប័ត្រលេខ: ២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ នូវទឹកប្រាក់ចំនួន៦០,០០០USD(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដើម្បីខូទាត់ថ្លៃទិញដែកនេះឱ្យឈ្មោះ ហើយនៅពេលឈ្មោះ យកមូលប្បទានប័ត្រនេះទៅបើកប្រាក់ ខាងធនាគារបញ្ជាក់ថាគ្មានសាច់ប្រាក់ឡើយ ។ បន្ទាប់មកឈ្មោះ បានខូទាត់ប្រាក់ថ្លៃទិញដែកនេះឱ្យឈ្មោះ បានតែចំនួន ៤០,០០០USD (បួនម៉ឺនដុល្លារអាមេរិក) នៅខ្វះចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ទៀត ។

-តាមការពិនិត្យឯកសារកស្តុតាង និងចម្លើយរបស់ឈ្មោះ បានបញ្ជាក់ថា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន និងឈ្មោះ ជាម្ចាស់ក្រុមហ៊ុន បានចុះកិច្ចព្រមព្រៀងនៃការទិញលក់ដែក ហើយឈ្មោះ បានចេញមូលប្បទានប័ត្រលេខ:២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ មានទឹកប្រាក់ចំនួន ៦០,០០០USD (ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដាក់តម្កល់ដើម្បីខូទាត់ថ្លៃទិញដែកនេះឱ្យឈ្មោះ ហើយឈ្មោះ បានបញ្ជាទិញដែកជាច្រើនលើកពីក្រុមហ៊ុនរបស់ឈ្មោះ និងបានខូទាត់ប្រាក់ថ្លៃទិញដែកនេះជាបន្តបន្ទាប់ឱ្យឈ្មោះ នៅសល់តែទឹកប្រាក់ចំនួន ៨,៥៥៩USD (ប្រាំបីពាន់ប្រាំរយហាសិបប្រាំបួនដុល្លារអាមេរិក)ប៉ុណ្ណោះ ។ ផ្ទុយទៅវិញឈ្មោះ បានយកមូលប្បទានប័ត្រលេខ:២២២១៥៨ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ធនាគារ នូវទឹកប្រាក់ចំនួន៦០,០០០ USD(ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលខ្លួនដាក់តម្កល់ខាងលើប្តឹងខ្លួនទៅវិញ ។

-តាមពាក្យស្នើសុំដកពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ របស់ឈ្មោះ បានបញ្ជាក់ថាឈ្មោះ បានខូទាត់ប្រាក់ជំពាក់ថ្លៃទិញដែកឱ្យខ្លួនចំនួន ៩,០០០USD (ប្រាំបួនពាន់ដុល្លារអាមេរិក) រួចហើយ ។

-តាមអង្គហេតុនៃសំណុំរឿងនេះ ពុំមានទំហំព្យសនកម្មបង្កឱ្យមានភាពរំភើបរប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសន្តិសុខសាធារណៈសង្គមធ្ងន់ធ្ងរនោះទេ ។

-ហេតុដូចនេះគប្បីតំណាងអយ្យការសម្រេចតម្កល់សំណុំរឿងនេះទុកឥតចាត់ការ តាមបញ្ញត្តិមាត្រា ៤១ និង មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

<u>**ហេតុដូច្នេះសម្រេច**</u>

□-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥២០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកឥតចាត់ការ ។

ថ្ងៃ អង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**